**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sports


**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education


# និក្ខេបបទ

# ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា កម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ

# THE IMPLEMENTATION OF HISTORY CURRICULUM AT HIGH SCHOOL LEVEL IN PHNOM PENH


**ដោយ**/By

**ស៊ុន ផុន**

SUN PHON


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២០**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា កម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ

## THE IMPLEMENTATION OF HISTORY CURRICULUM AT HIGH SCHOOL LEVEL IN PHNOM PENH

ដោយ/By
**ស៊ុន ផុន**
SUN PHON

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧**
**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨-២០២០**

**គ្រូដឹកនាំបង្គោល ៖ លោក បណ្ឌិត នី រដ្ឋា**
**គ្រូដឹកនាំរង ៖ លោក លឹម វ៉ាន់**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមធ្វើការបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុងប្រាកដមែន។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជា បានសិក្សាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ.................................ខែ....................ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខាបេក្ខជន**

**ស៊ុន ផុន**

# លិខិតបញ្ជាក់

**លោក បណ្ឌិត នី រដ្ឋា ជាគ្រូដឹកនាំបង្គោល**

**លោក លឹម វ៉ាន់ ជាគ្រូដឹកនាំរង**

**សូមបញ្ជាក់ និងទទួលស្គាល់ថា** បេក្ខជន ឈ្មោះ **ស៊ុន ផុន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ**" ខាងលើប្រាកដមែន។

ថ្ងៃ..............................ខែ...............ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

| ..................................................... | ..................................................... |
|---|---|
| **លោក បណ្ឌិត នី រដ្ឋា** | **លោក លឹម វ៉ាន់** |
| ប្រធានការិយាល័យសិក្សា | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៣០៧ **អយក.ឧទ**
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារុំម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នួវ វិរៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី វេង្ហា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វុំប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូន ឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ភរិយាជាទីស្រឡាញ់ បងប្អូនរបស់ខ្ញុំ ដែលតែងតែផ្តល់កម្លាំងចិត្ត និងទំនុកបំរុងទាំងសម្ភារ និងថវិកាដល់រូបខ្ញុំដើម្បីមានលទ្ធភាពក្នុងការបន្តការសិក្សារហូតពេលនេះ។ ជាពិសេស មិត្តភក្តិសម្លាញ់ទាំងពីរនាក់( ជាង ចាន់ណាក់ និងហុង សុវណ្ណ) ដែលបានជួយក្នុងការផ្តល់មតិយោបល់ល្អ ពិភាក្សាក្នុងដំណាក់កាលនៃការសរសេរ។

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំយុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំ និងផ្តល់នូវអាហារូបករណ៍ ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំឱ្យបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ នាពេលកន្លងមក។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុតមកបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេសខ្ញុំសូមគោរព ថ្លែងអំណរគុណចំពោះ **លោកបណ្ឌិត នី រដ្ឋា** គ្រូដឹកនាំបង្គោល និងលោកសាស្ត្រាចារ្យ **លឹម ទ៉ាន់** ជាគ្រូដឹកនាំរងសរសេរនិក្ខេបបទ ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយពន្យល់ណែនាំ បង្ហាញផ្លូវ ផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធន៍ដល់រូបខ្ញុំ ដែលធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានជោគជ័យ និងបញ្ចប់ប្រកបដោយភាពរលូន។ ព្រមទាំងមិត្តរួមថ្នាក់ជំនាន់ទី៧ និងមិត្តរួមការងារដែលតែងតែផ្តល់នូវកម្លាំងចិត្តធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។ ខ្ញុំបាទសូមថ្លែងអំណរគុណមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ នៅតាមសាលាគោលដៅទាំងអស់ ដែលបានអនុញ្ញាត និងចូលរួមសហការធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ លោក លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ !

# មាតិកា


**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ........ i

**លិខិតបញ្ជាក់** ........ ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ iv

**មាតិកា** ........ v

**បញ្ជីតារាង** ........ viii

**បញ្ជីអក្សរកាត់** ........ x

**មូលន័យសង្ខេប** ........ xi

Abstract ........ xii

**ជំពូកទី១៖ សេចក្តីផ្តើម** ........ 1

**១. ១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........ 1

**១. ២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ 3

**១. ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ** ........ 4

**១. ៤. សំណួរស្រាវជ្រាវ** ........ 4

**១. ៥. សារៈសំខាន់នៃការស្រាវជ្រាវ** ........ 5

**១. ៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ** ........ 6

**១. ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ 7

**ជំពូកទី២៖ ការរំលឹកទ្រឹស្តី** ........ 9

**២. ១. និយមន័យកម្មវិធីសិក្សា** ........ 9

**២. ២. សារៈសំខាន់នៃកម្មវិធីសិក្សា** ........ 11

**២. ៣. ប្រសិទ្ធភាពនៃការប្រើប្រាស់ពេលវេលាបង្រៀន** ........ 11

២. ៣. ១. ការអនុវត្តម៉ោងបង្រៀន ........ 12

២. ៣. ២. ផលប៉ះពាល់នៃការអវត្តមានរបស់គ្រូ ........ 14

២. ៣. ៣. គុណភាពបង្រៀននៅក្នុងថ្នាក់រៀន ........ 16

**២. ៤. ស្តង់ដារសម្រាប់ការបង្រៀន** ........ 18

២. ៤. ១. គ្រូបង្រៀនជាអ្វី? ...18

២. ៤. ២. តួនាទីរបស់គ្រូបង្រៀន ...21

២. ៤. ៣. ការប្រើប្រាស់សម្ភារឧបទេសសម្រាប់ការបង្រៀន ...27

២. ៤. ៤. ការរៀបចំកិច្ចតែងការបង្រៀន ...28

២. ៤ .៥. លក្ខណៈសំខាន់ៗរបស់គ្រូបង្រៀន ...30

**២. ៥. សមត្ថភាពគរុកោសល្យក្នុងការបង្រៀន** ... 31

**២. ៦. ការបណ្តុះបណ្តាល និងការពង្រាយគ្រូ** ... 33

២. ៦. ១. ការបណ្តុះបណ្តាល ...33

២. ៦. ២. ការពង្រាយគ្រូ ...34

**២. ៧. ការកែលម្អគុណភាពអប់រំ** ... 36

**២. ៨. វិធីសាស្រ្តបង្រៀន** ... 39

២. ៨. ១. លក្ខណៈសំខាន់ៗក្នុងសកម្មភាពបង្រៀន ...40

២. ៨. ២. វិធីសាស្រ្តបង្រៀន ...41

២. ៨. ៣. វិធីសាស្រ្តចិត្តគរុកោសល្យជួយសិស្សក្នុងការរៀនសូត្រ ...44

**ជំពូកទី៣៖ វិធីសាស្រ្តស្រាវជ្រាវ** ...46

**៣. ១. គម្រោងវិភាគ** ... 46

**៣. ២. ការប្រមូលទិន្នន័យ** ... 46

**៣. ៣. ឧបករណ៍ស្រាវជ្រាវ** ... 47

៣. ៣. ១. កម្រិតចង្អុលបង្ហាញ ...49

៣. ៣. ២. កម្រងសំណួរ ...50

**៣. ៤. ការជ្រើសរើសភាគសំណាក** ... 52

**៣. ៥. ការវិភាគទិន្នន័យ** ... 53

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** ...54

**៤. ១. ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីព័ត៌មានប្រជាសាស្រ្តរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន** ... 54

៤. ១. ១. ព័ត៌មានប្រជាសាស្រ្តរបស់គណៈគ្រប់គ្រងសាលារៀន ...55

៤. ១. ២. ព័ត៌មានប្រជាសាស្រ្តរបស់ប្រធានក្រុមបច្ចេកទេស ...56

៤. ១. ៣. ព័ត៌មានប្រជាសាស្រ្តរបស់គ្រូបង្រៀន ...57

**៤. ២. ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីកម្រិតអនុវត្តនៃកម្មវិធីសិក្សា** ............... 59
៤. ២. ១. កម្រិតនៃការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់គណៈគ្រប់គ្រងសាលា ............................59
៤. ២. ២. លទ្ធផលស្រាវជ្រាវលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា ........................................................65
៤. ២. ៣. កម្រិតនៃការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់ប្រធានក្រុមបច្ចេកទេស............................66
៤. ២. ៤. លទ្ធផលស្រាវជ្រាវលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា ........................................................69
៤. ២. ៥. កម្រិតនៃការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់គ្រូបង្រៀន ..................................................70
៤. ២. ៦. លទ្ធផលស្រាវជ្រាវលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា ........................................................78
**៤. ៣. ការពិភាក្សាលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា**................................................................. 79
**៤. ៤. ការវិភាគទិន្នន័យលើសំណួរស្តីពីបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា**........... 83
៤. ៤. ១. បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈគណៈគ្រប់គ្រង ............................84
៤. ៤. ៣. បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈប្រធានក្រុមបច្ចេកទេស ..............89
៤. ៤. ៤. លទ្ធផលស្រាវជ្រាវលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា.....................................91
៤. ៤. ៥. បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈគ្រូបង្រៀន ...................................92
៤. ៤. ៦. លទ្ធផលស្រាវជ្រាវលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា.....................................94
**៤. ៥. ការពិភាក្សាលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា**............................ 95
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**..........................................................................98
**៥. ១. សេចក្តីសន្និដ្ឋាន**........................................................................................................ 98
**៥. ២. សំណូមពរ** .................................................................................................................. 101
**ឧបសម្ព័ន្ធ**......................................................................................................................108
ឧបសម្ព័ន្ធ (ក)៖ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា..........................................................109
ឧបសម្ព័ន្ធ (ខ)៖ កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស .......................................................115
ឧបសម្ព័ន្ធ (គ)៖ កម្រងសំណួរសម្រាប់គ្រូបង្រៀន...........................................................................119
ឧបសម្ព័ន្ធ (ឃ)៖ លិខិតចុះប្រមូលទិន្នន័យរបស់បេក្ខជន ..............................................................124
ឧបសម្ព័ន្ធ (ង)៖ គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........................................................126

# បញ្ជីតារាង


| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១ | តារាងទី១៖ ឈ្មោះខណ្ឌ និងឈ្មោះសាលា | ៤៨ |
| ២ | តារាងទី២៖ ភាគសំណាក និងទំហំសំណាក | ៥២ |
| ៣ | តារាងទី៣៖ ព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលារៀន | ៥៥ |
| ៤ | តារាងទី៤៖ ព័ត៌មានប្រជាសាស្ត្ររបស់ប្រធានក្រុមបច្ចេកទេស | ៥៦ |
| ៥ | តារាងទី៥៖ ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន | ៥៧ |
| **តារាងក្នុងផ្នែកសំណួរស្រាវជ្រាវទី១** | | |
| ៦ | តារាងទី៦(ក)៖ ការងារដឹកនាំ និងគ្រប់គ្រង | ៦០ |
| ៧ | តារាងទី៧(ខ)៖ ការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សា | ៦១ |
| ៨ | តារាងទី៨(គ)៖ ការងារបង្រៀន និងរៀន | ៦៣ |
| ៩ | តារាងទី៩(ឃ)៖ លទ្ធផលសិក្សារបស់សិស្ស | ៦៤ |
| ១០ | **តារាងទី៧៖ មធ្យមភាគសរុបរួមរបស់គណៈគ្រប់គ្រងសាលារៀន** | ៦៦ |
| ១១ | តារាងទី១១(ក)៖ ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេស | ៦៦ |
| ១២ | តារាងទី១២(ខ)៖ ការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ | ៦៨ |
| ១៣ | **តារាងទី១៣៖ មធ្យមភាគសរុបរួមរបស់ប្រធានក្រុមបច្ចេកទេស** | ៦៩ |
| ១៤ | តារាងទី១៤(ក)៖ ការអនុវត្តកម្មវិធីសិក្សា | ៧០ |
| ១៥ | តារាងទី១៥(ខ)៖ ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា | ៧២ |
| ១៦ | តារាងទី១៦(គ)៖ ដំណើរការបង្រៀន | ៧៤ |
| ១៧ | តារាងទី១៧(ឃ)៖ ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន | ៧៥ |

| | | |
|---|---|---|
| ១៨ | តារាងទី១៨(ង)៖ ទំនាក់ទំនងគ្រូ-សិស្ស | ៧៧ |
| ១៩ | **តារាងទី១៩៖ មធ្យមភាគសរុបរួមរបស់គ្រូបង្រៀន** | ៧៨ |
| **តារាងក្នុងផ្នែកសំណួរស្រាវជ្រាវទី២** | | |
| ២០ | តារាងទី២០(ក)៖ ដំណើរការបង្រៀន និងរៀន | ៨៤ |
| ២១ | តារាងទី២១(ខ)៖ ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន | ៨៦ |
| ២២ | តារាងទី២២(គ)៖ វិធីសាស្ត្របង្រៀន | ៨៧ |
| ២៣ | **តារាងទី២៣៖ មធ្យមភាគសរុបរួមរបស់គណៈគ្រប់គ្រងសាលារៀន** | ៨៨ |
| ២៤ | តារាងទី២៤(ក)៖ ការងារប្រតិបត្តិរបស់គ្រូបង្រៀន | ៨៩ |
| ២៥ | តារាងទី២៥(ខ)៖ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ | ៩០ |
| ២៦ | **តារាងទី២៦៖ មធ្យមភាគសរុបរួមរបស់ប្រធានក្រុមបច្ចេកទេស** | ៩២ |
| ២៧ | តារាងទី២៧(ក)៖ ការបាត់បង់ម៉ោងបង្រៀន | ៩៣ |
| ២៨ | តារាងទី២៨(ខ)៖ ការងប្រៀន និងរៀន | ៩៤ |
| ២៩ | **តារាងទី២៩៖ មធ្យមភាគសរុបរួមរបស់គ្រូបង្រៀន** | ៩៥ |

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ក្រសួងអ.យ.ក | : | ក្រសួងអប់រំ យុវជន និងកីឡា |
| CDRI | : | Cambodia Development Resources Institute |
| DPs | : | Development Partnerships |
| LS | : | Lesson Study |
| MoEYS | : | Ministry of Education Youth and Sport |
| NEP | : | NGO Education Partnership |
| OECD | : | Organisation for Economic Co-operation and Development |
| SEIP | : | Secondary Education Improvemnet Project |
| SBM | : | School Based Management |
| SLA | : | Student Learnng Achievement |

# មូលន័យសង្ខេប

ការអភិវឌ្ឍធនធានមនុស្សឱ្យសម្បូរបែប ជាកត្តាមួយដ៏សំខាន់ក្នុងវិស័យអប់រំ សម្រាប់បម្រើឱ្យការកសាង និងអភិវឌ្ឍប្រទេសជាតិ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ ១៥ ចំណុចនៅឆ្នាំ២០១៥ ឈរលើសសរស្តម្ភ ៥សំខាន់ៗ សំដៅលើកម្ពស់គុណភាពអប់រំក្នុងសតវត្សថ្មី ដើម្បីឆ្លើយតបនឹងតម្រូវកាចាំបាច់របស់ប្រទេសជាតិ និងការវិវឌ្ឍរបស់សកលលោក។ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា ជាសរសរស្តម្ភមួយនៃកំណែទម្រង់ ក្រសួងអប់រំ យុវជន និងកីឡា។ ដោយផ្អែកទៅលើយុទ្ធសាស្ត្រនៃកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ទើបលេចចេញនូវការសិក្សាស្រាវជ្រាវនេះឡើង។

ដើម្បីសិក្សាស្វែងយល់លើ "**ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា កម្រិតមធ្យមសិក្សាទុតិយភូមិ**" នៅរាជធានីភ្នំពេញ ឱ្យបានស៊ីជម្រៅ និងច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យក្នុងកាប្រមូលទិន្នន័យមកវិភាគ ដែលទទួលបានពីគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនសរុប ៥០នាក់ នៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ។ ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់កម្រងសំណួរ រៀបចំតាមលំដាប់លំដោយសម្រាប់នាយកសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដែលផ្តោតទៅលើតែមុខវិជ្ជា ប្រវត្តិវិទ្យា ត្រូវបានចូលរួមផ្តល់ព័ត៌មានទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជា ប្រវត្តិវិទ្យា និងបញ្ហាប្រឈមក្នុងការអនុវត្តនៅមធ្យមសិក្សាទុតិយភូមិ។

តាមការសិក្សាស្រាវជ្រាវ កម្រិតអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា នៅមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ មានដំណើរការល្អ ដោយមានការចូលរួមសហការ និងគាំទ្រពីគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានការរៀបចំផែនការងារបង្រៀន និងរៀននបានត្រឹមត្រូវ។ ក្នុងនោះផងដែរ ក៏នៅតែមានបញ្ហាមួយចំនួនក្នុងដំណើរការអនុវត្ត ដែលជាចំណុចខ្វះចន្លោះគួរតែធ្វើការកែលម្អបន្ថែមដូចជាការប្រើប្រាស់ម៉ោងបង្រៀន វិធីសាស្ត្រ សម្ភារឧបទេសបង្រៀន និងរៀន។ ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់សម្រាប់អ្នកអប់រំដែលពាក់ព័ន្ធទាំងអស់ ក្នុងការចូលរួមរកដំណើស្រាយលើបញ្ហាខ្វះចន្លោះ ដើម្បីពង្រឹងគុណភាពនៃការអប់រំឱ្យកាន់តែប្រសើរ ជាពិសេសការអនុវត្តកម្មវិធីសិក្សា ដែលជាចំណែកយ៉ាងសំខាន់មួយក្នុងការធានាបាននូវគុណភាព ប្រសិទ្ធភាពនៃការអប់រំនៅកម្ពុជា។

# Abstract

Human resource development is an important factor in education for nation building and development. In this regard, the Ministry of Education, Youth and Sports has made 15 reforms in 2015 based on five main pillars aimed at improving the quality of education in the new century to meet the needs of the nation and global development. Review of the curriculum, textbooks, and improving the learning environment is one of the pillars of the reform of the Ministry of Education, Youth and Sports. Based on the reform strategy of the Ministry of Education, Youth and Sports, this research has just emerged.

In order to study and understand the “Implementation of the High School History Curriculum ” in Phnom Penh in depth and clearly, the researchers used quantitative methods to collect and analyze data obtained from the school management, technical team leader and teachers of a total of 50 respondents in Phnom Penh. This study uses a sequential set of questionnaires for principals, technical team leaders, and teachers who focus only on history subjects to provide information related to the implementation of the history curriculum and the challenges of implementing it in high school.

According to the study, the implementation level of the history curriculum in the high school in Phnom Penh is working well, with the cooperation and support of the school management, the technical team leader and the teachers, the work plan, teaching and learning are correct. In addition, there are still some problems in the implementation process, which are gaps that should be improved, such as the use of teaching hours, teaching methods and teaching materials. This research is important for all relevant educators to participate in addressing the gaps to improve the quality of education, especially the implementation of the curriculum, which is an important part of ensuring quality and effectiveness of education in Cambodia.

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការធ្វើពិពិធកម្ម និងការធ្វើឱ្យស៊ីជម្រៅនៃមូលដ្ឋានធនធានមនុស្សរបស់ប្រទេស គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ប្រភពកំណើនសេដ្ឋកិច្ចថ្មីៗ និងប្រកបដោយចីរភាពក៏ដូចជាការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន។ ដើម្បីសម្រេចគោលដៅនេះរដ្ឋាភិបាលបានប្តេជ្ញាជំរុញវិស័យអប់រំរបស់ខ្លួនឱ្យរីកចម្រើន រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងណាមួយដើម្បីកែលម្អមូលដ្ឋានគ្រឹះនៃការអប់រំរបស់ប្រទេស ត្រូវតែចាប់ផ្តើមពីបាតក្រោមដោយផ្តល់នូវការអប់រំជាមូលដ្ឋានប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា។ ទោះបីជាមានការកែលម្អយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈម និងលំបាកមួយចំនួនក្នុងការបង្រួបបង្រួម និងទទួលបានជោគជ័យទាំងនេះឆ្ពោះទៅរកការទទួលបានការអប់រំជាមូលដ្ឋានប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែសម្រួលផែនការយុទ្ធសាស្ត្រអប់រំរបស់ខ្លួននាពេលថ្មីៗនេះ២០១៩/២០២៣(Bank, 2005)

ការអប់រំពិតជាបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិយ៉ាងពិតប្រាកដ រួមទាំងការកសាងធនធានមនុស្សដ៏សម្បូរបែប តាមរយៈវិធីសាស្ត្រក្នុងការបង្កើនចំណេះដឹង ជំនាញ និងសមត្ថភាពរបស់មនុស្សគ្រប់រូបនៅក្នុងសង្គម។ អាស្រ័យហេតុនេះហើយ ការអភិវឌ្ឍវិស័យអប់រំត្រូវបានចាត់ទុកជាអាទិភាពដ៏មានសារៈសំខាន់ក្នុងចំណោមវិស័យអាទិភាពដទៃទៀតដែលការអប់រំ គឺជាគុណធម៌ដ៏ចាំបាច់របស់មនុស្ស ជាភាពចាំបាច់របស់សង្គម ជាមូលដ្ឋានដ៏ល្អនៃជីវិត ជាសញ្ញាណនៃសេរីភាព និងជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មនៃភាពផ្សេងៗគ្នានៅក្នុងសង្គម(Bhardwaj, 2016)។ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាទិភាពលើវិស័យអប់រំ ក្នុងការអភិវឌ្ឍធនធានមនុស្ស និងកសាងសមត្ថភាពគ្រប់ផ្នែករបស់យុវជនកម្ពុជា ក្នុងការសម្រេចជោគជ័យគ្រប់វិជ្ជាជីវៈរបស់ប្រជាជន ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យមានលក្ខណៈសម្បូររុងរឿងដូចប្រទេសនានាក្នុងតំបន់ និងលើសកលលោកដោយផ្អែកលើចំណេះ និងចំណេះធ្វើជាមូលដ្ឋាន(ក្រសួង អ.យ.ក ២០១៩ក)។

គុណភាពអប់រំ គឺជាបញ្ហាដែលអ្នកអប់រំទាំងឡាយត្រូវយកចិត្តទុកដាក់ និងចូលរួមដោះស្រាយទាំងអស់គ្នានៅក្នុងសង្គម ជាពិសេសអ្នកសិក្សាអប់រំគ្រប់លំដាប់ថ្នាក់។ គុណភាពអប់រំ ជាឆ្អឹងខ្នងនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ របស់ប្រទេសជាច្រើននៅជុំវិញពិភពលោក ហើយធនធានសាធារណៈជាច្រើនត្រូវបានគេយកចិត្តទុកដាក់ដើម្បីសម្រេចបាននូវគោលដៅនេះ(Miningou, 2019)។ ដើម្បីបង្កើនសមត្ថភាពរបស់មនុស្ស រាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍នានាត្រូវចំណាយពេលវេលាវែងឆ្ងាយ ក្នុងការពង្រឹងគុណភាពអប់រំប្រកបដោយចីរភាព ដូចនេះអ្នករៀបចំគោលនយោបាយអប់រំ មន្ត្រីអប់រំគ្រប់រូប អ្នកពាក់ព័ន្ធគ្រប់ផ្នែកត្រូវចូលរួមនៅក្នុងការអនុវត្តច្បាប់អប់រំ គោលនយោបាយអប់រំ ផែនការអប់រំ និងកម្មវិធីសិក្សាជាតិឱ្យបានត្រឹមត្រូវតាមនីតិវិធី។ ក្នុងន័យនេះ ត្រូវផ្តោតការយកចិត្តទុកដាក់គោរពតាមគោលការណ៍ច្បាប់ មានលក្ខណៈប្រជាធិបតេយ្យ និងលក្ខណៈវិទ្យាសាស្ត្រ រួមទាំងស្របទៅនឹងបទដ្ឋាន ស្ថានភាពនាពេលបច្ចុប្បន្ន និងអនាគត ដែលប្រទេសជាតិ និងសកលលោកត្រូវការ។ ដើម្បីឱ្យការអនុវត្ត និងប្រតិបត្តិប្រកបដោយតម្លាភាព និងចីរភាព គោលការណ៍ច្បាប់ទាំងនោះ ចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់មជ្ឈដ្ឋានទាំងអស់(Hoy, Bayne-Jardine, & Wood, 1999)។

ចំណុចសំខាន់មួយទៀត គឺគុណភាពអប់រំ បានទទួលរងឥទ្ធិពលពីកត្តាជាច្រើនដូចជាសង្គមសេដ្ឋកិច្ច គោលនយោបាយអប់រំ ហេដ្ឋារចនាសម្ព័ន្ធអប់រំអគារ បន្ទប់សិក្សា សិស្សផលធៀបសិស្ស-ថ្នាក់ ផលធៀបគ្រូ-សិស្ស សុខភាពអនាម័យ សុខសុវត្ថិភាព សមត្ថភាពគ្រូ វិធីសាស្ត្ររបស់គ្រូបង្រៀន ភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន ជាពិសេសកម្មវិធីសិក្សាដែលរួមបញ្ចូលទាំងឯកសារពាក់ព័ន្ធនឹងក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស សៀវភៅសិក្សា ឯកសារជំនួយ សម្ភារឧបទេស មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងសៀវភៅណែនាំអំពីការវាយតម្លៃសមត្ថភាពសិស្ស(ក្រសួង អ.យ.ក ២០១៥ក)។ ដូច្នេះការផ្សារភ្ជាប់ទំនាក់ទំនងជាមួយការអនុវត្តកម្មវិធីសិក្សា គឺសំដៅទៅលើអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុងការអនុវត្តជាក់ស្តែង ដោយប្រៀបធៀបទៅនឹងអ្វីដែលបានកើឡើងពីមុន។ ការអនុវត្តកម្មវិធីសិក្សា រួមទាំងការជួយដល់បុគ្គលិក ដើម្បីធានាបានថា កម្មវិធីសិក្សាថ្មីដែលបានរៀបចំឡើង និងយុទ្ធសាស្ត្រណែនាំប្រកបទៅដោយឥទ្ធិពល និងប្រសិទ្ធភាពបានយកទៅអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់

រៀន (Chapman & Adams, 2002 ; Olayide, 2015)។ ទោះជាយ៉ាងណាក៏ដោយ វិធានការដ៏មានប្រសិទ្ធភាព និងចំណាយនូវធនធានថវិកាតិចបំផុត ពោលគឺមានលក្ខណៈសន្សំសំចៃត្រូវបានប្រើប្រាស់ដើម្បីលើកស្ទួយគុណភាព និងប្រសិទ្ធភាពអប់រំនៅតាមសាលារៀន គឺត្រូវធ្វើយ៉ាងណាឱ្យគ្រូបង្រៀនទាំងអស់ទទួលបាននូវសមត្ថភាព បទពិសោធន៍ក្នុងការផ្ទេរចំណេះដឹង និងចេះប្រើប្រាស់កម្មវិធីសិក្សាដែលរៀបចំថ្មី សៀវភៅសិក្សាគោល គោលការណ៍ណែនាំ និងផែនការសកម្មភាពទាក់ទងទៅនឹងពេលវេលាបង្រៀន ការផលិត និងប្រើប្រាស់សម្ភារឧបទេស ការគាំទ្រពីនាយកសាលា និងស្ថាប័នពាក់ព័ន្ធដទៃទៀតផ្តោតលើការបង្រៀនរបស់គ្រូ( Fairhurst et al., 1999 )។

កត្តាសំខាន់ដែលជួយលើកកម្ពស់ដល់ការរៀនសូត្ររបស់សិស្សនៅក្នុងសតវត្សទី២១ និងក្នុងយុគសម័យនៃការអភិវឌ្ឍឧស្សាហកម្ម ៤.០ រួមមានគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងការបំពេញតួនាទីរបស់សាលារៀន ក្នុងការជួយឱ្យសិស្ស សិក្សារៀនសូត្រប្រកបដោយប្រសិទ្ធភាព( ក្រសួង អ.យ.ក ២០១៩ក )។ ប្រការនេះ ទាមទារឱ្យគ្រូបង្រៀន និងនាយកសាលា ត្រូវអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីមានសមត្ថភាពធ្វើឱ្យការរៀនសូត្រក្នុងសាលារៀនអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាព( Olayide, 2015 )។

## ១. ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការអភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សានៅប្រទេសកម្ពុជាឆ្លងកាត់ចំនួន៤ដំណាក់កាល ចាប់តាំងពីឆ្នាំ ១៩៧៩ រហូតមកដល់ពេលបច្ចុប្បន្ន(Hang-Chuon, 2018)។ នៅឆ្នាំ២១០៥ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អទៅលើកម្មវិធីសិក្សាបច្ចុប្បន្ន ដោយវិភាគទៅលើសៀវភៅសិក្សាគោលបានបង្ហាញថា កម្មវិធីសិក្សា មិនបានផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស និងមិនបានផ្តល់ឱ្យសិស្សនូវសមត្ថភាពគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងបន្តការសិក្សារបស់ពួកគេទៅថ្នាក់ឧត្តមសិក្សាក្នុងស្ថានភាពបច្ចុប្បន្ន។ ការធ្វើកំណែទម្រង់កម្មវិធីសិក្សាសំដៅទៅដល់ការប្រើប្រាស់ ឯកសារកម្មវិធីសិក្សារបស់គ្រូបង្រៀន សាលរៀនឱ្យបានល្អប្រសើរ ដូចជាគោលនយោបាយ ស្តីពី ការអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតសាលារៀន ត្រូវផ្តោតការយកចិត្តទុកដាក់ដល់លទ្ធផលសិក្សារបស់សិស្ស ឯគ្រូបង្រៀនត្រូវមានសមត្ថភាព

ស្រាវជ្រាវទាំងជំនាញឯកទេស(មុខវិជ្ជាបង្រៀន) និងកែលម្អវិធីសាស្ត្រ និងដំណើរការបង្រៀនឱ្យកាន់តែប្រសើរ(Hang-Chuon, 2018)។

ក្នុងការអនុវត្តនៅកម្មវិធីសិក្សានាពេលបច្ចុប្បន្ន ទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនបន្ថែមទៀតទៅលើកម្មវិធីសិក្សា ជំនាញឯកទេស វិធីសាស្ត្របង្រៀន ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការប្រើប្រាស់សម្ភារឧបទេសជំនួយការបង្រៀន(Hang-Chuon, 2018)។ ទាំងអស់នេះវាជាសមាសធាតុចាំបាច់ដែលគ្រូបង្រៀនម្នាក់ៗត្រូវតែមាន ដើម្បីបំពេញតម្រូវការឱ្យសិស្ស ដើម្បីឆ្លើយតបទៅនឹងបរិបទនាពេលបច្ចុប្បន្ន។ តាមរយៈចំណុចបង្ហាញខាងលើ អាចវាយតម្លៃបានថា បញ្ហានេះគឺបណ្តាលមកពីការអនុវត្តកម្មវិធីសិក្សាមិនបានចប់ចុងចប់ដើមឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ ក្រសួងអប់រំ យុវជន និងកីឡា ដោយបូកបញ្ចូលទាំងការខ្វះចន្លោះលើការប្រើប្រាស់ឯកសារកម្មវិធីសិក្សា ការប្រើប្រាស់ម៉ោងបង្រៀនរបស់គ្រូម្នាក់ៗ ក្នុងមួយសប្តាហ៍ ចំនួនម៉ោងបង្រៀនសរុបសម្រាប់មេរៀននីមួយៗក្នុងមួយខែ និងក្នុងមួយឆ្នាំសិក្សា(MoEYS, 1999)។

## ១.៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងសំខាន់ពីរដូចខាងក្រោម៖

(១) រកឱ្យឃើញពីកម្រិតអនុវត្តកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជា ប្រវត្តិវិទ្យាតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

(២) រកឱ្យឃើញបញ្ហាប្រឈមនានារបស់លោកគ្រូ អ្នកគ្រូ និងភាគីពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនមុខវិជ្ជាបង្រៀនប្រវត្តិវិទ្យា។

## ១.៤. សំណួរស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវ គឺដើម្បីស្វែងយល់ពីការអនុវត្តកម្មវិធីសិក្សាឱ្យបានទូលំទូលាយនៅកម្រិតសាលារៀន និងស្វែងរកចម្លើយចំពោះសំណួរខាងក្រោម៖

(១) តើលោកគ្រូ-អ្នកគ្រូបានអនុវត្តកម្មវិធីសិក្សាលើមុខវិជ្ជា ប្រវត្តិវិទ្យា ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ បានកម្រិតណា?

(២) តើលោកគ្រូ-អ្នកគ្រូបានជួបនូវបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តកម្មវិធីសិក្សា លើមុខវិជ្ជាបង្រៀនប្រវត្តិវិទ្យា តាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ សម្រាប់អ្នកជំនាញវិស័យអប់រំ អ្នករៀបចំគោលនយោបាយអប់រំ និងអ្នកពាក់ព័ន្ធនានា ជាពិសេសគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនដែលជាអ្នកប្រតិបត្តិ និងចូលរួមដោះស្រាយរាល់បញ្ហាកើតមានឡើងក្នុងការអនុវត្តកម្មវិធីសិក្សាដោយផ្ទាល់។ ថ្នាក់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ការិយាល័យមធ្យមសិក្សាចំណេះទូទៅគ្រាន់យកជាទស្សនទាន ពោលគឺអាចយល់ច្បាស់ពីប្រកតពនៃបញ្ហាក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា និងចូលរួមជួយដោះស្រាយចំពោះបញ្ហាប្រឈមដែលកើតមានក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា នៅតាមសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិ និងផ្តល់ជាអនុសាសន៍ គំនិតយោបល់ដោយប្រយោល។ លោកគ្រូ អ្នកគ្រូអាចយកលំនាំនៃការសិក្សាស្រាវជ្រាវនេះ ទៅអនុវត្តក្នុងការបង្រៀនក្នុងថ្នាក់រៀនរបស់លោកគ្រូ អ្នកគ្រូ ព្រមទាំងទទួលយកនូវមេរៀនបទពិសោធន៍ល្អៗសម្រាប់កាបង្រៀន ការផ្ទេរចំនេះដឹង និងដឹកនាំការរៀនសូត្ររបស់សិស្សប្រកបដោយគុណភាណ និងប្រសិទ្ធភាពខ្ពស់ ដែលអាចឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់វិស័យអប់រំ លើការអនុវត្តកម្មវិធីសិក្សាបច្ចុប្បន្ន និងកម្មវិធីសិក្សាថ្មីដែលបានអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

បន្ថែមពីនេះទៀត ការសិក្សាស្រាវជ្រាវនេះក៏រួមចំណែករកឃើញនូវលទ្ធផលសំខាន់ៗពីភាពលម្អិតនៃព័ត៌មានជាក់លាក់ពិតប្រាកដ ដែលបានកើតឡើងនៅតាមវិទ្យាល័យនានា(មធ្យមសិក្សាទុតិយភូមិ) គន្លឹះដែលរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ នឹងជួយគណៈគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន រួមទាំងលោកគ្រូ អ្នកគ្រូធ្វើការឆ្លុះបញ្ចាំង និងវាយតម្លៃនូវដំណើរការអនុវត្តកម្មវិធីសិក្សា

នៅមធ្យមសិក្សាទុតិយភូមិ ថាតើការដែលប្រតិបត្តិមិនបានល្អ មិនទទួលបានជោគជ័យដូចការគ្រោងទុកក្នុងបំណែងចែកកម្មវិធីសិក្សាបណ្តាលមកពីកត្តាអ្វីខ្លះ។ បន្ថែមទៅលើបញ្ហានេះ ការសិក្សាក៏បានសង្កត់ធ្ងន់លើស្ថានភាពជាក់ស្តែងនៅតាមសាលារៀននីមួយៗក្នុងការប្រើប្រាស់នីតិវិធីផ្តល់ចំណេះដឹង ការងារសម្របសម្រួលការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ទៅឱ្យអ្នកពាក់ព័ន្ធអប់រំទាំងអស់នូវព័ត៌មានច្បាស់លាស់មួយអំពីការអនុវត្តកម្មវិធីសិក្សាដែលបានកំណត់ ថាតើអនុវត្តន៍បាន ឬមិនបានតាមគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ក្របខណ្ឌកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាលម្អិតសិក្សាសង្គម និងឯកសារណែនាំផ្សេងៗទៀតដែលដាក់ឱ្យអនុវត្តដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា។ ស្របពេលជាមួយគ្នានេះដែរ ការសិក្សាស្រាវជ្រាវក៏បានចង្អុលបង្ហាញអំពីការប្រើប្រាស់សៀវភៅសិក្សាគោល សម្ភារឧបទេសឯកសារជំនួយផ្សេងៗ វិធីសាស្ត្របង្រៀនថ្មីៗ ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីគាំទ្រដល់ដំណើរការបង្រៀន ការផ្ទេរចំណេះដឹង និងសម្របសម្រួលការសិក្សារបស់សិស្សប្រកបដោយភាពជឿជាក់ ជាពិសេសស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលបានកំពុងដាក់ឱ្យអនុវត្ត។

## ១. ៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើង នៅក្នុងសាលារៀនមធ្យមសិក្សាទុតិយភូមិចំនួន ១០ ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ ហើយផ្តោតតែទៅលើមុខវិជ្ជា ប្រវត្តិវិទ្យា។ ការសិក្សានេះមិនអាចធ្វើឡើងនៅគ្រប់សាលាមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេសបានឡើយ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវធ្វើឡើងក្នុងកម្រិតមួយជាក់លាក់ ហេតុនេះហើយ យើងត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតលើគ្រប់ផ្នែកទាំងអស់។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ក៏មិនអាចប្រើប្រាស់សម្រាប់សិក្សាជាទូទៅលើការអនុវត្តកម្មវិធីសិក្សាទាំងមូលនៅក្នុងប្រទេសកម្ពុជាបានទេ ពីព្រោះការសិក្សានេះគ្រាន់តែផ្តោតគំរូតាងដ៏តូចមួយដែលបានមកពីគ្រឹះស្ថានសិក្សាទាំង ១០ ប៉ុណ្ណោះ។ ទោះបីជាការសិក្សាស្រាវជ្រាវនេះមានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីត្រួតពិនិត្យព័ត៌មានមិនពិតក៏ដោយ ទាំងអស់នេះមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ស្វែងរកហេតុ និងផលបានឡើយ។ ការសិក្សាស្រាវជ្រាវនៅពេលនេះ វាគ្រាន់តែបានផ្តល់នូវបន្ទាត់ដែលជាផ្លូវយ៉ាង

សំខាន់មួយ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវបន្ត ស្តីពីតួនាទីគ្រូបង្រៀន ភារកិច្ចគ្រូបង្រៀន ពិសេសសំដៅលើការអនុវត្តកម្មវិធីសិក្សាតែម្តង។

នៅក្នុងការសិក្សាស្រាជ្រាវនេះ អ្នកស្រាវជ្រាវបានជ្រើសរើសយកសំណាកដែលពាក់ព័ន្ធ គឺមានដូចជាលោកនាយក លោកស្រីនាយិកាសាលារៀន លោកគ្រូ អ្នកគ្រូជាប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាថ្នាក់ទី១០ ទី១១ និងទី១២ នៅសាលមធ្យមសិក្សាទុតិយភូមិទាំង ១០ ក្នុងឆ្នាំសិក្សា២០១៩-២០២០ សម្រាប់ធ្វើការស្រាវជ្រាវ និងការវិភាគ។ ការវិភាគនេះ អ្នកស្រាវជ្រាវមិនបានធ្វើការបែងចែករវាងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមឡើយ។

ការសិក្សាស្រាវជ្រាវប្រធានបទស្តីពី"ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ" ដោយសារតែចំពេលដែលស្ថានភាពនៃការរីករាលដាលជំងឺ Covid-19 បានធ្វើឱ្យរាំងស្ទះគ្រប់វិស័យសំខាន់ៗក្នុងការអភិវឌ្ឍប្រទេសជាតិ រួមទាំងវិស័យអប់រំផងដែរ។ ប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសជាច្រើននៅលើពិភពលោក គ្រឹះស្ថានសិក្សាទាំងសាធារណៈ និងឯកជនត្រូវបានបិទ ហេតុដូចនេះហើយការសិក្សាស្រាវជ្រាវ មិនបានធ្វើឡើងឱ្យមានភាពទូលំទូលាយដូចដូចការរំពឹងទុក ដាក់សស្តែងការជ្រើសរើសសាលារៀនគោលដៅ ទំហំភាគសំណាកក្នុងការសិក្សាស្រាវជ្រាវជាដើម។

## ១. ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូកទី១៖ សេចក្តីផ្តើម** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីសាវតា ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ និយមន័យពាក្យគន្លឹះ វិធីប្រមូល និងការវិភាគទិន្នន័យ និងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ"។

**ជំពូកទី២៖ ការរំលឹកទ្រឹស្តី** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីចាស់ៗ ពាក់ព័ន្ធនឹងប្រធានបទ ពីអ្នកសិក្សាស្រាវជ្រាវមុនៗតាមរយៈសៀវភៅ កម្រងអត្ថបទស្រាវជ្រាវជាតិ និង អន្តរជាតិ រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្ត សេចក្តីប្រកាស សារាចរណ៍ណែនាំ និងឯកសារពាក់ព័ន្ធនានា របស់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាគំនិត និងជាទុនសម្រាប់ ស្រាវជ្រាវ និងបង្កើតជាស្នាដៃថ្មី។

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសសំណាក និងប្រភេទសំណាក ព្រមទាំង វិធីសាស្ត្រក្នុងការវិភាគទិន្នន័យរកតម្លៃមធ្យម និងភាគរយតាមរយៈកម្មវិធី SPSS និងកម្មវិធី MS. EXCEL សម្រាប់សង់ក្រាហ្វិក និងផ្គុំទិន្នន័យបញ្ចូលគ្នា។

**ជំពូកទី៤៖ លទ្ធផលនិងការពិភាក្សា** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែល ប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឱ្យបានយ៉ាងក្បោះក្បាយដើម្បីរកឱ្យឃើញនូវចំណុចល្អ ចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្តែងនៃការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា នៅកម្រិត មធ្យមសិក្សា ករណីសិក្សា រាជធានីភ្នំពេញ និងតម្រូវការសម្រាប់នាយក គ្រូបង្រៀន និងសិស្សដែលបម្រើ ឱ្យការបង្រៀន មុខវិជ្ជា ប្រវត្តិវិទ្យាឱ្យទទួលបានលទ្ធផលល្អប្រសើរ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់សំណូមពរ** ជាផ្នែកមួយដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើ ការសន្និដ្ឋានលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនដល់ក្រសួងអប់រំ មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលា គ្រូបង្រៀនប្រវត្តិវិទ្យា អ្នកសិក្សាស្រាវជ្រាវ ក្រោយៗ និងភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ និងធ្វើឱ្យស្ថានភាពនៃការបង្រៀន និង រៀនប្រវត្តិវិទ្យារបស់សិស្ស និងគ្រូបង្រៀនប្រវត្តិវិទ្យា ឱ្យកាន់តែមានភាពល្អប្រសើរឡើង។

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

ដើម្បីសម្រេចបាននូវលទ្ធផលអប់រំដែលបានកំណត់ទុក ការផ្លាស់ប្តូរនៅក្នុងសាលារៀន ពិសេសគឺការអនុវត្តកម្មវិធីសិក្សា ដែលមានមហិច្ឆិតាធ្វើឱ្យសម្រេចនូវលទ្ធផលសិក្សាក្នុងមុខវិជ្ជាស្នូល និងដើម្បីបំពេញឱ្យបានយ៉ាងល្អបំផុតនូវកម្មវិធីវាយតម្លៃលទ្ធផលសិក្សា។ ភាពស៊ីគ្នានៃខ្លឹមសារកម្មវិធីសិក្សា និងបទដ្ឋានលទ្ធផលសិក្សា តាមរយៈការអនុវត្តកម្មវិធីសិក្សា ជាមួយនឹងការរៀបចំនីតិវិធីវាយតម្លៃដែលមានគោលបំណង ផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាពត្រឹមត្រូវ ទើបជានាបាននូវប្រសិទ្ធភាព ប្រសិទ្ធផលនៃការសិក្សារបស់សិស្ស មិនអាចកាត់ផ្តាច់បានពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀន។ ដើម្បីពង្រីកវិសាលភាពការអនុវត្តកម្មវិធីសិក្សា ឱ្យទទួលបានគុណភាពខ្ពស់ កត្តាចំបាច់កម្មវិធីសិក្សាត្រូវតែបានប្រើប្រាស់យ៉ាងទូលំទូលាយដោយគ្រូបង្រៀន(Kelly, 2004)។

## ២. ១. និយមន័យកម្មវិធីសិក្សា

កម្មវិធីសិក្សា៖ សំដៅដល់សំណុំមុខវិជ្ជាដែលត្រូវបានរៀបចំឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិត(ក្រសួង អ.យ.ក ២០០៧)។

យោងទៅតាមលោក Morris (1996) បានឱ្យនិយមន័យទៅលើកម្មវិធីសិក្សា ត្រូវចែកចេញជាប្រាំមួយចំណុចផ្សេងៗគ្នាដូចតទៅ៖

- កម្មវិធីសិក្សា៖ គឺជាច្បាប់សិក្សាអប់រំ លើមុខវិជ្ជាជាច្រើន ដូចជាវេយ្យាករណ៍ តក្កវិជ្ជារួមទាំងការអាន។
- កម្មវិធីសិក្សា៖ គឺជាកាប្រមូលផ្តុំនូវចំណេះវិជ្ជាទាំងឡាយដែលកើតចេញមកពីច្បាប់ទំលាប់ និងការគោរព។
- កម្មវិធីសិក្សា៖ គឺជាផែនការសិក្សាដែលមានលទ្ធផលជាក់លាក់។
- កម្មវិធីសិក្សា៖ គឺជាមេរៀនពិសោធន៍របស់អ្នកសិក្សា ដែលស្ថិតក្រោមកាណែនាំគ្រប់គ្រងរបស់សាលា។
- កម្មវិធីសិក្សា៖ គឺជាសំណុំមុខវិជ្ជាដែលមានសារៈប្រយោជន៍ដល់ជីវិតរស់នៅក្នុងសង្គម។
- កម្មវិធីសិក្សា៖ គឺជាការផ្ទេរឱ្យគ្នាទៅវិញទៅមករវាងគ្រូ ហើយនិងសិស្ស។

បើយោងតាមលោក Marsh (2004) កម្មវិធីសិក្សាត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើនទៅតាមអ្នកនិពន្ធ(Toombs and Tierney, 1993)៖

- កម្មវិធីសិក្សា៖ គឺជាមុខវិជ្ជាទាំងឡាយដែលមានប្រយោជន៍បំផុត សម្រាប់ការរស់នៅក្នុងសង្គមសម័យបច្ចុប្បន្ន។ មុខវិជ្ជាដែលបង្កើតជាកម្មវិធីសិក្សា ច្រើនតែត្រូវបានគេជ្រើសរើសទាក់ទងនឹងបញ្ហាធំៗ និងបញ្ហាបច្ចុប្បន្ននៅក្នុងសង្គម។
- កម្មវិធីសិក្សា៖ គឺជាការសិក្សាដែលបានគ្រោងទុក ដែលសាលារៀនជាអ្នកទទួលខុសត្រូវ។ ការសិក្សាដែលបានគ្រោងទុក អាចជាឯកសារសរសេរវែង ដែលបញ្ជាក់ពីមាតិកា បញ្ជីខ្លីនៃលទ្ធផលសិក្សាដែលមានគោលបំណង ឬគំនិតទូទៅរបស់គ្រូអំពីអ្វីដែលសិស្សគួរដឹង។

បើយោងតាម Ornstein and Hunkins (2018) កម្មវិធីសិក្សា ត្រូវបានគេកំណត់និយមន័យជាមូលដ្ឋានផ្សេងៗគ្នាមួយចំនួន៖

- កម្មវិធីសិក្សា៖ គឺជាផែនការដើម្បីសម្រេចគោលដៅ។
- កម្មវិធីសិក្សា៖ គឺជាផែនការសម្រាប់ផ្តល់នូវឱកាសរៀនសូត្រសម្រាប់មនុស្សដែលត្រូវទទួលបានការអប់រំ(J. Galen Saylor, William Alexander, and Arthur Lewis)។
- កម្មវិធីសិក្សា៖ គឺជាដំណើរការនៃការអភិវឌ្ឍ ដែលមានការកំណត់ពីទស្សនវិជ្ជា ការវាយតម្លៃសមត្ថភាពសិស្ស ការពិចារណាពីវិធីសាស្ត្រសម្រាប់ធ្វើការណែនាំ យុទ្ធសាស្ត្រសម្រាប់អនុវត្តជ្រើសរើសឧបការណ៍សម្រាប់វាយតម្លៃ និងកែលម្អជាបន្តបន្ទាប់(David Pratt Jon Wiles and Joseph Bondi)។
- កម្មវិធីសិក្សា៖ គឺជាបទពិសោធន៍ទាំងអស់ដែលកុមារមាន ក្រោមការណែនាំរបស់គ្រូបង្រៀន (Hollis Caswell and Doak Campbell)។

កម្មវិធីសិក្សានៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺសំដៅលើមេរៀននីមួយៗនៃមុខវិជ្ជាប្រវត្តិវិទ្យាដែលបង្រៀននៅមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១០ ទី១១ និងទី១២)។

## ២. ២. សារៈសំខាន់នៃកម្មវិធីសិក្សា

កំណែទម្រង់ស៊ីជម្រៅនៅក្នុងវិស័យអប់រំ ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជសសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ជាកត្តាកំណត់ជោគជ័យនៃការអភិវឌ្ឍលើវិស័យនានាទាំងអស់(ក្រសួង អ.យ.ក ២០១៥ក)។ ឯកសារគោលនយោបាយ ស្តីពី ការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៦ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ ២០១៥ ត្រូវបានរៀបចំឡើងដើម្បីអប់រំពលរដ្ឋកម្ពុជាឱ្យក្លាយជាពលរដ្ឋពេញលេញ តាមរយៈការធ្វើឱ្យកម្មវិធីសិក្សាកាន់មានលក្ខណៈស្តង់ដាអន្តរជាតិទាំងខ្លឹមសារ វិធីសាស្ត្របង្រៀន និងរៀន ព្រមទាំងវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងគោលបំណងធ្វើឱ្យសមត្ថភាពរបស់សិស្សឆ្លើយតបនឹងតម្រូវការទីផ្សារការងារនៅកម្រិតជាតិ តំបន់ និងពិភពលោក។ ការធ្វើកំណែទម្រង់កម្មវិធីសិក្សាជាបន្តបន្ទាប់ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយធ្វើការពង្រីកវិសាលភាពនៃចំណេះដឹង បំណិន ការអប់រំសីលធម៌ ការទំនាក់ទំនង គំនិតច្នៃប្រឌិត ការបង្កើតថ្មី ស្មារតីសហគ្រិនភាព និងផ្តល់នូវចំនេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យសិស្សក្លាយជាបុគ្គលដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ និងប្រទេសជាតិ។

## ២. ៣. ប្រសិទ្ធភាពនៃការប្រើប្រាស់ពេលវេលាបង្រៀន

ប្រទេសកម្ពុជាបានកំណត់គោលដៅសម្រាប់ការអប់រំទាំងអស់គ្នា(EFA)នៅឆ្នាំ២០១៥ គឺធានាឱ្យកុមារកម្ពុជាយ៉ាងហោចណាស់ក៏ទទួលបានការអប់រំកម្រិតមូលដ្ឋាន៩ឆ្នាំ។ ជាងនេះទៅទៀត ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យទៅជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន(ក្រសួង អ.យ.ក ២០១៩ខ)។ តាមរយៈចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តវិធានការកំណែទម្រង់ទាំង ៨ ចំណុចប្រកបដោយជោគជ័យនៅឆ្នាំ២០១៤ រួមមាន (១)ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ (២) ពង្រឹងការគ្រប់គ្រងបុគ្គលិក (៣) ពង្រឹងការប្រឡងគ្រប់ប្រភេទ (៤) កំណែទម្រង់ឧត្តមសិក្សា (៥) ការអភិវឌ្ឍសម្រាប់យុវជននូវជំនាញទន់ និង

បច្ចេកទេស (៦) អនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៧) ការបង្កើតធនាគារខួរក្បាលវិស័យអប់រំ និង(៨) កំណែទម្រង់អប់រំកាយ និងកីឡា និងបានបន្តយុទ្ធសាស្ត្រកំណែទម្រង់នៅឆ្នាំ២០១៥ ដែលមានចំនួន ១៥ ចំណុច ឈរលើសសរស្តម្ភចំនួន៥(ក្រសួង អ.យ.ក ២០១៩ខ)។ ក្នុងចំណោមសសរស្តម្ភទាំង៥ចំណុច នៃយុទ្ធសាស្ត្រកំណែទម្រង់ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល គឺជាចំណុចសំខាន់មួយដើម្បីធានាបាននូវគុណភាពនៃការអប់រំ ។ ការសិក្សានៅក្នុងផ្នែកនេះសំដៅទៅលើគុណភាពនៃការអប់រំ ហើយគុណភាពនោះ វាកើតចេញពីការបង្រៀននៅក្នុងថ្នាក់រៀនរបស់សិស្ស និងគ្រូប្រកបដោយប្រសិទ្ធភាព។ គុណភាពនៃការអប់រំ គឺជាអ្វីដែលកើតឡើងពីការបង្រៀនមានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀន គ្រូបង្រៀនជួយសិស្សរាល់គ្នាឱ្យដឹង ឬស្គាល់ពីគោលបំណងរបស់ខ្លួន ស្វ័យភាពក្នុងការគិតពិចារណា មានគំនិតចាស់ទុំ សមត្ថភាពគិតបានស៊ីជម្រៅ មានការខិតខំប្រឹងប្រែង និងដឹងពីតម្លៃនៃការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ គឺជាគោលបំណងសំខាន់បំផុតនៃការអប់រំ ដែលវាជាទិដ្ឋភាពនៃគុណភាពអប់រំ(Reimers, 2020)។

យោងទៅតាមការសិក្សារបស់ Abadzi (2006) បានបង្ហាញថា ចំនួនម៉ោងដែលសិស្សបានចំណាយក្នុងការរៀនសូត្រ គឺមានភាពទាក់ទងគ្នាទៅនឹងលទ្ធផលសិក្សារបស់សិស្ស។ ទោះជាយ៉ាងណាក៏ដោយ សាលារៀនបានបង្រៀនសិស្សត្រឹមតែពេលវេលាដែលរដ្ឋ ឬក្រសួងអប់រំកំណត់ឱ្យ ហើយសាលារៀនដែលនៅស្ថិតនៅតំបន់ជនបទ បង្រៀនមិនបានគ្រប់ម៉ោងកំណត់ទៀតផង។ លើសពីនេះទៅទៀត សាលារៀនខ្លះបានបិទក្រៅផ្លូវការមុនពេល ឬក្រោយថ្ងៃឈប់សម្រាក។ គ្រូបង្រៀន នៅក្នុងម៉ោងបង្រៀនបានដឹកនាំសិស្សធ្វើសកម្មភាពផ្សេងពីការបង្រៀន ជាលទ្ធផលនៃសកម្មភាពទាំងនោះ បានធ្វើឱ្យសិស្សមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអាន ខ្វះការគាំទ្រពីឪពុកម្តាយ សិស្សដែលក្រីក្រមានទំនោរទៅរកការបោះបង់ការសិក្សា រៀនត្រួតថ្នាក់ ឬក៏បោះបង់ទាំងមិនចេះអក្សរ។

### ២. ៣. ១. ការអនុវត្តម៉ោងបង្រៀន

នៅក្នុងការអប់រំ ជាទូទៅតែងតែមិនមានភាពស្របគ្នារវាងគោលបំណង និងការអនុវត្តឱ្យសម្រេចបានទៅតាមកម្មវិធីទាំងស្រុងគ្រប់ស្ថានភាពនោះទេ(Hoy et al., 1999)។ គោលបំណងនៃកម្មវិធី តែងត្រូវ

បានរៀបចំឡើងដោយអ្នករៀបចំគោលនយោបាយ ការអនុវត្តកម្មវិធី ត្រូវអនុវត្តដោយលោកគ្រូ-អ្នកគ្រូនៅក្នុងថ្នាក់រៀនរបស់ពួកគាត់ ហើយការសម្រេចកម្មវិធី ក៏ជាបញ្ហាមួយដែលត្រូវធ្វើការសិក្សាទៅលើលទ្ធផលសិក្សារបស់សិស្ស ការសម្រេចបាននូវកម្មវិធីដែលត្រូវបានដាក់ឱ្យអនុវត្ត នោះវាជាគុណភាពនៃការអប់រំ។ គុណភាពអប់រំ វានឹងអាចសម្រេចទៅបានដោយមានកត្តារួមផ្សំជាច្រើន ដែលរួមសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស បុគ្គលិកអប់រំទាំងអស់ វាមិនមែនគ្រូបង្រៀនតែមួយមុខប៉ុណ្ណោះទេ ហើយដែលរួមមានទាំងឪពុក-ម្ដាយ អាណាព្យាបាល និងសហគមន៍ទាំងមូលផងដែរ(Hoy et al., 1999)។

ម្យ៉ាងវិញទៀត តាមការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា គ្រប់គ្រឹះស្ថានសិក្សាទាំងអស់នៅលើពិភពលោក ពេលវេលាសម្រាប់ការបង្រៀនពិតជាមានផលប៉ះពាល់ជាវិជ្ជមានទៅលើការសិក្សារបស់សិស្ស(OECD, 2011)។ នេះវានឹងមានទំនាក់ទំនងអវិជ្ជមានរវាងគ្រូ ហើយនឹងសិស្ស ឬក៏ទំនាក់ទំនងនឹងអវត្តមានរបស់សិស្ស វានឹងស្ដែងចេញពីលទ្ធផលសិក្សារបស់គ្រឹះស្ថាន។ តួយ៉ាងដូចជានៅក្នុងករណីប្រទេស Madagascar ការសិក្សាបានបង្ហាញឱ្យឃើញថា ក្នុងខណៈពេលដែលមានការកែលម្អនូវផែនការអប់រំសម្រាប់ទាំងអស់គ្នាកាលពីឆ្នាំ២០០៥ បានលេចជារូបរាងឡើង ម៉ោងបង្រៀនពិតប្រាកដនៅតាមតំបន់មួយចំនួនគឺស្មើនឹងពាក់កណ្ដាលនៃម៉ោងដែលក្រសួងអប់រំបានកំណត់។ ដូច្នេះម៉ោងបង្រៀននៅតាមតំបន់ គឺជាកត្តាមួយដែលមានឥទ្ធពលយ៉ាងខ្លាំង ដែលតម្រូវឱ្យលោកគ្រូ អ្នកគ្រូ និងអ្នកសិក្សានៅក្នុងការិយាល័យសិក្សាទាំងអស់ ធ្វើការសហការគ្នាដើម្បីបង្កើននូវចំណេះដឹងរបស់សិស្ស។ ម៉ោងបង្រៀនជាផ្លូវការនៅប្រទេសកម្ពុជាមានចំនួន ៦៨៤-៧៦០ ម៉ោងក្នុងមួយឆ្នាំសិក្សា ដែលជាតួលេខមួយដែលទាបជាងអនុសាសន៍ជាលក្ខណៈអន្តរជាតិដែលគួរតែមាន ៨៥០-១០០០ ម៉ោងក្នុងមួយឆ្នាំសិក្សា។ គុណភាពនៃការអប់រំទាបនៅកម្ពុជា គឺការបាត់បង់នៃម៉ោងបង្រៀនក្រៅផ្លូវការជាមធ្យមនៅឆ្នាំ២០១៣ មាន ២៧ ភាគរយនៃម៉ោងបង្រៀន (៥០.៥ ថ្ងៃ) ការបាត់បង់នេះ ដោយសារតែការឈប់សម្រាកផ្លូវការ ការអវត្តមានរបស់គ្រូ និងការបង្រៀនមិនពេញម៉ោងដោយសារចូលយឺត ចេញមុន(Vision, 2017)។

ម្យ៉ាងវិញទៀត បើយោងតាមការសិក្សាស្រាវជ្រាវរបស់ Glatthorn, Boschee, Whitehead, and Boschee (2019) បានបង្ហាញឱ្យដឹងថា មានគ្រូបង្រៀនប្រមាណជា ៧០.២៣% ដែលមិនអាចមានលទ្ធផលបង្រៀនបានចប់កម្មវិធីសិក្សា ដូចនេះមានតែគ្រូបង្រៀនចំនួន ២០.៧៧% ដែលបានបញ្ចប់នូវកម្មវិធីសិក្សាបានពេញលេញ។ ហេតុផលរបស់លោកគ្រូ-អ្នកគ្រូ បណ្តាលមកពីខ្វះខាតពេលវេលា នេះជាការព្រួយបារម្ភយ៉ាងខ្លាំងទៅលើមុខវិជ្ជាទាំងអស់ដែលក្រសួងអប់រំបានកំណត់។ យោងតាម Abadzi (2007) តួលេខនៃការអវត្តមានខ្ពស់របស់គ្រូបង្រៀន គឺជាការខ្វះខាតទៅលើការវិនិយោគវិស័យអប់រំ។ តាមការស្រាវជ្រាវបានបង្ហាញថា អវត្តមានរបស់គ្រូបង្រៀនមាន ១១ភាគរយនៅក្នុងប្រទេសប៉េរូ ២១ភាគរយនៅឥណ្ឌូនេស៊ី ២៧ភាគរយ នៅអ៊ុយហ្គង់ដា ៣០ភាគរយ នៅប្រទេសកេនយ៉ា។ សរុបជារួមមាន ២០-២៥ ភាគរយ ដែលគ្រូបង្រៀនអវត្តមាន ពិសេសសាលារៀននៅតាមតំបន់ជនបទដែលមានអត្រាខ្ពស់។ លើសពីនេះទៀតការបិទសាលារៀន និងការខ្វះខាតពេលវេលាក្នុងការបង្រៀនក្នុងថ្នាក់ក៏ជាកត្តាសំខាន់ផងដែរ។

### ២. ៣. ២. ផលប៉ះពាល់នៃការអវត្តមានរបស់គ្រូ

ការអវត្តមានញឹកញាប់របស់គ្រូ ដែលជាបញ្ហាកើតឡើងញឹកញាប់នៅក្នុងប្រទេសជាច្រើន ជាហេតុធ្វើឱ្យធ្លាក់ចុះនូវគុណភាពអប់រំ និងបណ្តាលឱ្យមានការខាតបង់ធនធាន។ នៅឆ្នាំ២០០៣ អ្នកអង្កេតសម្រាប់ការសិក្សាស្រាវជ្រាវមួយរបស់ធនាគារពិភពលោក បានធ្វើទស្សនកិច្ចចុះទៅពិនិត្យតាមសាលារៀនចំនួន ២០០ នៅក្នុងប្រទេសឥណ្ឌា មិនមានសកម្មភាពបង្រៀននៅក្នុងសាលារៀនចំនួនពាក់កណ្តាល។ គ្រូបង្រៀនមានដល់ទៅ ៤៥% នៅក្នុងប្រទេសអេត្យូពី បានអវត្តមានយ៉ាងហោចណាស់មួយថ្ងៃ ក្នុងមួយសប្តាហ៍មុនការចុះទស្សនកិច្ចមានចំនួន ២៦% ចំណែកនៅឯប្រទេសហ្សំប៊ីមានចំនួន ១៧%(Joshi & Verspoor, 2013)។

កម្រិតអវត្តមានខ្ពស់របស់គ្រូ ជាទូទៅបានបង្ហាញពីដំណើរការមិនល្អខ្លាំងនៅក្នុងប្រព័ន្ធអប់រំ ប៉ុន្តែវាអាចនឹងមានបុព្វហេតុផ្ទាល់ខុសៗគ្នា បទពិសោធន៍វិជ្ជាជីវៈធូរលុង កង្វះការជួយគាំទ្រ និងការត្រួតពិនិត្យពីសំណាក់អាជ្ញាធរអប់រំ គឺជាបញ្ហាចម្បងនៅក្នុងប្រទេសជាច្រើន។ ភាពខ្វះចន្លោះនៅក្នុងគោលនយោបាយអប់រំក៏ដើរតួនាទីសំខាន់ផងដែរ ឧទាហរណ៍ នៅកន្លែងដែលគ្រូបង្រៀនត្រូវបានចាត់ឱ្យទៅបង្រៀននៅ

កន្លែងផ្សេងៗ ត្រូវធ្វើដំណើរដើម្បីទៅមក ឬត្រូវចំណាយលើកន្លែងស្នាក់អាស្រ័យ ឬចាំបាច់ត្រូវរកការងារបន្ទាប់បន្សំ ដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្សរ៍ដែលមិនគ្រប់គ្រាន់ ក្នុងគោលបំណងដោះស្រាយកត្តាជីវភាពរស់នៅ(UNESCO, 2015a)

អវត្តមានរបស់គ្រូក្នុងការបង្រៀនសិស្សនៅក្នុងថ្នាក់ ពិតជាបានជះផលអវិជ្ជមានទៅដល់លទ្ធផលសិក្សារបស់សិស្ស ជាពិសេសក្នុងចំណោមសិស្សដែលមកពីគ្រួសារក្រីក្រ ដោយសារតែពួកគេពុំមានលទ្ធភាពចូលរៀនបន្ថែមតាមសាលាឯកជន និងមិនឆ្លងកាត់ការធ្វើតេស្តប្រឡងសាកល្បងផ្សេងៗ ជាហេតុដែលធ្វើឱ្យលទ្ធផលសិក្សារបស់ពួកគេកាន់តែទាប។ អត្រានៃចំនួនអវត្តមានរបស់គ្រូកាន់តែខ្ពស់ ប្រសិនបើគ្រូបង្រៀនតែម្នាក់ បង្រៀននៅកម្រិតថ្នាក់ដដែលចំនួន ២ឆ្នាំជាប់ៗគ្នា ហើយលទ្ធផលសិក្សារបស់សិស្សក៏នឹងធ្លាក់ចុះពី ៤-៨ ភាគរយក្នុងឆ្នាំសិក្សាដូចគ្នាផងដែរ។ ជាងនេះទៅទៀត ឥរិយាបថអវត្តមានក្នុងចំណោមគ្រូបង្រៀន ក៏ជះឥទ្ធិពលដល់ឥរិយាបថរបស់សិស្សដូចគ្នា(Abadzi, 2007)។ ការសិក្សាដដែលបានបង្ហាញថា ពេលវេលាបង្រៀនរបស់គ្រូ គឺជាផ្នែកមួយដ៏សំខាន់ដែលមានឥទ្ធិពលវិជ្ជមានទៅលើលទ្ធផលសិក្សារបស់សិស្ស ដែលបន្ថែមពីលើគុណភាពគ្រូបង្រៀន និងគុណភាពនៃសៀវភៅសិក្សា។

យោងតាមក្រសួង អ.យ.ក(២០១៨ក) អត្រាអវត្តមានខ្ពស់របស់គ្រូបង្រៀន គឺជាបញ្ហាចម្បងមួយនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍(Duflo, Hanna, & Ryan, 2012; Glewwe & Muralidharan, 2016; Banerjee & Duflo, 2006)។ ប្រសិនបើសាលាត្រូវបិទទ្វារនៅក្នុងថ្ងៃបង្រៀន ថ្នាក់រៀនមិនបានបើកបង្រៀន ឬគ្រូបង្រៀនធ្វើការងារផ្សេងៗទៀតជាជាងបង្រៀន សកម្មភាពនេះបានធ្វើឱ្យប៉ះពាល់ដល់គុណតម្លៃនៃការអប់រំ ហើយមិនត្រឹមតែសិស្សមិនអាចរៀនតាមកម្មវិធីសិក្សាប៉ុណ្ណោះទេ ថែមទាំងគ្រូបង្រៀនមិនអាចបង្ហាញពីសារសំខាន់នៃការខិតខំប្រឹងប្រែង និងការតស៊ូព្យាយាមដើម្បីភាពជោគជ័យក្នុងវិស័យអប់រំផងដែរ។ ការបាត់បង់ម៉ោងបង្រៀន ជាមូលហេតុនាំឱ្យមានការអនុវត្តកម្មវិធីសិក្សាមិនបានពេញលេញ សិស្សគេសាលាមានទំនោរបោះបង់ការសិក្សា ក្រោយរៀនចប់ទទួលបានការងារដែលមានប្រាក់ខែតិច ការមានផ្ទៃពោះដោយមិនចង់បាន ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹងហើយថែមទាំងក្លាយទៅជា

ជនល្មើសជាដើម(Baker, Sigmon, & Nugent, 2001; Meece & Eccles, 2010; Hallfors, et al., 2002; Henry & Huizinga, 2007; Juvonen, Espinoza, & Knifsend, 2012; Office for Standards in Education, 2001)(ក្រសួង អ.យ.ក ២០១៨ក)។

យោងតាម Ameeq (2018) អវត្តមានរបស់គ្រូមានឥទ្ធិពលធំទូលាយ ពិសេសនឹងមានឥទ្ធិពលលើប្រព័ន្ធអប់រំរបស់ប្រទេសទាំងមូល។ កម្រិតខ្ពស់នៃអវត្តមាន នឹងជះឥទ្ធិពលអវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្ស កេរ្តិ៍ឈ្មោះសាលារៀនរួមចំណែកដល់ការធ្លាក់ចុះនៃការប្រតិបត្តិវិជ្ជាជីវៈ និងបំផុសនូវអវត្តមានរបស់សិស្សផងដែរ។ តាមរបាយការណ៍ ដែលចេញដោយធនាគារពិភពលោកក្នុងឆ្នាំ ២០១៥ អំពីអវត្តមានរបស់គ្រូបង្រៀននៅអាស៊ី បានស្វែងយល់ថាម្ចាស់ជំនួយផ្តល់សម្ភារៈសិក្សា សៀវភៅសិក្សាដើម្បីកសាងប្រទេសរបស់ពួកគេ ទោះយ៉ាងណាប្រសិនបើគ្រូអវត្តមានពីសាលាជាទៀងទាត់ នោះសិស្សមិនអាចរៀនបានត្រឹមត្រូវទេ វាជាការខ្ជះខ្ជាយនូវថវិកាយ៉ាងច្រើន។ នៅក្នុងរបាយការណ៍នេះក៏ត្រូវបានអះអាងថាគ្រូបង្រៀននៅកម្រិតវិទ្យាល័យ ការអវត្តមានរបស់ពួកគេពីប្រព័ន្ធសាលារៀន នឹងប៉ះពាល់ដល់បញ្ហាសំខាន់ៗសម្រាប់ការគ្រប់គ្រងគុណភាពភាព ការធ្លាក់ចុះនៃស្មារតីសីលធម៌ និងទំនួលខុសត្រូវក្នុងការអប់រំ(Oakes, Jeannie, et al)។ អ្នកស្រាវជ្រាវបានលើកឡើងពីទំនាក់ទំនង រវាងឥទ្ធិពលនៃអវត្តមានរបស់គ្រូលើការអប់រំសិស្សដូច្នេះភស្តុតាងនៅអាស៊ី និងអាមេរិកឡាទីនកន្លែងល្អប្រសើរ និងមានហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរផ្តល់ដល់តួនាទីគ្រូដែលមានការប្រកួតប្រជែង មានអត្រាអវត្តមានទាប។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការលើកទឹកចិត្តអាចជួយយើងក្នុងការកាត់បន្ថយអវត្តមាន។ ដូចគ្នានេះផងដែរ អធិការកិច្ចសាលារៀនជារៀងរាល់ថ្ងៃអាចជួយកាត់បន្ថយបញ្ហានេះ (Chaudhury, Nazmul, et al 2006)។

## ២. ៣. ៣. គុណភាពបង្រៀននៅក្នុងថ្នាក់រៀន

យោងតាមក្រសួង អ.យ.ក(២០១៨ក) គ្រូបង្រៀន គឺជាធនធានយ៉ាងសំខាន់បំផុតមួយនៅក្នុងសាលារៀននាពេលបច្ចុប្បន្ននេះ។ នៅក្នុងវិស័យអប់រំ ការបង្រៀន ជាកត្តាកំណត់លទ្ធផលសិក្សារបស់សិស្ស ហើយមិនមានកិច្ចអន្តរាគមន៍ណាមួយ ដែលអាចជួយលើកកម្ពស់ការរៀនសូត្ររបស់សិស្សដោយមិនពឹង

ផ្អែកលើគ្រូបង្រៀននោះទេ(Darling-Hammond, et al., 2017)។ យោងតាមអនុក្រឹត្យ រាជរដ្ឋាភិបាលកម្ពុជា (២០១៧) បានបង្ហាញថា តាមនិយាមគ្រូបង្រៀនម្នាក់ ត្រូវបង្រៀនទ្រឹស្តីប្រចាំសប្តាហ៍ ១៦ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ និងម៉ោងណែនាំអនុវត្តរៀបចំការងារបង្រៀន ១៨ ម៉ោងក្នុងមួយសប្តាហ៍ សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ។ តាមការរំពឹងទុករបស់អ្នករៀបចំកម្មវិធីសិក្សា ចំនួនម៉ោងបង្រៀនតាមទ្រឹស្តី គឺគ្រប់គ្រាន់សម្រាប់បង្រៀនសិស្សឱ្យទទួលបានលទ្ធផលល្អ ផ្ទុយមកវិញ សាលារៀននិងថ្នាក់រៀនភាគច្រើនត្រូវបានគេសង្កេតឃើញថា មានការបាត់បង់ម៉ោងសិក្សា។ ម៉ោងសិក្សាដែលអនុវត្តជាក់ស្តែង អាចខុសពីម៉ោងរំពឹងទុកដោយមូលហេតុផ្សេងៗ ដែលមូលហេតុភាគច្រើនរួមមាន៖ អវត្តមានសិស្ស ការមករៀនយឺតរបស់សិស្ស និងមូលហេតុជាច្រើនធ្វើឱ្យសាលរៀនបិទទ្វារ ឬកែប្រែកម្មវិធីបង្រៀនដែលធ្លាប់បង្រៀនធម្មតា ដោយសារអវត្តមានរបស់គ្រូ គ្រោះធម្មជាតិ។ លើសពីនេះ សូម្បីតែនៅពេលដែលថ្នាក់រៀនបានដំណើរការ សិស្សមានវត្តមាននៅក្នុងថ្នាក់ទៅហើយក្តី ក៏ការបាត់បង់ម៉ោងបង្រៀននៅតែកើតមានជាញឹកញាប់ ដោយសារសិស្សមិនមានវិន័យ គ្រូត្រូវចំណាយពេលវេលារក្សាសណ្តាប់ធ្នាប់ ជាជាងការងារបង្រៀន(ក្រសួង អ.យ.ក ២០១៨ក)។ ស្របគ្នាទៅនឹងការលើកឡើងខាងលើ កាលពីខែ មករា ឆ្នាំ ២០១៨ កន្លងទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានរំឭកដល់ប្រធានមន្ទីរអប់រំ រាជធានី ខេត្តឱ្យពង្រឹងការងារគ្រប់គ្រងគ្រឹះស្ថានសិក្សា និងពង្រឹងវិន័យ ចំពោះគ្រូបង្រៀនដែលមិនយកចិត្តទុកដាក់លើការបង្រៀន ឬមិនបំពេញភារកិច្ចឱ្យបានល្អ ខណៈមានការរកឃើញពីការបាត់បង់ពេលវេលានៃការបង្រៀននាពេលកន្លងមក។ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឲ្យចាត់វិធានការពង្រឹងវិន័យ និងការគ្រប់គ្រងបុគ្គលិកអប់រំ ឬគ្រូបង្រៀន នៅគ្រប់គ្រឹះស្ថានអប់រំសាធារណៈទាំងអស់។

ប្រសិទ្ធភាពរបស់គ្រូបង្រៀនក្នុងការធានាថា សិស្សចូលរួមរៀនសូត្រក្នុងអំឡុងពេលបង្រៀន គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់ពួកគាត់ នៅក្នុងការគ្រប់គ្រងឥរិយាបថរបស់សិស្សព្រមទាំងរក្សាការបង្រៀនដើម្បីបំពេញលើតម្រូវការរបស់អ្នកសិក្សាគ្រប់ៗរូប ព្រមទាំងត្រូវមានទទួលខុសត្រូវក្នុងការបំពេញការងារប្រកបដោយភាពហ្មត់ចត់(ក្រសួង អ.យ.ក ២០១៨ក)។ ជាងនេះទៅទៀត សកម្មភាពដឹកនាំការ

រៀន និងការបង្រៀនរបស់គ្រូនៅក្នុងថ្នាក់រៀន ជាកត្តាចាំបាច់ដែលជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស ដូចជាវិធីសាស្ត្របង្រៀន សម្ភារឧបទេសជំនួយការបង្រៀន ភាពទៀងទាត់នៃការបង្រៀនរបស់គ្រូក្នុងការយកចិត្តទុកដាក់លើការរៀនរបស់សិស្សទាំងផ្នែកវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា(MoEYS, 2019)។

## ២. ៤. ស្តង់ដារសម្រាប់ការបង្រៀន

### ២. ៤. ១. គ្រូបង្រៀនជាអ្វី?

គ្រូបង្រៀន គឺជាកូនសោរដើម្បីសំរេចបាននូវរាល់របៀបវារៈអប់រំឆ្នាំ ២០៣០... ក្នុងនាមជាគ្រូ គឺជាលក្ខខណ្ឌគ្រឹះសម្រាប់ការធានានូវការអប់រំប្រកបដោយគុណភាព គ្រូបង្រៀន និងអ្នកអប់រំគួរតែត្រូវបានផ្តល់សិទ្ធិអំណាចជ្រើសរើស និងផ្តល់សំណងគ្រប់គ្រាន់ឱ្យមានជំនាញវិជ្ជាជីវៈ និងត្រូវបានគាំទ្រផ្នែកធនធានហើយមានប្រព័ន្ធគ្រប់គ្រងប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព(UNESCO et al., 2015, p. 21)។ម៉្យាងវិញទៀត ការអប់រំឆ្នាំ ២០៣០ បញ្ជាក់ច្បាស់ថា "គ្រូបង្រៀន អ្នកអប់រំ និងស្ថាប័នរបស់ពួកគេ គឺជាដៃគូសំខាន់ ហើយពួកគេគួរតែសិទ្ធិរបស់ចូលរួមនៅគ្រប់ដំណាក់កាល"(UNESCO, 2015b)

គ្រូបង្រៀន គឺជាអ្នកអប់រំប្រៀនប្រដៅសិស្ស ជាអ្នកបំភ្លឺបង្ហាញផ្លូវដល់សិស្ស ជាបុគ្គលដែលគួរឱ្យគេគោរព។ ម្យ៉ាងទៀត គ្រូបង្រៀនមានន័យច្រើនយ៉ាង ជាមនុស្សដែលមានសារៈប្រយោជន៍ ទី១៖ គ្រូបង្រៀនត្រូវបានគេឱ្យនិយមន័យថា ជាតួសម្តែង ទី២៖ គ្រូបង្រៀន គឺជាអ្នកបង្កើតនូវវង់តន្ត្រី ពីព្រោះគ្រូគឺជាអ្នកគ្រប់គ្រង និងរៀបចំនូវកិច្ចការសព្វបែបយ៉ាងក្នុងថ្នាក់រៀន ទី៣៖ គ្រូបង្រៀន គឺជាអ្នកថែរក្សា មានន័យថាគ្រូបង្រៀនត្រូវតែយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ចំពោះសិស្សរបស់ខ្លួន។ គ្រូបង្រៀន ត្រូវតែការពារសិស្សរបស់ខ្លួន ទោះបីជាសិស្សទាំងនោះមានទោសកំហុសក៏ដោយ។ លើសពីនេះទៅទៀត គ្រូបង្រៀនត្រូវបានគេចាត់ទុកជាឪពុក-ម្តាយទី២ មានន័យថា ពេលដែលសិស្សនៅផ្ទះ ពួកគេមានឪពុក-ម្តាយគឺជាអ្នកមើលថែរក្សា ប៉ុន្តែនៅពេលដែលពួកគេបានមកដល់សាលារៀន មានលោកគ្រូ-អ្នកគ្រូគឺជាអ្នកមើលការខុសត្រូវគ្រប់សកម្មភាពដែលកើតមានឡើង។ ចុងក្រោយនេះ គ្រូបង្រៀន គឺជាអ្នកផ្តល់ដំបូន្មាន នៅខណៈពេលដែលសិស្សមានបញ្ហា(Myrdal, Schratz, Snoek, Stéger, & Caena, 2013)។

ការសិក្សាជាច្រើនបានបង្ហាញថា គ្រូបង្រៀនមានសញ្ញាបត្រកាន់តែខ្ពស់ ការបង្រៀនកាន់តែមានគុណភាព(ក្រសួង អ.យ.ក ២០១៨)។ គ្រូបង្រៀនទាំងឡាយតែងតែបានចែករំលែកនូវជំនាញ ចំណេះដឹង និងបទពិសោធន៍សម្រាប់ការចូលរួមសម្រេចកិច្ចការងារផ្សេងៗ ពីព្រោះគ្រូបង្រៀនមានជំនាញច្រើនជាងមនុស្សទូទៅ។ យោងតាម SIREP (2010) គុណវុឌ្ឍិរបស់គ្រូបង្រៀន នៅក្នុងបណ្តាប្រទេសអាស៊ានត្រូវមានសមាសធាតុសំខាន់ៗចំនួន ៦ គឺ៖ ចំណេះដឹងលើមុខជំនាញឯកទេស ចំណេះដឹងលើផ្នែកគរុកោសល្យ(ចិត្តគរុកោសល្យ និងជំនាញបង្រៀន) ចំណេះដឹងលើផ្នែកភាសាបរទេស ចំណេះដឹងលើផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា ចំណេះដឹងលើផ្នែកក្រមសីលធម៌វិជ្ជាជីវៈ និងបុគ្គលិកលក្ខណៈសម្បត្តិ។ លើសពីនេះទៅទៀត បុគ្គលិកលក្ខណៈមួយចំនួនដែលបានផ្សារភ្ជាប់បុគ្គលឱ្យក្លាយទៅជាគ្រូបង្រៀន យោងតាម Oxfam (2011) មានដូចជា៖

ក. ការរៀបចំមេរៀនដើម្បីឱ្យមានភាពទាក់ទាញ៖ រាល់អត្ថបទ ឬខ្លឹមសារមេរៀនត្រូវមានការចាប់អារម្មណ៍ និងផ្តល់ផលប្រយោជន៍ឱ្យសិស្សអាចអនុវត្តបាននៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ និងស្របទៅតាមតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត។ ម្យ៉ាងខ្លឹមសារត្រូវ រៀបចំឱ្យមានលក្ខណៈងាយយល់ មិនមានភាពស្មុគស្មាញ ដើម្បីងាយស្រួលដល់អ្នកសិក្សា មានប្រយោជន៍ចំពោះខ្លួនឯង និងសង្គមជាតិ។

ខ. ស្រលាញ់នូវការងាររបស់ខ្លួន៖ ការងារ គឺជាវត្ថុដ៏មានតម្លៃលើសអ្វីៗទាំងអស់សម្រាប់មនុស្សគ្រប់រូប មិនថាការងារនោះមានលក្ខណៈតូចក្តី ធំក្តី សុទ្ធតែផ្តល់ផលប្រយោជន៍ ក្នុងន័យនេះអាចនិយាយបានថា បុគ្គលិកគ្រប់រូបត្រូវប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត អនុវត្តនូវការងាររបស់ខ្លួន ការងារនោះនឹងផ្តល់ឱ្យមកវិញនូវតម្លៃ កិត្តិយស អំណាចដែលគេត្រូវការចង់បាន។

គ. ទទួលខុត្រូវនូវទង្វើរបស់ខ្លួនដែលបានប្រតិបត្តិ៖ ការទទួលខុសត្រូវ គឺជាការបង្ហាញឱ្យឃើញនូវចរិតលក្ខណៈរបស់មនុស្ស និងឆ្លុះបញ្ចាំងពីភាពជាក់ស្តែងក្នុងការអនុវត្តការងារ មានន័យថាការទទួលខុសត្រូវជាទង្វើប្រកបដោយគតិបណ្ឌិត ហើយសាកសមជាមនុស្សពិតៗ។ មួយវិញទៀត រាល់សកម្មភាពដែល

យើងបានអនុវត្ត ប្រសិនបើបរាជ័យដោយប្រការណាមួយ មិនបានទម្លាក់កំហុសឱ្យទៅបុគ្គលណាមួយនោះទេ ត្រូវចូលរួមដោះស្រាយប្រកបដោយទំនួលខុសត្រូវខ្ពស់ទាំងអស់គ្នា ពិសេសក្នុងនាមជាអ្នកគ្រប់គ្រង។

ឃ. ការផ្តល់យោបល់ និងទស្សនៈដល់សិស្ស៖ ក្នុងនាមជាអ្នកអប់រំ វាមិនមែនជាការងាយស្រួលនោះទេ ត្រូវឆ្លងកាត់ការរៀនសូត្រ និងការសិក្សាស្រាវជ្រាវជាច្រើនឆ្នាំ ព្រោះក្នុងនាមយើងជាមនុស្សគំរូពេលគឺរាល់សកម្មភាពអនុវត្ត ពាក្យសម្តីរបស់អ្នកអប់រំពិតជាមានន័យ ប្រកបដោយការអប់រំ ដូចនេះត្រូវតែពិចារណាឱ្យបានត្រឹមត្រូវច្បាស់លាស់មុននឹងធ្វើការសម្រេចចិត្តផ្តល់ឱ្យទៅនរណាម្នាក់។ តួយ៉ាងសិស្សគ្រប់រូបប្រៀបបានទៅនឹងកំណាត់សមួយដុំ ងាយនឹងឃើញស្នាមប្រឡាក់ ឆាប់ទទួលយកនូវអ្វីដែលមិនល្អ អាចនិយាយបានថា ការផ្តល់យោបល់ ឬទស្សនៈអ្វីមួយត្រូវតែមានការប្រុងប្រយ័ត្ន និងគិតគូរឱ្យបានហ្មត់ចត់បំផុត។

ង. ការប្រាស្រ័យទាក់ទងជាមួយសិស្ស៖ គ្រូបង្រៀន គឺជាបុគ្គលម្នាក់ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀន និងរៀនរបស់សិស្សគ្រប់រូប ជាមនុស្សមានឥទ្ធិពលក្នុងថ្នាក់រៀន ហើយដើម្បីជានាឱ្យការផ្តល់ចំណេះដឹង បំណិន ឱ្យសិស្សងាយស្រួលចាប់បាន គ្រូ និងសិស្សត្រូវតែមានទំនាក់ទំនងគ្នាទៅវិញទៅមក ទាំងពាក្យសម្តី ភាសា អាកប្បកិរិយា របស់គ្រូត្រូវតែមានភាពទន់ភ្លន់ ច្បាស់លាស់ បត់បែនទៅតាមកាលៈទេសៈ គ្រប់រូបភាពគ្រប់ទីកន្លែង ដើម្បីឱ្យសិស្សហ៊ាននិយាយ ឆ្លើយតបជាមួយគ្រូដោយគ្មានអារម្មណ៍រងនូវសំពាធទាំងផ្លូវចិត្តរបស់ពួកគេ(Slavin, 2006)។

យោងតាម SIREP (2010) លទ្ធផលនៃការសិក្សាស្រាវជ្រាវបានកំណត់នូវសមាសធាតុស្តង់ដាសមត្ថភាពគ្រូសម្រាប់ការបង្រៀនក្នុងតំបន់អាស៊ីអាគ្នេយ៍គឺ៖

(១) ចំណេះដឹងជំនាញ៖ សំដៅទៅលើភាពប៉ិនប្រសប់នៃខ្លឹមសារ និងវិធីសាស្ត្រក្នុងការបង្រៀន។

(២) ជំនាញវិជ្ជាជីវៈ៖ សំដៅទៅលើគុរុកោសល្យ ការគ្រប់គ្រងថ្នាក់រៀន និងវាយតម្លៃអ្នកសិក្សា។

(៣) ចរិតលក្ខណៈផ្ទាល់ខ្លួន៖ សំដៅទៅលើការប្រព្រឹត្ត កិរិយាមាយាទ ដូចជាការទទួលខុសត្រូវការគោរពពេលវេលា។

(៤) គុណធម៌វិជ្ជាជីវៈផ្ទាល់ខ្លួន៖ សំដៅទៅលើស្តង់ដារសុជីវធម៌ និងសីលធម៌ដែលនាំឱ្យគ្រូក្លាយជាគំរូល្អនៅក្នុងសាលារៀន និងសហគមន៍។

(៥) ការអភិវឌ្ឍវិជ្ជាជីវៈ និងការសិក្សារៀនសូត្រពេញមួយជីវិត៖ សំដៅទៅលើការអភិវឌ្ឍវិជ្ជាជីវៈពេញមួយជីវិតដែលធ្វើឡើងដោយគ្រូដូចជា ការចូលរួមក្នុងអង្គការគ្រូបង្រៀន និងសកម្មភាពនានាដែលបង្ហាញពីបំណងចង់លើកកម្ពស់វិជ្ជាជីវៈបង្រៀន។

## ២. ៤. ២. តួនាទីរបស់គ្រូបង្រៀន

គ្រូបង្រៀន គឺជាធាតុចូលយ៉ាងសំខាន់ខ្លាំងបំផុត ដើម្បីធានាគុណភាពនៃការរៀនសូត្ររបស់សិស្ស ហើយគុណភាពនៃការអប់រំ គឺផ្អែកទៅលើគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលា(Hang-Chuon, 2018)។ ដើម្បីឱ្យការបង្រៀន និងរៀនមានលទ្ធផលជាផ្លែផ្កា និងសម្រេចបានតាមវត្ថុបំណងដែលបានកំណត់ ទាមទារឱ្យគ្រូបង្រៀនទទួលខុសត្រូវ អនុវត្តការកិច្ច ប្រកាន់ភ្ជាប់នូវតួនាទី និងបំពេញកិច្ចការរបស់ខ្លួនឱ្យបានច្បាស់លាស់។ យោងតាមការសិក្សារបស់(Harmer, 2005) បានកំណត់តួនាទីរបស់គ្រូបង្រៀនមានប្រាំបីចំណុច នៅក្នុងដំណើរការបង្រៀន និងរៀនរួមមាន ជាអ្នកតាមដានត្រួតពិនិត្យ អ្នករៀបចំចាត់ចែង អ្នកវាយតម្លៃ អ្នកផ្ទៀងផ្ទាត់គាំទ្រ អ្នកចូលរួម អ្នកមានធនធាន អ្នកបង្ហាត់ និងអ្នកសង្កេត។

អ្នកតាមដានត្រួតពិនិត្យ៖ គ្រូបង្រៀនត្រូវធ្វើការត្រួតពិនិត្យនៅរាល់សកម្មភាពក្នុងការសិក្សារបស់សិស្ស ដើម្បីធានាបាននូវទង្វើមួយមានភាពច្បាស់លាស់។ ជាធម្មតា ការពិនិត្យតាមដានត្រូវបានចែកចេញជាបីដំណាក់កាលធំៗ (១) ដំណាក់កាលមុនពេកពិនិត្យតាមដាន ជាដំណាក់កាលមួយត្រូវពិនិត្យមើលថាតើ ចង់ទៅមើលអ្វី ចង់ដឹងអំពីអ្វី ហើយក្រុមគោលដៅជានរណា មានប៉ុន្មាននាក់ មានទីតាំងនៅកន្លែងណា ប្រើប្រាស់ពេលវេលាប៉ុន្មាន និងត្រូវចំណាយទៅលើអ្វីខ្លះ។ ម្យ៉ាងទៀត កត្តាសំខាន់នោះត្រូវរៀបចំឧបករណ៍ដើម្បីជួយដល់អ្នកពិនិត្យតាមដានក្នុងដំណើរការបំពេញការងារ និងត្រូវដឹងពីផលប៉ះពាល់នៃការអនុវត្តកម្មវិធី ជួយផ្តល់នូវលទ្ធផលនៃការបំពេញការងារ ដើម្បីជាភស្តុតាងបញ្ជាក់បន្ថែមពីលក្ខណៈពិសេសរបស់ស្ថានភាពមួយ ឬមូលហេតុនៃបម្រែបម្រួលនានាទៅលើការវិភាគទិន្នន័យដែលទទួលបាន

ស្រាប់ ក៏ដូចជាលទ្ធផលរបស់ដំណើរការបង្រៀន និងការរៀន។ (២) ដំណាក់កាលដំណើរការត្រួតពិនិត្យ ការពិនិត្យតាមដាន ត្រូវកំណត់ថាមានក្រុមគោលដៅប៉ុន្មាននាក់ ត្រូវប្រើប្រាស់វិធីសាស្ត្រអ្វី តាមរយៈការបំពេញកម្រងសំណួរ ការសម្ភាស ឬការអង្កេត។ (៣) ដំណាក់កាលក្រោយការត្រួតពិនិត្យ ជាផ្នែកមួយសំខាន់សម្រាប់បង្ហាញពីបញ្ហាប្រឈម និងផលអវិជ្ជមាននូវអ្វីដែលចង់បាន រាល់សកម្មភាពអវិជ្ជមាននេះត្រូវយកទៅកែលម្អ រកវិធីសាស្ត្រដោះស្រាយ។ ឧទាហរណ៍ ដូចជាការអនុវត្តកម្មវិធីសិក្សា ប្រសិនបើពុំមានការពិនិត្យតាមដាន ការស្រាវជ្រាវលើការបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស ពិតជាមិនដឹងថាសិស្សអាចទទួលបានចំណេះដឹងដល់កម្រិតណា ហើយការអនុវត្តកម្មវិធីសិក្សា ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងបានកម្រិតណា តើរបាយការណ៍ផ្តល់ជូនស្តីពីការងារនេះ មានភាពត្រឹមត្រូវបានកម្រិតណា។

អ្នករៀបចំចាត់ចែង៖ គ្រូបង្រៀនត្រូវរៀបចំចាត់ចែងគ្រប់សកម្មភាពសព្វបែបយ៉ាង ដែលមានការជាប់ទាក់ទងយ៉ាងជិតស្និតជាមួយសកម្មភាពរបស់សិស្ស។ ជាទូទៅ ការចាត់ចែងរៀបចំរបស់គ្រូបង្រៀន វាមិនខុសគ្នាពីការចាត់ចែងរៀបចំរបស់ប្រធានអង្គភាពផ្នែករដ្ឋ ឬផ្នែកឯកជននោះទេ គ្រាន់តែថាទំហំការងារការទទួលខុសត្រូវមានតាមកម្រិត។ ក្នុងន័យនេះគ្រូបង្រៀន ត្រូវរៀបចំកិច្ចការរបស់ខ្លួន មានកិច្ចតែងការបង្រៀន សម្ភារឧបទេសសម្រាប់បង្រៀន បង្រៀនមានលំដាប់លំដោយ រៀបចំលំហាត់ ឬកិច្ចការផ្ទះសម្រាប់សិស្សដោយគិតយ៉ាងហ្មត់ចត់ពីកម្រិតនៃចំណេះដឹងរបស់សិស្សម្នាក់ៗ មិនមានភាពងាយស្រួលពេក ឬលំបាកពេក ជាងនេះទៅទៀត គ្រូបង្រៀនត្រូវមានបញ្ជីឈ្មោះសិស្ស បញ្ជីដាក់ពិន្ទុ សៀវភៅសម្រង់អត្តបទ សៀវភៅវត្តមាន សៀវភៅតាមដានសិស្សរៀនយឺត។ លើសពីនេះទៅទៀត គ្រូបង្រៀនត្រូវតែពិនិត្យមើលចាត់ចែងអនាម័យបរិស្ថានទសងក្នុង និងក្រៅថ្នាក់រៀន សណ្តាប់ធ្នាប់របស់សិស្សជាដើម។ ឧទាហរណ៍ ក្នុងថ្នាក់រៀនមួយ ប្រសិនបើពុំមានការចាត់ចែងរបស់គ្រូ នោះថ្នាក់រៀនប្រាកដជាមិនមានភាពល្អប្រសើរ ហើយលទ្ធផលនៃការសិក្សារបស់សិស្ស ក៏ប្រាកដជាមិនទទួលបានលទ្ធផលល្អប្រសើរនោះដែរ ហើយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាពិតជាមានការកើនឡើង។

អ្នកវាយតម្លៃ៖ គ្រូបង្រៀន ត្រូវធ្វើការវាយតម្លៃនូវសកម្មភាពរបស់សិស្ស ជាពិសេសការប្រតិបត្តិរបស់សិស្សក្នុងពេលកំពុងបង្រៀន ដើម្បីងាយដឹងពីព័ត៌មានត្រឡប់របស់សិស្ស។ ស្របពេលជាមួយគ្នានេះដែរ ការវាយតម្លៃទាមទារឱ្យលោកគ្រូ-អ្នកគ្រូមានព័ត៌មានគ្រប់គ្រាន់ ហើយព័ត៌មាននោះត្រូវធានាឱ្យបាននូវភាពពិតប្រាកដដូចជា លទ្ធផលសិក្សារបស់សិស្សប្រចាំខែនីមួយៗ បញ្ជីវត្តមានសិស្ស សៀវភៅសម្រង់ពិន្ទុ សៀវភៅតាមដានសិស្សខ្សោយ ព័ត៌មានទាំងអស់នោះ នឹងធ្វើឱ្យអ្នកវាយតម្លៃមានភាពងាយស្រួល ហើយការវាយតម្លៃនឹងទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ការវាយតម្លៃ វាពិតជាមានសារៈប្រយោជន៍ណាស់ក្នុងការអនុវត្តគម្រោងផែនការសកម្មភាព ជាពិសេសសកម្មភាពក្នុងពេលកំពុងបង្រៀន។ ឧទាហរណ៍ ប្រសិនបើសិស្សមួយក្រុមមានលទ្ធផលសិក្សាល្អ ឬមិនល្អដោយពុំមានការវាយតម្លៃបានត្រឹមត្រូវ នោះប្រាកដជាសិស្សមានការតវ៉ាចំពោះលទ្ធផលនោះ ហើយសិស្សប្រាកដជាមានការបាត់បង់ការជឿជាក់ និងបាត់បង់ក្តីសង្ឃឹមក្នុងការខិតខំប្រឹងប្រែងសិក្សារបស់ពួកគេ។

អ្នកគាំទ្រ៖ គ្រូបង្រៀនត្រូវតែមានការគាំទ្រចំពោះតម្រូវការសិស្ស និងចូលរួមដោះស្រាយគ្រប់សកម្មភាពដែលមានបញ្ហាកើតឡើង។ វាពិតជាមានសារៈសំខាន់ណាស់ ការគាំទ្រជាចំណែកមួយដែលមិនអាចខ្វះបានក្នុងដំណើរការបង្រៀន និងរៀន ពីព្រោះអ្នកគាំទ្រ ដើរតួនាទីយ៉ាងសំខាន់ក្នុសកម្មភាពបង្រៀនជួយរាល់សកម្មភាពដែលកើតមានឡើងចំពោះសិស្ស និងមានការអត់ធ្មត់ខ្ពស់ក្នុងាការដោះស្រាយចម្ងល់ក៏ដូចជាការជំរុញឱ្យមានការខិតខំប្រឹងប្រែងសិក្សាដល់សិស្ស ដើម្បីធានាបាននូវគុណភាពអប់រំមួយប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងនៅក្នុងគ្រឹះស្ថានសិក្សាមួយ ប្រសិនបើពុំមានអ្នកគាំទ្រនោះទេ រាល់ចម្ងល់របស់សិស្ស តើអ្នកណាជាអ្នកដោះស្រាយ បំភ្លឺផ្លូវទៅរកភាពល្អប្រសើរ ហើយគ្រឹះស្ថានសិក្សានោះ ប្រាកដជាមិនទទួលបាននូវគុណភាពអប់រំនោះទេ។

អ្នកចូលរួម៖ គ្រូបង្រៀនត្រូវ ចូលរួមគ្រប់សកម្មភាពរបស់សិស្សទាំងអស់ ជាបុគ្គល ជាក្រុមក្នុងការផ្តល់យោបល់ គំនិតល្អៗខណៈពេលកំពុងអនុវត្តការងារ។ ការចូលរួម ពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការបង្រៀន និងរៀន ដើម្បីឱ្យការបង្រៀនទទួលបាននូវប្រសិទ្ធភាព និងគុណភាព លោកគ្រូ

អ្នកគ្រូត្រូវចូលរួមគ្រប់រូបភាពទោះបីក្នុងស្ថានភាពងាយស្រួល ឬស្ថានភាពស្មុគ្រស្មាញយ៉ាងណាក៏ដោយ។ គួយ៉ាងប្រសិនបើក្នុងថ្នាក់រៀនមួយ ដែលពុំមានការចូលរួមសម្របសម្រួល ពីសំណាក់លោកគ្រូ-អ្នកគ្រូទេ នោះសកម្មភាពរៀន និងបង្រៀនប្រាកដជាទទួលភាពបរាជ័យ។

អ្នកមានធនធាន៖ គ្រូបង្រៀនត្រូវផ្តល់ធនធានដែលខ្លួនមាន ផ្ទេរទៅឱ្យសិស្សគ្រប់រូប តាមទិដ្ឋភាពនានាដែលអាចធ្វើទៅបាន។ នៅក្នុងន័យនេះ លោកគ្រូ-អ្នកគ្រូត្រូវកសាងសមត្ថភាពរបស់ខ្លួនឱ្យបានពេញលេញ តាមរយៈការសិក្សាស្រាវជ្រាវមេរៀន ដកស្រង់បទពិសោធន៍ល្អៗ បច្ចេកទេស វិធីសាស្ត្របង្រៀន ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីធានាឱ្យការផ្ទេរចំណេះដឹង ការបណ្តុះបំណិនឱ្យសិស្សទទួលបានភាពជោគជ័យ។ ប្រសិនបើអ្នកផ្តល់ចំណេះដឹងឱ្យគេ ពុំមានសមត្ថភាពគ្រប់គ្រាន់ តើអ្នកទទួលចំណេះដឹងនោះនឹងទទួលបានកម្រិតណា ហើយទៅជាយ៉ាងណា។

អ្នកបង្ហាត់៖ ជាធម្មតាអ្នកបង្ហាត់មិនមែនសំដៅតែសកម្មភាពនៅក្នុងថ្នាក់ប៉ុណ្ណោះទេ សកម្មភាពក្រៅថ្នាក់ដែលគ្រូច្នៃប្រឌិតបញ្ហាដើម្បីឱ្យសិស្សធ្វើការសិក្សាស្រាវជ្រាវដោយខ្លួនឯង រួមទាំងមិនកំណត់នូវបរិមាណសិស្សចូលរួមផងដែរ។ ក្នុងន័យនេះ អ្នកបង្ហាត់ទាមទារត្រូវតែស្វែងយល់ពីសមត្ថភាពរបស់សិស្សម្នាក់ៗ ថាតើសិស្សដែលមានសមត្ថភាពពូកែ មធ្យម និងខ្សោយមានប៉ុន្មានភាគរយ នេះជាចំណុចសំខាន់ដែលធ្វើឱ្យអ្នកបង្ហាត់មានភាពងាយស្រួលបង្ហាត់ និងរកវិធីសាស្ត្រដែលសមស្រប ដើម្បីជួយសិស្សទៅតាមសមត្ថភាពរបស់ពួកគេម្នាក់ៗ។

អ្នកសង្កេត៖ ជាទូទៅគ្រូបង្រៀន ត្រូវតែមានទេពកោសល្យជាចាំបាច់ នៅក្នុងការសង្កេតសិស្សនៅក្នុងដំណើរបង្រៀន និងរៀន។ ក្នុងន័យនេះ ជាចំណុចសំខាន់ដែលគ្រូអាចជួយសិស្ស និងស្វែងយល់ពីស្ថានភាពរបស់សិស្សម្នាក់ៗ ដែលអាចជួយគ្រូឱ្យមានភាពងាយស្រួល ក្នុងការជួយសិស្ស ជាពិសេសសិស្សរៀនយឺត ដែលពួកគេអាចមានស្ថានភាពផ្សេងៗពីសិស្សដទៃទៀត ដែលជាមូលហេតុនៃការរៀនយឺតរបស់ពួកគេ។

យោងតាម វណ្ណី (២០១៩) ពីមួយថ្ងៃទៅមួយថ្ងៃគ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ៗជាច្រើននៅឯសាលារៀនដូចជា៖

អ្នកគ្រប់គ្រង៖ ក្នុងនាមជាអ្នកគ្រប់គ្រង គ្រូបង្រៀនទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃថ្នាក់រៀនតាំងពីពេលចាប់ផ្តើម រហូតដល់ចុងបញ្ចប់។ គ្រូត្រូវតែអនុវត្ត នូវរាល់សកម្មភាពប្រចាំថ្ងៃជាប្រព័ន្ធដើម្បីអភិវឌ្ឍការយល់ដឹងពីទិដ្ឋភាពនៃចិត្តវិទ្យា និងទិដ្ឋភាពនៃដំណើរការបង្រៀន និងការរៀនប្រកបដោយប្រសិទ្ធភាព។ ដូច្នេះការខ្នះខ្នែង និងចំណាប់អារម្មណ៍របស់សិស្ស ក្នុងការចូលរួមសកម្មភាពរៀនសូត្រទាំងអស់ គឺបង្ហាញពីការគ្រប់គ្រងថ្នាក់រៀនដ៏មានសណ្តាប់ធ្នាប់ដែលត្រូវបានរៀបចំ និងដឹកនាំដោយគ្រូបង្រៀន។

ជាទីប្រឹក្សា៖ គ្រូបង្រៀនគ្រប់រូបជាអ្នកណែនាំ ជាអ្នកផ្តល់ប្រឹក្សាដល់សិស្ស ជាពិសេសនៅពេលដែលពួកគេមានបញ្ហា។ ក្នុងនាមជាអ្នកផ្តល់យោបល់ គ្រូបង្រៀនត្រូវរក្សានូវរាល់សកម្មភាពរបស់សិស្សដោយការយកចិត្តទុកដាក់ទៅលើព័ត៌មានសំខាន់ៗ ទាក់ទងនឹងអារម្មណ៍ សុខភាព និងលទ្ធផលសិក្សារបស់សិស្ស ដែលជួយគ្រូក្នុងការវាយតម្លៃការសិក្សា។

ជាអ្នកជំរុញ៖ ការសរសើរលើកទឹកចិត្តសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ មានអាកប្បកិរិយាត្រឹមត្រូវក្នុង និងក្រៅថ្នាក់ជាកិច្ចការដ៏ធំធេងរបស់គ្រូបង្រៀន។ ទោះបីជាមានឧបសគ្គយ៉ាងណាក៏ដោយ គ្រូត្រូវតែប្រើវិធីដែលមានប្រសិទ្ធភាព ដើម្បីជួយដាស់ស្មារតី និងបំណងរបស់សិស្សឱ្យចូលរួមកាន់តែច្រើនក្នុងសកម្មភាពរៀនសូត្រ។ គ្រូបង្រៀនដែលពូកែ គឺតែងតែជាអ្នកពូកែជំរុញ លើកទឹកចិត្តសិស្សឱ្យស្តាប់ ចូលរួមសកម្មភាព និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាព។

ជាអ្នកដឹកនាំ៖ គ្រូបង្រៀនជាអ្នកបង្វឹក ជួយគាំទ្រអាស្រ័យទៅតាមតម្រូវការនៃស្ថានភាព។ អ្នកដឹកនាំតែងតែត្រូវបានគេមើលឃើញថា ជាមនុស្សដែលអាចទុកចិត្តបាន និងមានទំនួលខុសត្រូវ។ ដូច្នេះគ្រូបង្រៀនត្រូវតែបង្ហាញពីសក្តានុពល ភាពជាអ្នកដឹកនាំខ្ពស់បំផុត ដែលតួនាទីរបស់គាត់ ជាគ្រូបង្រៀនផង និងជាអ្នកដឹកនាំផង។

ជាគំរូល្អ៖ គ្រូបង្រៀន គឺជាគំរូ។ គាត់ធ្វើជាគំរូដល់សិស្ស និងមហាជនទូទៅ។ សិស្សគោរពគ្រូ ពួកគេជឿលើអ្វីដែលគ្រូនិយាយ ទង្វើរបស់គ្រូ សណ្ដានចិត្តល្អ សេចក្ដីអាណិតអាសូររបស់គ្រូ ជាអ្វីដែលសិស្សត្រូវការ។ ក្នុងនាមជាជនគំរូ ត្រូវមើលទៅលើអ្វីដែលជាចំណុចល្អ វិជ្ជមានគ្រប់ពេល ម្ចាស់ការលើមេរៀន បង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនចំពោះសុខមាលភាពរបស់សិស្ស បង្ហាញពីអាកប្បកិរិយាល្អ និងការងារល្អ ព្រមទាំងបណ្ដុះនូវឥរិយាបថល្អ ពិសេសការខិតខំព្យាយាមក្នុងការសិក្សារៀនសូត្រ។

ជាអ្នកជំនាញខាងទំនាក់ទំនងសង្គម៖ ភាពជឿជាក់របស់សាលារៀន ត្រូវបានសន្មតថាភាគច្រើនជាវិធីទំនាក់ទំនងរបស់គ្រូបង្រៀនជាមួយមនុស្សខាងក្រៅសាលាដូចជា សប្បុរសជនរបស់សាលា ឪពុក-ម្ដាយ អាណាព្យាបាលរបស់សិស្ស អាជ្ញាធរដែនដី ចាស់ព្រឹទ្ធាចារ្យ បុគ្គលិករដ្ឋាភិបាល អង្គការជាតិ អន្តរជាតិនានា។ ទំនាក់ទំនងល្អរបស់គ្រូបង្រៀន នឹងអាចកៀរគរប្រភពចំណូលហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍសាលា និងលើកកម្ពស់ការសិក្សារបស់សិស្ស កសាងកេរ្តិ៍ឈ្មោះសាលារៀនផងដែរ។

ជាឪពុក-ម្ដាយទី២៖ នៅក្នុងសាលារៀន គ្រូត្រូវបានគេចាត់ទុកជាឪពុក-ម្ដាយទី២របស់សិស្សគ្រប់គ្នា។ មុខងារដ៏សំខាន់របស់គ្រូ គឺអភិវឌ្ឍបញ្ញាស្មារតី និងថែរក្សាសុខមាលភាពផ្នែកចិត្តសាស្ត្ររបស់សិស្ស។ នៅសាលារៀន គ្រូបង្រៀនតែងតែយកចិត្តទុកដាក់លើតម្រូវការរបស់សិស្ស ផ្ដល់ភាពងាយស្រួល ជានានូវការគោរពសិទ្ធិបុគ្គលរបស់សិស្ស ចំពោះការអប់រំ និងសុវត្ថិភាពរបស់សិស្សដូចៗគ្នា។

អ្នកសម្របសម្រួល៖ គ្រូជាអ្នកសម្របសម្រួលចំពោះដំណើរការសិក្សារៀនសូត្រ និងរៀបចំនូវបរិស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព។ គ្រូបានដើរតួនាទីជាអ្នកចូលរួម និងសម្របសម្រួលក្នុងសកម្មភាពសិក្សា ការពិភាក្សា ជាអ្នកត្រួតពិនិត្យ និងវាយតម្លៃនៅក្នុង និងក្រៅថ្នាក់រៀន។ ជាងនេះទៅទៀត គ្រូជាអ្នកផ្ដល់ឱកាសឱ្យសិស្សពិភាក្សា បញ្ចេញយោបល់ដោយខ្លួនឯង ដោយគ្រូគ្រាន់តែជាអ្នកសម្របសម្រួល និងបំផុសគំនិតដល់សិស្ស។

អ្នកបង្រៀន៖ មុខងារដ៏សំខាន់របស់គ្រូ គឺការបង្រៀន។ តួនាទីផ្សេងៗទៀតដែលបានរៀបរាប់ខាងលើ គឺជាសកម្មភាពជួយឱ្យដំណើរការបង្រៀន និងរៀនកាន់តែមានភាពរលូន និងសម្រេចបាននូវលទ្ធផល

សិក្សាកាន់តែប្រសើរឡើង។ ដើម្បីអនុវត្តផ្នែកបង្រៀនឱ្យមានប្រសិទ្ធភាព គ្រូបង្រៀនត្រូវមានចំណេះដឹងជាមូលដ្ឋានចំនួន៧ តាមលោក Shulman 1987( Bennett & Carré, 1993 ) រួមមាន៖ ( ១ ) ចំណេះដឹងទៅលើខ្លឹមសារមេរៀន ឬមុខវិជ្ជាដែលត្រូវបង្រៀន ( ២ ) ចំណេះដឹងទូទៅពីគរុកោសល្យបង្រៀន ( ៣ ) ចំណេះដឹងពីកម្មវិធីសិក្សា ( ៤ ) ចំណេះដឹងផ្នែកខ្លឹមសារគរុកោសល្យ ( ៥ ) ចំណេះដឹងពីចរិតលក្ខណៈរបស់សិស្ស ( ចិត្តគរុកោសល្យ ) ( ៦ ) ចំនេះដឹងស្ដីពីបរិបទ និងនិន្នាការអប់រំក្នុងស្រុក តំបន់ និងពិភពលោក និង( ៧ ) ចំណេះដឹងស្ដីពីគោលបំណង គុណតម្លៃ ទស្សនវិជ្ជា និងប្រវត្តិនៃការអប់រំ។

## ២. ៤. ៣. ការប្រើប្រាស់សម្ភារឧបទេសសម្រាប់ការបង្រៀន

គុណភាពនៃការបង្រៀន គឺជាសមាសធាតុសំខាន់បំផុតក្នុងការបន្តនិរន្តរភាពរបស់សិស្សចំពោះការសិក្សា( Benveniste, Marshall, & Araujo, 2008 )។ ជាការពិត ដើម្បីឱ្យការបង្រៀនប្រកបដោយគុណភាព វាជាការងារមួយដែលមិនមានភាពងាយស្រួលនោះទេ គេត្រូវតែយល់ថា វាជាប្រព័ន្ធមួយដែលមានភាពស្មុគ្រស្មាញ ដូច្នេះយើងត្រូវផ្ដោតទៅលើរបៀបប្រើប្រាស់សម្ភារឧបទេស និងវិធីសាស្ត្រដែលលោកគ្រូ-អ្នកគ្រូបានប្រើប្រាស់ដើម្បីណែនាំសិស្ស តាមរយៈសកម្មភាពផ្សេងៗ។ ឧទាហរណ៍ លោកគ្រូ-អ្នកគ្រូតាមដានលើវឌ្ឍនភាពរបស់សិស្សតាមរបៀបណា នៅពេលប្រើប្រាស់សម្ភារឧបទេស ពិនិត្យមើលលើការដោះស្រាយបញ្ហាដោយប្រើប្រាស់សម្ភារឧបទេស វាយតម្លៃការសិក្សារបស់សិស្ស ព្រមទាំងវិធីសាស្ត្រ ដែលសម្ភារឧបទេសធ្វើឱ្យមានភាពប្រសើរឡើង។

ការប្រើប្រាស់សម្ភារឧបទេស នៅក្នុងដំណើរការបង្រៀន និងរៀន នឹងផ្ដល់ឱ្យសិស្សនូវបទពិសោធន៍ថ្មី ជាមួយនឹងការអនុវត្តរបស់ពួកគេ( Davis, 2009 )។ ការបង្រៀន និងរៀនដែលមានប្រសិទ្ធភាព ទាមទារឱ្យមានសម្ភារៈសិក្សាសមរម្យ និងមានភាពទូលំទូលាយ ស្ថានភាពបែបនេះទាមទារឱ្យមានការយកចិត្តទុកដាក់ និងគិតគូរពីគោលនយោបាយគ្រប់គ្រងផលិតកម្ម ការបែងចែកសៀវភៅសិក្សាគោលរួមទាំងសម្ភារៈសិក្សាដទៃទៀត ព្រមទាំងការបណ្ដុះបណ្ដាលគ្រូបង្រៀនស្ដីពី របៀបផលិត និងប្រើប្រាស់សម្ភារឧបទេសនៅក្នុងការបង្រៀនឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរថែមទៀត ដើម្បីឱ្យស្របទៅនឹងការអនុវត្តការបង្រៀនល្អ និងមានគុណភាព។

សម្ភារៈផ្សេងៗក្រៅពីសៀវភៅសិក្សាក៏មានសារៈសំខាន់ផងដែរ សម្រាប់ជំនួយ និងគាំទ្រដល់ការបង្រៀន ពេលខ្លះវាបានបន្ថែមទៅលើធនធានដែលមាននៅក្នុងថ្នាក់រៀនតិចតួច ជាពិសេសដោយមានការគាំទ្រពីមជ្ឈមណ្ឌលធនធានគ្រូបង្រៀន។ យោងតាមការសិក្សារបស់លោក(Giordano, 2008) បង្ហាញថាសាលារៀននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល ពិបាកផ្តល់ឱ្យការអប់រំប្រកបដោយគុណភាព ដោយសារតែហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់សម្រាប់ការអប់រំ ជាពិសេសគឺខ្វះខាតធនធាន និងសម្ភារៈឧបទេសសម្រាប់ការបង្រៀនរបស់គ្រូ និងសិស្សមិនគ្រប់គ្រាន់។ គ្រូបង្រៀន គឺទាមទារឱ្យអនុវត្តកម្មវិធីសិក្សា ដើម្បីឱ្យការផ្តល់ចំណេះដឹងដល់សិស្សមានប្រសិទ្ធភាព ត្រូវតែមានជំនួយពីការប្រើប្រាស់សម្ភារឧបទេសបន្ថែម។ ការកែច្នៃ ឬផលិតសម្ភារៈជំនួយបន្ថែមដល់ការបង្រៀនរបស់គ្រូ ដើម្បីជាការពង្រីកចំណេះដឹងដល់សិស្ស ហើយគ្រូជាអ្នកត្រួតពិនិត្យសកម្មភាពរបស់សិស្ស និងធ្វើការវាយតម្លៃនៅចុងបញ្ចប់នៃមេរៀន ត្រីមាស ឆមាស ឬមួយឆ្នាំសិក្សា(Kumar, 2017)។ គ្រូបង្រៀន និងសិស្សពឹងផ្អែកទៅលើសម្ភារឧបទេសដើម្បីយល់ច្បាស់ពីខ្លឹមសារ ឯសម្ភារឧបទេសគឺជាធាតុសំខាន់នៃការបង្រៀន។ ម្យ៉ាងវិញទៀត ការយល់ច្បាស់ពីវិធីសាស្ត្របង្រៀន ការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន ការច្នៃប្រឌិតសម្ភារៈសម្រាប់ថ្នាក់រៀនបានសមស្រប វាជាសំណុចសំខាន់បំផុតដែលគ្រូបង្រៀនត្រូវយកចិត្តទុកដាក់។ ប្រសិទ្ធភាពនៃសម្ភារឧបទេស រួមទាំងឆន្ទៈរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់វិធីសាស្ត្រ បច្ចេកវិទ្យាថ្មី ហើយមានការគាំទ្រលើកទឹកចិត្តដល់គ្រូបង្រៀន គួរតែជាផ្នែកមួយនៃការអភិវឌ្ឍសម្ភារៈបង្រៀន(Kumar, 2017)។

## ២. ៤. ៤. ការរៀបចំកិច្ចតែងការបង្រៀន

គុណភាពនៃការបង្រៀនរបស់គ្រូ ទាមទារឱ្យមាននូវលក្ខណៈពិសេសផ្សេងៗជាច្រើន ដែលគ្រូបង្រៀនត្រូវមានមុននឹងបង្រៀននៅក្នុងថ្នាក់(Killen, 2009)។ ការបង្រៀនដែលមានប្រសិទ្ធភាពទាមទារឱ្យគ្រូបង្រៀនគ្រប់រូបមានសមត្ថភាពក្នុងការផលិតសម្ភារៈជំនួយការបង្រៀន និងអនុវត្តវិធីសាស្ត្របង្រៀនបានសមស្រប រួមជាមួយនឹងបំណិនក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការបង្រៀនផងដែរ។

គ្រូបង្រៀនដែលមានប្រសិទ្ធភាព គឺមិនពឹងផ្អែកតែទៅលើការបើកសៀវភៅ និងបញ្ជូនព័ត៌មានទៅសិស្សនោះទេ ប៉ុន្តែពួកគេត្រូវរៀបចំមេរៀនមួយដ៏ល្អសម្រាប់សិស្សានុសិស្ស(វណ្ណី ២០១៩)។ ការរៀបចំ

មេរៀនមួយដ៏ល្អ ទាមទារឱ្យគ្រូបង្រៀនត្រូវតែជ្រើសរើស និងអភិវឌ្ឍមេរៀនមុនដំណើរការបង្រៀន រៀបចំកិច្ចតែងការសម្រាប់បង្រៀន រៀបចំសម្ភារឧបទេសសម្រាប់គោលបំណងនៃការបង្រៀន ការកំណត់នូវវិធីសាស្ត្របង្រៀន រៀបចំរបៀបគ្រប់គ្រងថ្នាក់រៀន រៀបចំផែនការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ គ្រូបង្រៀនដែលបានរៀបចំទុកជាមុននូវសកម្មភាពទាំងនេះ នឹងជួយឱ្យពួកគាត់អាចសម្រេចបាននូវប្រសិទ្ធភាពបង្រៀន និងរៀនទទួលបានលទ្ធផលល្អប្រសើរ។ ជាននេះទៅទៀត ការយកចិត្តទុកដាក់លើការងាររៀបចំកិច្ចតែងការបង្រៀនរបស់គ្រូ ជាកូនប្រយោជន៍ដល់ការបង្កើនប្រសិទ្ធភាពនៃការរៀនរបស់សិស្ស និងសម្រេចវត្ថុបំណាងមេរៀននីមួយៗផងដែរ។

យោងតាម John (2007) ការបង្រៀនដែលមានប្រសិទ្ធភាព វាមិនអាចកាត់ផ្តាច់បានពីការរៀបចំផែនការ ឬកិច្ចតែងការបង្រៀន មុនដំណើរការបង្រៀនបានទេ។ ហើយជាទូទៅ ការរៀបចំកិច្ចតែងការសម្រាប់បង្រៀនមួយដែលល្អ មានប្រសិទ្ធភាព និងគុណភាព ត្រូវរួមបញ្ចូលនូវព័ត៌មានសំខាន់ៗដូចជាៈ (១) គោលបំណង (២) វត្ថុបំណង និងលទ្ធផលសិក្សារំពឹងទុក (៣) ទិន្នន័យវាយតម្លៃលទ្ធផលសិស្ស (៤) វិសាលភាព និងខ្លឹមសារនៃការវាយតម្លៃ (៥) វិធីសាស្ត្រគរុកោសល្យ (៦) ការរំពឹងទុករបស់គ្រូបង្រៀន (៧) សកម្មភាពបង្រៀន និងរៀន(៨) កិច្ចការផ្ទះសម្រាប់សិស្ស (៩) ភាពផ្សេងៗគ្នានៃការរៀនរបស់សិស្ស (១០) ដំណើរការបង្រៀន និងរៀន (១១) ភាពទាក់ទងគ្នានៃកម្មវិធីសិក្សា (១២) ប្រភពព័ត៌មាន និងឯកសារពាក់ព័ន្ធ (១៣) បញ្ហាប្រឈម (១៤) ការវាយតម្លៃ (១៥) វិធីសាស្ត្រវាយតម្លៃ និង (១៦) ពិនិត្យឡើងវិញនូវដំណើរការទាំងអស់។

ម្យ៉ាងវិញទៀត Haynes (2010) ការបង្រៀនត្រូវបានត្រូវបានគិតថា ត្រូវបែងចែកជាបីដំណាក់កាលសំខាន់ៗគឺ (១) ការរៀបចំផែនការ និងការរៀបចំមុនដំណើរការបង្រៀន (២) សកម្មភាពក្នុងដំណាក់កាលង្រៀន និងរៀនដូចជាការគ្រប់គ្រងថ្នាក់រៀន ការបង្រៀន ការរៀន និង(៣) សកម្មភាពក្រោយបញ្ចប់មេរៀន មានសកម្មភាពវាយតម្លៃតាមដំណាក់កាល កំណត់ត្រានៃការវាយតម្លៃ របាយការណ៍វាយតម្លៃ និងការវាយតម្លៃលទ្ធផលសរុប។

## ២.៤.៥. លក្ខណៈសំខាន់ៗរបស់គ្រូបង្រៀន

គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ គឺធានាការអប់រំប្រកបដោយ គុណភាព បរិយាបន្ន និង សមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប(ក្រសួងអយក, 2019)។ ការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការស្វែងរកឧត្តមភាពនៅលើពិភពលោក បានជំរុញឱ្យប្រទេសនីមួយៗខិតខំធ្វើការប្រកួតប្រជែងផលិតផល និងសេវាកម្មរបស់ខ្លួន។ ធនធានមនុស្សជាកម្លាំងចលករក្នុងការសម្រេចនូវបំណងប្រាថ្នានេះ។ គ្រូបង្រៀនត្រូវបានគេទទួលស្គាល់ និងឱ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធនមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក(ក្រសួង អ.យ.ក ២០១៣)។ គ្រូបង្រៀន គឺចំណែកយ៉ាងសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើនគុណភាពអប់រំ ហើយគ្រូបង្រៀន ត្រូវតែមានសមត្ថភាពដែលអាចឱ្យសិស្សសាលារៀនសហគមន៍ទទួលស្គាល់តាមរយៈចំណេះដឹង ជំនាញ សីលធម៌ និងលក្ខណសម្បត្តិដែលជាតម្រូវការចាំបាច់សម្រាប់គ្រូបង្រៀនមានការប្រែប្រួលទៅតាមតម្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ និងបច្ចេកវិទ្យានៃសង្គមពុទ្ធិ។ ក្នុងន័យនេះអាចនិយាយបានថា ការភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន គឺជាបញ្ហាអាទិភាព និងស្មុគ្រស្មាញដែលមានមតិជជែកដេញដោលមិនចេះចប់។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានកិច្ចខិតខំប្រឹងប្រែងដាក់ចេញនូវក្របខណ្ឌ និងផែនការសកម្មភាព ស្តីពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា(ក្រសួង អ.យ.ក ២០១៩ក)។ យោងតាមក្របខណ្ឌខាលើនេះ វាជាឧបករណ៍មួយសម្រាប់កំណត់ឱ្យឃើញថាគ្រូបង្រៀន ត្រូវតែមានការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការគុណភាពអប់រំសម្រាប់ទាំងអស់គ្នានាពេលបច្ចុប្បន្ន និងអនាគត។ បើយោងតាម(Gregory, 2004) គ្រូបង្រៀនម្នាក់ៗត្រូវមានការយល់ដឹងពីច្បាប់គ្រូមួយចំនួនៈ (១) ជាអ្នកមានចំណេះដឹងពេញលេញ រួមមានចំណេះដឹងទូទៅ ចំណេះដឹងជំនាញឯកទេស និងចំណេះដឹងផ្នែកគរុកោសល្យ(ចិត្តគរុកោសល្យ និងវិធីសាស្ត្របង្រៀន)។ (២) ជាអ្នកមានចំណេះដឹងវាងវៃចំពោះការចាប់អារម្មណ៍របស់សិស្ស និងចូលរួមការងារជាមួយគ្នានៅក្នុងការប្រតិបត្តិការបង្រៀន។ (៣) មានគំនិតទូលំទូលាយ និងជឿជាក់ថាសិស្សគ្រប់រូបមានសមត្ថភាពរៀនសូត្រ ចាប់យក

ចំណេះដឹងថ្មីៗបានពេញលេញដោយខ្លួនឯង។ (៤) ជាអ្នកចាប់អារម្មណ៍លើខ្លួនឯងក្នុងផ្លូវវិជ្ជមាន ដែលនាំទៅរកទស្សនវិជ្ជាល្អជាមួយអ្នកដទៃ ក៏ដូចជាចំពោះសិស្សគ្រប់រូប។ (៥) មានជំនឿលើខ្លួនឯង ថាអាចជួយជ្រោមជ្រែងសិស្ស ឱ្យមាសមត្ថភាពខ្ពស់តាមដែលអាចធ្វើទៅបាន នៅក្នុងការសិក្សារៀនសូត្រ។ (៦) ស្គាល់ពីប្រភពគំនិតផ្សេងៗ និងទ្រឹស្តីប្រើក្នុងការរៀន និងបង្រៀនសិស្ស។ (៧) ត្រូវតែរំឭក ម្តងហើយម្តងទៀត នូវអ្វីដែលត្រឹមត្រូវ ដោយបំផុសការគិតបែបស៊ីជម្រៅដល់សិស្ស កែតម្រូវនូវរាល់ឥរិយាបថដែលមិនត្រឹមត្រូវ និងបង្ហាញផ្លូវដែលត្រឹមត្រូវ។

## ២. ៥. សមត្ថភាពគរុកោសល្យក្នុងការបង្រៀន

ការអនុវត្តកម្មវិធីសិក្សា គឺជាកង្វល់មួយសម្រាប់លោកគ្រូ-អ្នកគ្រូជាច្រើនដែលកំពុងបង្រៀននៅក្នុងសាលារដ្ឋ ក៏ដូចជាសាលាឯកជន។ ការយល់ច្បាស់ពីបញ្ហា ក្នុងការអនុវត្តកម្មវិធីសិក្សា និងយុទ្ធសាស្ត្រពាក់ព័ន្ធនានា វាជាលទ្ធផលដ៏ល្អនៅក្នុងការផ្តល់បទពិសោធន៍ និងជំរុញឱ្យមានគុណភាពនៅក្នុងដំណើរការងារបង្រៀន និងការរៀន។ បទពិសោធន៍ និងមេរៀនដែលទទួលបានពីការស្រាវជ្រាវជាច្រើន រួមទាំងឯកសារដ៏សំខាន់នេះ បានបង្ហាញថាមានលក្ខណៈផ្សេងៗពីគ្នា ដែលវាក្លាយជាប្រភពដ៏ចំបងក្នុងការពង្រឹងការសិក្សាស្រាវជ្រាវឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីចង្អុលបង្ហាញថានេះ ជាប្រធានបទដ៏ល្អមួយ ដែលការសិក្សាស្រាវជ្រាវស្រដៀងគ្នាជាច្រើនបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះ គឺដោយសារតែកង្វះជំនាញក្នុងការគ្រប់គ្រង និងចំណេះដឹងដែលចាំបាច់សម្រាប់ការអនុវត្តកម្មវិធីសិក្សាថ្មី(Ornstein & Hunkins, 2018)។

គុណភាពអប់រំ គឺសំដៅដល់សមត្ថភាពរបស់សិស្ស ឬនិស្សិតជាមធ្យម នៅពេលដែលពួកគេបញ្ចប់ការសិក្សាតាមកម្រិតថ្នាក់ ឬទទួលសញ្ញាបត្រនោះក្នុងបរិបទជាក់ស្តែង (១) សំដៅទៅលើការប្រើប្រាស់ធាតុចូលដូចជា ចំនួនគ្រូបង្រៀន ចំនួនគ្រូដែលបណ្តុះបណ្តាល ចំនួនសៀវភៅសិក្សា (២) ដំណើរការអនុវត្តរួមមាន ចំនួនម៉ោងបង្រៀនផ្ទាល់ សកម្មភាពសិក្សា (៣) ធាតុចេញមានដូចជា លទ្ធផលធ្វើតេស្ត អត្រាបញ្ចប់ការសិក្សា (៤) លទ្ធផលសិក្សា ដែលស្តែងចេញតាមរយៈសមត្ថភាពបំពេញការងារ(Chapman & Adams, 2002 )។ មូលហេតុដែលនាំឱ្យការអប់រំពុំមានគុណភាពអប់រំ វាអាចមានកត្តាជាច្រើនដូចជា

ធនធានមនុស្សរបស់គ្រឹះស្ថានសិក្សា(គ្រូបង្រៀន) ធនធានសម្ភារៈដែលបម្រើឱ្យការបង្រៀន ការសិក្សាស្រាវជ្រាវ និងការរៀនសូត្រមិនគ្រប់គ្រាន់ និងកត្តាសិស្ស និស្សិតខ្លួនឯង ដែលខ្វះខាតផ្នែកជីវភាព ខ្វះការប្រកួតប្រជែងក្នុងទីផ្សារការងារ(Hang-Chuon, 2018)។ ការបង្កើនគុណភាពអប់រំ នៅកម្រិតមធ្យមសិក្សាចំណេះទូទៅឱ្យបំពេញបាននូវស្តង់ដាអប្បបរមា ដែលជាគម្រោងបង្កើនគុណភាពអប់រំមធ្យមសិក្សា (Secondary Education Improvement Project/SEIP) ដែលមានការគាំទ្រហិរញ្ញវត្ថុពីធនាគារពិភពលោក។ គោលបំណងរបស់គម្រោង គឺជួយពង្រឹងការគ្រប់គ្រងសាលារៀន បង្កើនគុណភាពនៃការបង្រៀន និងការរៀននៅតាមកម្រិតថ្នាក់ តាមរយៈការបង្កើនគុណវុឌ្ឍិរបស់គ្រូបង្រៀន ផ្តល់ការប្រឹក្សាណែនាំ និងធ្វើការវាយតម្លៃត្រឹមត្រូវលើសមត្ថភាពរបស់គ្រូបង្រៀន ព្រមទាំងធ្វើឱ្យរចនាសម្ព័ន្ធទ្រទ្រង់ការបង្រៀនកាន់តែមានភាពប្រសើរជាង។

តាមការសិក្សាស្រាវជ្រាវរបស់ Grisay and Mählck (1991) បានបង្ហាញថា សញ្ញាណនៃការអប់រំប្រកបដោយគុណភាព គួរតែស្ថិតនៅក្រោយលទ្ធផលនៃការសិក្សារបស់សិស្ស ហើយពិនិត្យមើលកត្តាកំណត់នូវលទ្ធផលទាំងនោះរួមមាន ការបណ្តុះបណ្តាលគ្រូបង្រៀន អគារសិក្សា សម្ភារឧបទេសបង្រៀន និងរៀន និងកម្មវិធីសិក្សា។ តាមការអះអាងនេះ គុណភាពនៃការអប់រំរួមមានកត្តាកំណត់ចំនួនបីគឺៈ (១) គុណភាពមនុស្សរបស់គ្រឹះស្ថានសិក្សា (២) ធនធានសម្ភារៈសម្រាប់ការបង្រៀន និងការរៀន គឺគុណភាពនៃដំណើរការបង្រៀន និង(៣) ផលដែលសម្រេចបាន(ទិន្នផល និងលទ្ធផល)។

ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកទទួលបន្ទុកវិស័យអប់រំ បានកំណត់ដាក់លាក់នូវកម្មវិធីសិក្សាគោលសម្រាប់ការអប់រំចំណេះទូទៅ ដែលមានលក្ខណៈជាកាតព្វកិច្ច សម្រាប់អនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា(ក្រសួង អ.យ.ក ២០១៨ខ)។ ស្របពេលនេះដែរ ដំណើរការអនុវត្តកម្មវិធីសិក្សា នៅតែមានបញ្ហាខ្វះចន្លោះ ដោយសាលារៀនត្រូវដោះស្រាយបញ្ហាប្រឈមមួយចំនួនដូចជា ការបាត់បង់ពេលវេលាក្នុងការបង្រៀន និងរៀន គ្រូបង្រៀនមិនបានបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀន និងការប្រើប្រាស់កម្មវិធីសិក្សា សៀវភៅសិក្សាគោល គ្រូបង្រៀនគ្មានកម្មវិធីសិក្សា

និងមិនបានសិក្សាស្រាវជ្រាវ ឯកសារបន្ថែមសម្រាប់បង្រៀន មិនបានប្រើប្រាស់សម្ភារឧបទេស ឱ្យឆ្លើយតបតម្រូវការរបស់គ្រូ ជាបុព្វហេតុនៃការអនុវត្តកម្មវិធីសិក្សាមិនបានពេញលេញ(ក្រសួង អ.យ.ក ២០១៨ខ)។

## ២. ៦. ការបណ្តុះបណ្តាល និងការពង្រាយគ្រូ

### ២. ៦. ១. ការបណ្តុះបណ្តាល

គ្រូបង្រៀន គឺជាកត្តាជំរុញគន្លឹះមួយនៅក្នុងការលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែល្អប្រសើរ។ គ្រូបង្រៀន គឺជាធាតុចូលដ៏សំខាន់បំផុតដើម្បីធានាបាននូវគុណភាពនៃការអប់រំ ហើយការអប់រំដែលមានគុណភាព គឺជាគុណភាពរបស់គ្រូបង្រៀន និងគុណភាពរបស់នាយកសាលា(Hang-Chuon, 2018)។ នៅក្នុងន័យនេះហើយ ការធ្វើកំណែទម្រង់គ្រូបង្រៀនរបស់ក្រសួងអប់រំ ត្រូវបានដាក់ចេញតាមរយៈគោលនយោបាយ ស្តីពី គ្រូបង្រៀន និងផែនការសកម្មភាពនាឆ្នាំ២០១៥។ ការបណ្តុះបណ្តាលគ្រូបង្រៀនថ្មី និងរិក្រឹតការគ្រូបង្រៀនដែលមានស្រាប់ វាគឺជាវិភាគទានដ៏សំខាន់ដែលមិនអាចខ្វះបានដើម្បីសម្រេចបាននូវគុណភាពគ្រូបង្រៀន។ លើសពីនេះទៅទៀត ការធ្វើកំណែទម្រង់គោលនយោបាយ ស្តីពីគ្រូបង្រៀនកាន់តែមានសារៈសំខាន់ ដើម្បីឆ្ពោះទៅការអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត ហើយការធ្វើកំណែទម្រង់នេះវានឹងជះផលវិជ្ជមានទៅដល់គុណភាពអប់រំ និងលទ្ធផលសិក្សារបស់សិស្ស(Vision, 2017)។

ការបណ្តុះបណ្តាលគ្រូបង្រៀន អាចមានទម្រង់ផ្សេងៗពីគ្នាជាច្រើន រយៈពេលនៃការបណ្តុះបណ្តាល គោលដៅសំខាន់នៃកម្មវិធីសិក្សាដែលបានដាក់ចេញ និងទិដ្ឋភាពដទៃទៀតមានភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ ប៉ុន្តែការបណ្តុះបណ្តាលគ្រូបង្រៀនទាំងនោះ មានគោលដៅរួមមិនខុសគ្នានោះទេ គឺដើម្បីបង្កើននូវគុណភាពនៃការអប់រំ ហើយការបណ្តុះបណ្តាលគ្រូបង្រៀននេះ តំណាងឱ្យការវិនិយោគដ៏ច្រើនបំផុតក្នុងថវិកាសាធារណៈ។ ជាងនេះទៅទៀត នៅបណ្តាប្រទេសឧស្សាហកម្មខ្លះ ត្រូវប្រឈមនឹងកម្លាំងគ្រូបង្រៀន កាន់តែចាស់ទៅៗ នឹងខ្វះខាតធនធានមនុស្សដែលចាប់អារម្មណ៍នឹងអាជីពគ្រូបង្រៀន(Gasperini, 2000)។

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍគ្រូបង្រៀន លើកកម្ពស់គុណភាពអប់រំ និងគុណតម្លៃគ្រូបង្រៀនដូច

ជាគោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន ស្តង់ដានាយកសាលារៀន ស្តង់ដាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន(ក្រសួង អ.យ.ក ២០១៨)។ សមិទ្ធផលទាំងនេះ កើតចេញដោយមើលឃើញថា គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ជាកម្លាំងចលករជួរមុខមិនអាចខ្វះបាន ក្នុងការផលិតមូលធនមនុស្ស ដែលជាកម្លាំងពលកម្មយ៉ាងសកម្ម និងមានផលិតភាពសេដ្ឋកិច្ចខ្ពស់ សម្រាប់ធានាបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព(ក្រសួង អ.យ.ក ២០១៣)។

### ២. ៦. ២. ការពង្រាយគ្រូ

យោងទៅតាម McKinsey (2007) គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់នូវលទ្ធផលសិក្សារបស់សិស្ស។ ហើយកត្តាសំខាន់ៗចំនួន ៣ ដែលកំណត់ពីបានពីភាពជោគជ័យរបស់សាលារៀនគឺៈ (១) ជ្រើសរើសគ្រូដែលមានសមត្ថភាពឱ្យបំពេញការងារបានត្រឹមត្រូវ (២) រៀបចំនូវប្រព័ន្ធផ្តល់ប្រាក់ខែសមរម្យបានទៀងទាត់ (៣) បណ្តុះបណ្តាលគ្រូបង្រៀនឱ្យក្លាយជាអ្នកអប់រំដែលមានសក្តានុពល និងមានប្រសិទ្ធភាព។ ក្រៅពីលក្ខណៈសម្បត្តិ និងការបណ្តុះបណ្តាល ការដាក់ពង្រាយគ្រូបង្រៀន គឺជាកត្តាគោលនយោបាយដ៏សំខាន់ដែលជួយកំណត់អំពីគុណភាពនៃការអប់រំដែលសិស្សានុសិស្សត្រូវទទួលបាន។ នៅកម្រិតសាលារៀន សមាសធាតុដែលអាចមើលឃើញច្បាស់បំផុតនៃការដាក់ពង្រាយគ្រូបង្រៀន គឺទំហំថ្នាក់រៀន ចំនួនសិស្សដែលគ្រូត្រូវបង្រៀន ចំនួនម៉ោងបង្រៀនរបស់គ្រូ ក្នុងខណៈដែលឥទ្ធិពលនៃទំហំថ្នាក់រៀន ទៅលើលទ្ធផលនៃការអប់រំជាបញ្ហាមួយដែលត្រូវពិភាក្សា(Vision, 2017)។

សាលារៀន ថ្នាក់រៀន គឺជាផ្នែកមួយដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវគុណភាពអប់រំដែលរួមបញ្ចូលទាំងកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ បរិស្ថានរៀនសូត្ររបស់សិស្ស-គ្រូ តម្លាភាពក្នុងការវាយតម្លៃក្នុងដំណើរការ និងចុងបញ្ចប់នៃការសិក្សា ការធ្វើតេស្តសមត្ថភាព និងការប្រឡង ភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន ការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ អនាម័យ និងសុខភាពសិក្សា(Hang-Chuon, 2018)។

ការកែលំអរគុណភាពនៃការអប់រំ ទាំងការរៀន និងការបង្រៀន ពង្រឹងការគ្រប់គ្រងគ្រូ ការពង្រាយគ្រូ និងយន្តការផ្ទេរគ្រូ ការរៀបចំមាគ៌ាអាជីពគ្រូ ដើម្បីឈានទៅរកការអភិវឌ្ឍផ្នែកវិជ្ជាជីវៈ និងបន្តការវិវត្តអាជីពជាគ្រូ ត្រូវបានធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូទៅថ្នាក់ក្រោមៗដោយក្រសួងអប់រំ (ក្រសួង អ.យ.ក ២០១៥)។ ការពង្រាយគ្រូ ជាចំណុចស្នូលមួយក្នុងចំណោមយុទ្ធសាស្ត្រកំណែទម្រង់ទាំង ១៥ ចំណុចដែលបានដាក់ចេញដោយក្រសួងអប់រំតាំងពីឆ្នាំ២០១៥។ តាមរយៈយុទ្ធសាស្ត្រកំណែទម្រង់ខាងលើ គឺដើម្បីធានានូវបរិស្ថានការងារ និងលក្ខខណ្ឌរស់នៅរបស់គ្រូបង្រៀនឱ្យកាន់តែល្អប្រសើរតាមរយៈការផ្តល់នូវប្រាក់ឧបត្ថម្ភអត្ថប្រយោជន៍ផ្សេងៗ សម្រាប់គ្រូបង្រៀនណាដែលស្ម័គ្រចិត្តទៅបម្រើការងារនៅតាមតំបន់ជនបទ និងតំបន់ជួបការលំបាក(Hang-Chuon, 2018)។

យោងតាម NEP (២០១៥) បានលើកឡើងថា ក្រសួងអប់រំ ចាំបាច់ត្រូវបន្តផ្តល់អាទិភាពដល់វិធានការស្តីពីការជ្រើសរើស និងការពង្រាយគ្រូបង្រៀន ក្នុងគោលបំណងធ្វើឱ្យមានលទ្ធភាពពង្រឹងការងារគ្រប់គ្រងបុគ្គលិកអប់រំឱ្យកាន់តែរឹងមាំ ដើម្បីជៀសផុតពីការខ្វះគ្រូបង្រៀនកាន់តែច្រើនឡើង។ ហើយវាក៏ជាមូលហេតុដែលនាំទៅដល់ការបាត់បង់ម៉ោងបង្រៀន ដោយសារតែខ្វះគ្រូ និងជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់គុណភាពនៃការសិក្សារបស់សិស្ស។

យោងតាម No and Sokcheng (2018) ដៃគូអភិវឌ្ឍន៍ផ្សេងគ្នា(DPs) អង្គការក្រៅរដ្ឋាភិបាល (NGOs) បានផ្តល់នូវអនុសាសន៍ និងគោលនយោបាយផ្សេងៗគ្នាដើម្បីដោះស្រាយបញ្ហាស្តីពីការពង្រាយគ្រូបង្រៀន។ ធនាគារពិភពលោក បានផ្តល់អនុសាសន៍លើគោលនយោបាយផ្លាស់ប្តូរទីតាំងបម្រើការងាររបស់គ្រូបង្រៀនទៅក្រសួងអប់រំ យុវជន និងកីឡា ដែលជំរុញឱ្យមានអតិរេកគ្រូបង្រៀនត្រូវបានដាក់ឱ្យទៅសាលារៀនដែលនៅជិតបំផុតដែលខ្វះគ្រូ។ ការសិក្សារបស់ធនាគារពិភពលោកបានរកឃើញថា ៤៣ ភាគរយនៃសាលាបឋមសិក្សា និង ២៨ ភាគរយនៃមធ្យមសិក្សាដែលខ្វះគ្រូ គឺស្ថិតនៅចម្ងាយ ៥ គីឡូម៉ែត្រពីសាលារៀនដែលនៅជិតបំផុតដោយមានអតិរេក។ ស្រដៀងគ្នានេះផងដែរ លទ្ធផលនៃការស្រាវជ្រាវថ្មីៗនេះរបស់ NEP បានស្នើអនុសាសន៍គោលនយោបាយចំនួន ៥ រួមមាន៖

(១) បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានដើម្បីកំណត់តំបន់និងសាលារៀនដែលខ្វះគ្រូ

(២) ពិនិត្យឡើងវិញនូវប្រព័ន្ធបច្ចុប្បន្នដើម្បីបែងចែកគ្រូថ្មីទៅតាមខេត្ត និងសាលារៀនដែលខ្វះគ្រូ

(៣) ប្រើនិងលើកកម្ពស់ការប្តូរទីតាំងគ្រូទៅសាលារៀនដោយខ្វះគ្រូ

(៤) ពិនិត្យឡើងវិញនូវការលើកទឹកចិត្តគ្រូបង្រៀននាពេលបច្ចុប្បន្ន សម្រាប់គ្រូកំពុងបម្រើការងារ

(៥) បណ្តុះបណ្តាលគ្រូកិច្ចសន្យាឱ្យក្លាយជាគ្រូដែលមានសមត្ថភាពពេញលេញ (Conochie, Ang, & Anderson, 2017)។

## ២. ៧. ការកែលម្អគុណភាពអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកតាមក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មានមហិច្ឆិតាអភិវឌ្ឍធនធានមនុស្សដើម្បីប្រែក្លាយប្រទេសកម្ពុជាពីប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០(Hang-Chuon, 2018)។ ក្រសួងអប់រំ បានដាក់ចេញនូវបញ្ហាប្រឈមមួយចំនួនដែលត្រូវធ្វើកំណែទម្រង់ជាចាំបាច់ (១) ការគ្រប់គ្រងបុគ្គលិកអប់រំ ជំរុញការចូលរួមបំពេញការងាររបស់គ្រូបង្រៀននៅតាមតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក និងការផ្តល់ការលើកទឹកចិត្តគ្រូបង្រៀនតាមរយៈអត្ថប្រយោជន៍ផ្សេងៗដល់គ្រូបង្រៀន។ (២) កែទម្រង់ការប្រឡងគ្រប់ប្រភេទ ដើម្បីលុបបំបាត់នូវអំពើពុករលួយក្នុងដំណើរការប្រឡង ដែលនាំឱ្យបាត់ទំនុកចិត្តលើគុណភាពអប់រំ។ (៣) គុណភាពអប់រំសម្រាប់ទាំងអស់គ្នា មិនទាន់បានឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍប្រទេសជាតិនៅឡើយ។ (៤) កម្លាំងពលកម្មជំនាញរបស់ប្រទេសកម្ពុជា មិនឆ្លើយតបនឹងតម្រូវការទីផ្សារការងារ ខណៈដែលនិស្សិតបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យមិនមានជំនាញស្របតាមទីផ្សារការងារ។

គុណភាព គឺជាបេះដូងនៃការអប់រំ ជាអ្វីដែលកើតឡើងនៅក្នុងថ្នាក់រៀន និងបរិស្ថានសិក្សាដទៃទៀត និងជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់ដើម្បីអនាគតល្អរបស់កុមារ យុវជន និងមនុស្សពេញវ័យ។ គុណភាពអប់រំ គឺជាការបំពេញនូវតម្រូវការសិក្សាជាមូលដ្ឋាន និងជួយឱ្យជីវិតអ្នកសិក្សាទទួលបាននូវបទពិសោធន៍ពេញលេញ សម្រាប់ការរស់នៅរបស់ពួកគេនាពេលអនាគត។ ជាមួយគ្នានេះដែរ កម្មវិធីសិក្សាជាផ្នែកមួយរួមចំណែកអភិវឌ្ឍសមត្ថភាពរបស់សិស្ស និងគុណភាពអប់រំ។ ដើម្បីឱ្យកម្មវិធីអប់រំទទួលបាន

ភាពជោគជ័យនោះទាមទារឱ្យមាននូវសមាសធាតុសំខាន់៖ (១) សុខភាពសិក្សា អាហារូបត្ថម្ភ និងការលើកទឹកចិត្តសិស្ស (២) គ្រូបង្រៀនដែលទទួលការបណ្តុះបណ្តាលបានល្អ និងមានបច្ចេកទេសបង្រៀនរស់រវើកគ្រប់ស្ថានភាព (៣) សម្ភារៈរូបវន្ត និងសម្ភារសិក្សាគ្រប់គ្រាន់ (៤) កម្មវិធីសិក្សាសមស្រប ដែលអាចបង្រៀន និងកសាងចំណេះដឹង បទពិសោធន៍របស់គ្រូ និងអ្នកសិក្សា (៥) បរិស្ថានសិក្សា សម្រាប់សិស្សគ្រប់រូប គ្រប់ស្ថានភាពទទួលបាននូវឱកាសដូចៗគ្នា រួមបញ្ចូលទាំងយេនឌ័រ សុខភាព និងសុវត្ថិភាព (៦) ភាពច្បាស់លាស់នៃការវាយតម្លៃការសិក្សា រួមមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា (៧) ប្រសិទ្ធភាពនៃការងារដឹកនាំ គ្រប់គ្រង និង (៨) ទំនាក់ទំនងល្អ មានការចូលរួមពីភាគីពាក់ព័ន្ធ និងសហគមន៍(UNICEF, 2015)។

គុណភាពនៃការអប់រំ គឺជាការវាយតម្លៃទៅលើដំណើរការអប់រំ ដែលបានលើកកម្ពស់ពីលទ្ធផលនៃតម្រូវការ និងបានអភិវឌ្ឍបញ្ញាស្មារតី ទេពកោសល្យរបស់អ្នកសិក្សា ហើយស្របទៅនឹងស្តង់ដាមួយដែលអ្នកសិក្សាចង់បាន ដែលបានចំណាយពេលវេលានៅក្នុងដំណើរការសិក្សា(Hoy et al., 1999)។ ហើយការបង្រៀនប្រកបដោយគុណភាព គឺផ្តោតជាសំខាន់ទៅលើសកម្មភាពបង្រៀនរបស់គ្រូ និងសកម្មភាពរៀនរបស់សិស្សយ៉ាងសកម្ម ដូចជាសិស្សមានទំនាក់ទំនងយ៉ាងដូចម្តេចនៅក្នុងថ្នាក់រៀន ហើយគ្រូបង្រៀន និងសិស្សបានប្រើប្រាស់សម្ភាររៀន និងបង្រៀនមានប្រសិទ្ធភាពកម្រិតណា។ ដូចនេះ គោលនយោបាយសម្រាប់លើកកម្ពស់សកម្មភាពបង្រៀន និងរៀនដើម្បីធានាគុណភាពអប់រំឱ្យកាន់តែប្រសើរត្រូវតែផ្តោតលើសំខាន់ទៅលើកត្តាផ្សេងៗ យោងតាម(Chapman & Adams, 2002 )៖

(១) គ្រូបង្រៀន៖ ដើម្បីសម្រេចនូវសកម្មភាពអប់រំ ទាមទារឱ្យមានគ្រូបង្រៀនកាន់តែច្រើន និងពោរពេញដោយសមត្ថភាព។ ជាក់ស្តែងនៅតាមបណ្តាប្រទេសដែលទទួលបានជោគជ័យលើវិស័យអប់រំពិតជាបានវិនិយោគយ៉ាងច្រើនក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ប៉ុន្តែផ្ទុយទៅវិញនៅប្រទេសជាច្រើននារយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ប្រាក់បៀវត្សរបស់គ្រូបង្រៀនបានធ្លាក់ចុះបើប្រៀបធៀបទៅនឹងអាជីពផ្សេងៗ ហើយប្រាក់បៀវត្សទាបមិនអាចទ្រទ្រង់ជីវភាពគ្រូបង្រៀនបានសមរម្យនោះទេ។ ហេតុនេះ

នៅប្រទេសជាច្រើនការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវពិចារណាឡើងវិញ ត្រូវពង្រឹងការបណ្តុះបណ្តាល និងបំប៉នគ្រូនៅតាមសាលា ហើយត្រូវកាត់បន្ថយការបណ្តុះបណ្តាលតាមបែបចាស់ ដោយជំនួសមកវិញនូវវិធីសាស្ត្រថ្មីៗ ការសិក្សាស្រាវជ្រាវ បច្ចេកវិទ្យា នវានុវត្តន៍នៅក្នុងការអប់រំជាដើម។

(២) ដំណើរការបង្រៀន៖ ពេលវេលាបង្រៀន គឺជាកត្តាជួយសម្រេចជោគជ័យក្នុងការសិក្សា ដូចជារយៈពេលបង្រៀនក្នុងមួយម៉ោងសិក្សា ចំនួនម៉ោងបង្រៀនក្នុងមួយឆ្នាំសិក្សា។ វិសាលភាពនៃដំណើរការបង្រៀនរបស់គ្រូនៅក្នុងថ្នាក់រៀន និងសកម្មភាពរៀនរបស់សិស្សយ៉ាងសកម្ម បានជះឥទ្ធិពលជាវិជ្ជមានដល់ការរៀនរបស់សិស្ស។

(៣) តេស្តសមត្ថភាពរបស់សិស្ស៖ ការធ្វើតេស្តលើសមត្ថភាពរបស់សិស្សក្នុងដំណើរការរៀន និងបង្រៀន និងក្រោយបញ្ចប់វគ្គសិក្សា នឹងអាចជួយឱ្យគ្រូអាចកែលម្អនូវវិធីសាស្ត្របង្រៀនរបស់ខ្លួន វិធីសាស្ត្រការជួសិស្សក្នុងការរៀនសូត្រឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន។ ចំណែកឯសិស្សនឹងអាចស្វែងយល់ពីវិធីឬរបៀបរៀនសូត្ររបស់ពួកគេ ធ្វើបែបណាឱ្យទទួលបានលទ្ធផលល្អប្រសើរ។

(៤) គរុកោសល្យ៖ វិធីសាស្ត្របង្រៀនជាច្រើនត្រូវបានប្រើប្រាស់ជាទូទៅ ប៉ុន្តែមិនសម្រេចគោលបំណង និងតម្រូវចិត្តសិស្សនោះទេ ដោយសារតែវិធីសាស្ត្រទាំងនោះមិនមានភាពបត់បែនទន់ភ្លន់ ហើយតម្រូវឱ្យសិស្សទន្ទេញចាំមាត់ ដែលធ្វើឱ្យសិស្សរៀនតាមបែបអសកម្ម។ បច្ចុប្បន្នវិធីសាស្ត្របង្រៀនថ្មីៗជាច្រើនត្រូវបានអ្នកសិក្សាស្រាវជ្រាវអប់រំ គាំទ្រឱ្យប្រើប្រាស់ក្នុងការបង្រៀនប្រកបដោយរចនាសម្ព័ន្ធ ដែលគ្រូបង្រៀនជាអ្នកណែនាំ សម្របសម្រួលឱ្យសិស្សអនុវត្ត និងសិស្សរៀនដោយខ្លួនឯងក្នុងបរិយាកាសបង្រៀនសិស្សដោយមេត្រីភាព និងឯករាជ្យភាពក្នុងការចោទសួរ សិក្សាស្រាវជ្រាវ និងសន្និដ្ឋានដោយសិស្ស។

(៥) សម្ភារៈបរិក្ខាសាលារៀន៖ ដើម្បីសម្រេចគោលដៅអប់រំជាសកល កត្តាសំខាន់ត្រូវរៀបចំឱ្យសាលារៀនក្លាយជាសាលាកុមារមេត្រី តាមរយៈការរៀបចំបរិស្ថានទាំងក្នុង និងក្រៅសាលារៀន ការតុបតែងបន្ទប់ ឬថ្នាក់រៀនឱ្យបានស្អាត ក៏ដូចជាការៀបចំប្រព័ន្ធទឹកស្អាត បង្គន់អនាម័យដែលអាចឱ្យសិស្សប្រើប្រាស់ប្រកបដោយផាសុខភាព និងចាត់ទុកសាលារៀនគឺជាផ្ទះរបស់ពួកគេ។

(៦) ការដឹកនាំគ្រប់គ្រង៖ ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាមន្ទីរអប់រំ តាមបណ្តារាជធានីខេត្តត្រូវតែត្រៀមខ្លួនជាស្រេច ក្នុងការធានាដល់សេរីភាពក្នុងការចូលរៀនរបស់សិស្ស ដូចនេះត្រូវមានធនធានគ្រប់គ្រាន់ មានភារកិច្ចច្បាស់លាស់ និងកាទទួលខុសត្រូវនៅគ្រប់កម្រិតដឹកនាំទាំងអស់ ក្នុងគោលបំណងធានាឱ្យការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូទទួលបានភាពជោគជ័យ។

## ២. ៨. វិធីសាស្រ្តបង្រៀន

គ្រូបង្រៀនមានប្រសិទ្ធភាពដូចគ្នាទៅនឹងសម្ភារឧបទេសបង្រៀនរបស់គាត់ក្នុងការបង្រៀន ដែលវាជះឥទ្ធិពលដល់ចំណេះដឹង និងជំនាញរបស់សិស្ស។ វិធីសាស្រ្តដែលគ្រូបានអនុវត្ត(ឬមិនអនុវត្ត) ធ្វើឱ្យមានភាពខុសគ្នារវាងគ្រូល្អ និងគ្រូមិនល្អ។ ចងចាំថាគ្រូមិនល្អនឹងត្អូញត្អែរអំពីសម្ភារឧបទេសទាំងនោះ។ ប៉ុន្តែគ្រូល្អម្នាក់នឹងធ្វើឱ្យគ្រប់ស្ថានភាពរៀនសូត្រក្លាយជាបទពិសោធន៍នៃការរៀនសូត្រដោយមាន ឬគ្មានការផ្តល់ឧបករណ៍គ្រប់គ្រាន់(Olayide, 2015)

អ្វីដែលកំពុងកើតឡើងនៅក្នុងថ្នាក់រៀន ឥទ្ធិពលរបស់គ្រូបង្រៀន និងការបង្រៀនត្រូវបានលើកឡើងនៅក្នុងការសិក្សាស្រាវជ្រាវជាច្រើន ដែលវាជាធាតុចូលយ៉ាងសំខាន់សម្រាប់បង្កើនលទ្ធផលសិក្សារបស់សសិស្ស។ វិធីសាស្រ្តបង្រៀនរបសគ្រូ គឺជាអ្វីដែលត្រូវតែយកចិត្តទុកដាក់ ជាពិសេសនៅក្នុងកំណែទម្រង់ដែលសំដៅទៅដល់ការលើកកម្ពស់គុណភាពបង្រៀន។

ដំណើរការផ្លាស់ប្តូរ និងការវិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងចរន្តសកលភាវូបនីយកម្ម ដើម្បីឱ្យយុវជនក្លាយជាអ្នកសិក្សាពេញមួយជីវិត គឺត្រូវតែរំពឹង និងទាមទារការខិតខំយ៉ាងច្រើនពីគ្រូបង្រៀន(UNESCO, 2015a)។ តួនាទីរបស់គ្រូបង្រៀនត្រូវតែផ្លាស់ប្តូរ គ្រូបង្រៀនមិនចាំបាច់បន្តផ្តល់ព័ត៌មានទៅឱ្យសិស្សទៀតទេ ប៉ុន្តែគ្រូបង្រៀនក្លាយទៅជាអ្នកសម្របសម្រួល ដើម្បីឱ្យសិស្សរៀន និងជាអ្នកបង្កើតនូវបរិស្ថានថ្នាក់រៀនប្រកបដោយផលិតភាព។ គ្រូបង្រៀន ត្រូវបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សា ទៅលើប្រសិទ្ធភាព និងប្រសិទ្ធផលនៅក្នុងថ្នាក់រៀន តាមរយៈការជួយរបស់គ្រូដល់ការសិក្សារបស់សិស្សបានយ៉ាងច្រើនបំផុត ជាពិសេសក្នុងចំណោមសិស្សដែលជួបការលំបាក និងក្រុមភាគតិច(Agapitova & Navarrete Moreno, 2017)។

យោងតាម Olayide (2015) វិធីសាស្ត្របង្រៀនមានច្រើនប្រភេទទៅតាមមនុស្ស វប្បធម៌ ធម្មជាតិ និងវិទ្យាសាស្ត្រ។ល។ ទោះយ៉ាងណា វិធីសាស្ត្របង្រៀន ជារឿយៗមានការយកចិត្តទុកដាក់ជាមួយនឹងការសម្របសម្រួលការសិក្សា ឬធនធានសម្ភារៈណែនាំ។ ហេតុអ្វីយើងត្រូវប្រើធនធាន សម្ភារៈបង្រៀនក្នុងការសម្របសម្រួលដំណើរការរៀន និងបង្រៀន? យើងអាចសម្របខ្លួន ឬប្រើប្រាស់ធនធាន សម្ភារៈបង្រៀន (អេឡិចត្រូនិច ឬមិនមែនអេឡិចត្រូនិច) ដើម្បីទទួលបានដូចខាងក្រោម៖

(១) សន្សំសំចៃពេលវេលា និងថាមពល

(២) ធ្វើឱ្យការរៀនសូត្រមានលក្ខណៈអចិន្ត្រៃយ៍ពិតប្រាកដ និងបន្ទាន់

(៣) ធ្វើឱ្យការរៀនសូត្រគួរឱ្យចាប់អារម្មណ៍

(៤) ជំរុញ លើកទឹកចិត្តអ្នកសិក្សា

(៥) ធ្វើឱ្យការរៀនមានភាពត្រឹមត្រូវ ច្បាស់លាស់

(៦) នាំយកអ្វីដែលមិនមានទៅក្នុងថ្នាក់រៀន នៅបរិស្ថានដែលចាំបាច់

(៧) ធ្វើឱ្យការរៀនសូត្រមានប្រសិទ្ធភាព និងគួរឱ្យចាប់អារម្មណ៍។

### ២. ៨. ១. លក្ខណៈសំខាន់ៗក្នុងសកម្មភាពបង្រៀន

យោងតាមការស្រាវជ្រាវរបស់លោក Gregory (2004) បានបង្ហាញថា ដើម្បីធានាឱ្យបាននូវវិធីសាស្ត្របង្រៀនបានល្អ គ្រូបង្រៀនត្រូវប្រកាន់ភ្ជាប់នូវលក្ខណៈសម្បត្តិសំខាន់ៗដូចជា៖ (១) ត្រូវតែដឹងច្បាស់ពីមេរៀន ឬខ្លឹមសារដែលខ្លួនត្រូវបង្រៀន រួមទាំងចំណេះដឹងទូទៅ និងចំណេះដឹងផ្នែកគរុកោសល្យផងដែរ ដើម្បីឱ្យការរៀបចំមេរៀនយកទៅបង្រៀនត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។ (២) សិក្សាស្រាវជ្រាវមេរៀន និងភាពទាក់ទងរបស់មេរៀនទៅនឹងខ្លឹមសារផ្សេងៗទៀត ដើម្បីបង្រៀន។ (៣) ត្រូវស្វែងយល់ពីមេរៀន ឬខ្លឹមសារឱ្យបានច្បាស់លាស់ រហូតអាចកំណត់បាននូវគំនិតសំខាន់ ដែលអាចប្រើប្រាស់ជាភាសានិយាយឱ្យសាមញ្ញ និងមានភស្តុតាងសម្រាប់សិស្ស។ (៤) ត្រូវរកឱ្យឃើញនូវលំដាប់លំដោយខ្លឹមសារ

របស់មេរៀន ដោយភ្ជាប់នូវបច្ច័យ ឬអង្គហេតុ ទៅនឹងសេចក្តីពិតរបស់មេរៀននីមួយៗ។ (៥) ត្រូវរំលេចឱ្យចេញនូវភាពទាក់ទងរបស់មេរៀន ឬខ្លឹមសារបង្រៀនទៅនឹងតម្រូវការ តួនាទី និងជីវិតរបស់អ្នកសិក្សាឱ្យយល់ពីតម្លៃ។ (៦) ប្រើប្រាស់នូវជំនួយផ្សេងៗក្នុងការបង្រៀន(សម្ភារឧបទេស)។ (៧) ត្រូវធ្វើការបញ្ជាក់ ឬសួរឡើងវិញទៅលើខ្លឹមសារឱ្យបានច្បាសលាស់ ដើម្បីបញ្ជាក់ពីភាពប្រាកដប្រជារបស់សិស្ស។ (៨) ត្រូវតែរៀបចំមេរៀន ឬខ្លឹមសារបង្រៀនឱ្យបានមុនពេលដំណើរការបង្រៀន។ (៩) ត្រូវមានផែនការបង្រៀនបានត្រឹមត្រូវ។

ដោយផ្អែកតាម Jan (2017) ការបង្រៀន បានក្លាយទៅជាបញ្ហាស្មុគ្រស្មាញ ហើយនិងមានបញ្ហាប្រឈមជាច្រើននាពេលបច្ចុប្បន្ន។ ប៉ុន្តែគ្រូបង្រៀនដែលល្អ អាចជំរុញក្តីសង្ឃឹម រំញោចការស្រមើស្រមៃ និងបណ្តុះក្តីស្រលាញ់ចំពោះការសិក្សារៀនសូត្រដល់សិស្ស។ គ្រូបង្រៀននៅសតវត្សរ៍ទី ២១ ត្រូវតែគិតគូរពីតម្រូវការរបស់សិស្សរបស់ខ្លួន រៀបចំឱ្យពួកគេចេះឆ្លើយតបនឹងបញ្ហាប្រឈមនាពេលអនាគត ដឹកនាំសកម្មភាពបង្រៀន ដែលសិស្សដើរតួនាទីសំខាន់ក្នុងការផ្តល់ឱកាសឱ្យសិស្សស្គាល់ពីរបៀបរៀនរបស់ពួកគេម្នាក់ៗ សិស្សដើរតួនាទីជាអ្នកផលិតនូវខ្លឹមសារមេរៀន ចេះធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកលើប្រភពព័ត៌មានផ្សេងៗ ប្រើប្រាស់បច្ចេកវិទ្យាជាឧបករណ៍រៀនសូត្រប្រកបដោយប្រសិទ្ធភាព ពង្រីកការគិតបែបស៊ីជម្រៅ និងមានលក្ខណៈជាសកលជាដើម ដោយគ្រូជាអ្នកសម្របសម្រួលនៅពេលដែលពួកគេមានបញ្ហា។

### ២.៨.២. វិធីសាស្រ្តបង្រៀន

ការទាក់ទាញបុគ្គលណាម្នាក់ឱ្យក្លាយជាគ្រូបង្រៀន ការរក្សាទុកគ្រូបង្រៀនដែលមានសមត្ថភាពជាក្តីបារម្ភសម្រាប់បណ្តាប្រទេសជាច្រើននៅលើពិភពលោក ក៏ដូចជាបណ្តាប្រទេសដែលកំពុងអភិវឌ្ឍផងដែរ(Dembélé & Miaro-II, 2003)។ ដើម្បីកសាងគុណភាពរបស់សាលារៀន តាមរយៈការសិក្សារៀនសូត្រដ៏សកម្មរបស់សិស្ស និងលទ្ធផលសិក្សាល្អប្រសើរ គឺពឹងផ្អែកទៅលើគុណភាពរបស់គ្រូ និងការផ្តល់ឱកាសសម្រាប់គ្រូបង្រៀនទទួលបាននូវការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍសមត្ថភាពកាន់តែទូលំទូលាយ។

គោលវិធីបង្រៀនត្រូវបានគេស្គាល់ជាទូទៅមាន២ធំៗគឺ គោលវិធីគ្រូមជ្ឈមណ្ឌល និងគោលវិធីសិស្សមជ្ឈមណ្ឌល។ ចំណែកឯវិធីសាស្ត្របង្រៀនក៏ត្រូវបានគេចែកជា ២ ផងដែរគឺ វិធីសាស្ត្រសកម្ម និងវិធីសាស្ត្រអសកម្ម(វណ្ណី ២០១៩)។ ជាទូទៅគោលវិធីបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្របង្រៀនតាមបែបសកម្មត្រូវបានគេទទួលស្គាល់ថាមានប្រសិទ្ធភាពនៅក្នុងការបង្រៀន និងធ្វើឱ្យសិស្សមានសកម្មភាពរស់រវើកនៅក្នុងដំណើរការសិក្សាទាំងក្នុង និងក្រៅថ្នាក់រៀន ព្រមទាំងជួយសិស្សឱ្យសម្រេចបានលទ្ធផលសិក្សាល្អប្រសើរ។

យោងទៅតាមលោក Ginsburg (2017) គ្រូបង្រៀនដែលមានបទពិសោធន៍ ប៉ុន្តែមិនធ្លាប់ទទួលបាននូវការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ នោះការបង្រៀនរបស់ពួកគាត់នឹងមានលក្ខណៈខុសគ្នាឆ្ងាយពីស្ថានភាពបច្ចុប្បន្នដែលអ្នកធ្វើកំណែទម្រង់ចង់បាន ដូច្នេះហើយការបង្រៀនបែបនេះមិនបានជួយសិស្សឱ្យរៀនចេះគិតពិចារណា។ ការបង្រៀនប្រកបដោយប្រសិទ្ធភាព ត្រូវតែផ្សារភ្ជាប់ទៅនឹងគោលបំណងនៃការអភិវឌ្ឍ ដែលគ្រូបង្រៀនត្រូវតែ៖ (១) យល់ឱ្យបានច្បាស់ពីប្រធានបទដែលត្រូវបង្រៀន (២) ប្រើប្រាស់គរុកោសល្យនៃការបង្រៀនឱ្យស្របទៅតាមខ្លឹមសារ (៣) ប្រើប្រាស់ភាសានៃការបង្រៀនបានសមស្រប និងមានចំណេះដឹងពីភាសាបានត្រឹមត្រូវ (៤) ចេះបង្កើននូវបរិយាកាសរៀនសូត្រដល់សិស្សប្រកបដោយប្រសិទ្ធភាព (៥) ចេះស្វែងយល់ពីភាពឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស និងសហគមន៍ (៦) ចេះឆ្លុះបញ្ចាំងពីការបង្រៀនរបស់ខ្លួន និងការឆ្លើយតបរបស់សិស្ស ដើម្បីផ្លាស់ប្តូរនូវបរិយាកាសរៀនសូត្រដែលចាំបាច់ (៧) ត្រូវមានក្រមសីលធម៌វិជ្ជាជីវៈរឹងមាំ និង(៨) មានការប្តេជ្ញាចិត្តចំពោះការងារបង្រៀន និងយកចិត្តទុកដាក់ចំពោះសិស្សរបស់ខ្លួន។

យោងតាម Anderson (2017) សកម្មភាពបង្រៀនដែលធ្វើឱ្យសិស្សមានភាពសកម្មទាំងក្នុង និងក្រៅថ្នាក់រៀន ធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សកាន់តែមានលក្ខណៈប្រសើរឡើង តាមរយៈការផ្លាស់ប្តូរនូវគរុកោសល្យតាមបែបប្រពៃណីរបស់តួនាទីគ្រូបង្រៀនមួយចំនួនដូចជា៖

## (១) តួនាទីរបស់គ្រូបង្រៀន

| ការបង្រៀនបែបប្រពៃណី | ការបង្រៀនបែបថ្មី |
|---|---|
| ⊙ ជាអ្នកចែករំលែកចំណេះដឹង និងព័ត៌មាន | ⊙ ជាគ្រូបង្វឹក និងសម្របសម្រួល |
| ⊙ ទំនាក់ទំនងជាមួយសិស្សជាបុគ្គល | ⊙ ទំនាក់ទំនងជាមួយសិស្សជាក្រុម |
| ⊙ ធ្វើសកម្មភាពផ្ទាល់ឱ្យសិស្ស | ⊙ បង្វឹកសកម្មភាពសិស្ស |
| ⊙ គ្រូពន្យល់ទំនាក់ទំនងគោលគំនិត | ⊙ សម្របសម្រួលការគិតរបស់សិស្ស |
| ⊙ ផ្អែកលើចំណេះដឹងរបស់គ្រូ | ⊙ យកគំរូដំណើរការរៀនសូត្រ |
| ⊙ ប្រើប្រាស់សៀវភៅគោលដើម្បីណែនាំ។ | ⊙ ប្រើប្រាស់សម្ភារឧបទេសសមស្របទៅតាមខ្លឹមសារមេរៀន និងស្ថានភាព។ |

## (២) តួនាទីរបស់សិស្ស

| | |
|---|---|
| ⊙ ធ្វើសកម្មភាពតាមបញ្ជារបស់គ្រូ | ⊙ សិស្សដឹកនាំការរៀនសូត្រដោយខ្លួនឯង |
| ⊙ បំពេញសន្លឹកកិច្ចការ | ⊙ សិស្សបំពេញការងារតាមតួនាទីរៀងៗខ្លួន |
| ⊙ សិស្សទាំងអស់បំពេញការងារដូចៗគ្នា | ⊙ សិស្សរៀបចំដឹកនាំការងារដោយខ្លួនឯង |
| ⊙ គ្រូជាអ្នកដឹកនាំធ្វើការងារ | ⊙ សង្កត់ធ្ងន់លើហេតុផលតាមរយៈការអាន ការសរសេរពីអត្ថន័យ ការដោះស្រាយបញ្ហា |
| ⊙ មិនប្រើប្រាស់សម្ភារឧបទេសជំនួយ។ | ⊙ កសាងរចនាសម្ព័ន្ធនៃការយល់ដឹងដែលមានស្រាប់ |
| | ⊙ សិស្សពន្យល់ បកស្រាយពីប្រកពនៃបញ្ហា។ |

## (៣) កិច្ចការងាររបស់សិស្ស

| | |
|---|---|
| ⊙ ជាអ្នកទទួលអសកម្ម | ⊙ អ្នករៀនដឹកនាំខ្លួនឯង |
| ⊙ កត់ត្រាព័ត៌មានរបស់គ្រូ | ⊙ ព័ត៌មានដំណើការ |

⊙ សង្ខេបព័ត៌មាន ⊙ បកស្រាយ ពន្យល់ ភស្តុតាង

⊙ ធ្វើតាមការណែនាំរបស់គ្រូ ⊙ រៀបចំសកម្មភាពដោយខ្លួនឯង

⊙ គ្រូជាអ្នកបញ្ជា។ ⊙ សិស្សចែករំលែកចម្លើយផ្ទាល់ខ្លួន។

## ២. ៨. ៣. វិធីសាស្ត្រចិត្តគរុកោសល្យជួយសិស្សក្នុងការរៀនសូត្រ

នៅក្នុងប្រទេសជាច្រើន របៀប និងវិធីសាស្ត្របង្រៀនដែលគ្រូបានយកទៅប្រើជាទូទៅ មិនបានជួយសិស្សឱ្យរៀនសូត្របានប្រសើរឡើយ អ្នកជំនាញអប់រំជាច្រើនបានឯកភាពថា គរុកោសល្យយកគ្រូជាគោលមជ្ឈមណ្ឌល ដោយឱ្យសិស្សមានមុខងារជាអ្នកទទួលសុទ្ធសាធនោះ មិនមានលក្ខណៈល្អប្រសើរឡើយសម្រាប់ការរៀនសូត្ររបស់សិស្ស ប៉ុន្តែវិធីនេះត្រូវបានគេយកទៅអនុវត្តក្នុងបន្ទប់រៀនយ៉ាងច្រើន។ កម្មវិធីសិក្សាសំខាន់ៗទាំងឡាយដែលគេបានធ្វើការសិក្សាស្រាវជ្រាវ គឺបានជំរុញការលើកទឹកចិត្តឱ្យប្រើគរុកោសល្យ ដោយយកសិស្សជាគោលមជ្ឈមណ្ឌល វិធីសាស្ត្ររៀនសូត្រដោយមានការចូលរួម និងអភិវឌ្ឍជំនាញគិតវិភាគ រិះរក និងជំនាញដោះស្រាយបញ្ហា(Anderson, 2017)។ អ្នកឯកទេសអប់រំជាច្រើន បានគាំទ្រឱ្យការបង្រៀនមានរចនាសម្ព័ន្ធត្រឹមត្រូវ ច្បាស់លាស់ ពោលគឺការបង្រៀនដែលមានការដាក់បញ្ចូលគ្នានូវការណែនាំផ្ទាល់ ការអនុវត្តដោយមានកាណែនាំជាមុន និងការរៀនប្រកបដោយម្ចាស់ការ។ ជាធម្មតាគ្រូបង្ហាញខ្លឹមសារមេរៀនមួយចំនួនឱ្យសិស្សយល់ រួចបំផុសឱ្យសិស្សចាប់ផ្តើមសិក្សាស្រាវជ្រាវ ស្វែងរកប្រភពបញ្ហា និងចេះដោះស្រាយបញ្ហាដោយខ្លួនឯង គ្រូមានតួនាទីជាអ្នកបង្វឹក និងសម្របសម្រួលដំណើរការរៀនសូត្ររបស់សិស្ស(Diaz-Maggioli, 2004)។

គ្រូបង្រៀនដែលមានប្រសិទ្ធិភាព ត្រូវដឹងថាគោលការណ៍នៃចិត្តវិទ្យាអប់រំ និងការស្រាវជ្រាវអប់រំនឹងជួយពួកគាត់ដឹកនាំការសិក្សារបស់សិស្ស ឱ្យយល់បានស៊ីជម្រៅពីរបៀបនៃការសិក្សារៀនសូត្រ ជាជាងប្រាប់ពីអ្វីដែលសិស្សត្រូវរៀន(Santrock, 2011)។ ជាងនេះទៅទៀត នៅក្នុងដំណើរការបង្រៀន និងរៀនប្រចាំថ្ងៃ គ្រូបង្រៀនគួរតែត្រូវបានប្រើប្រាស់នូវសំណួរជាមូលដ្ឋានមួយចំនួន ដែលបណ្តុះនូវទម្លាប់នៃការសិក្សាដោយខ្លួនឯងដល់សិស្សដូចជា តើអ្នកគិតដូចម្តេចចំពោះកិច្ចការផ្ទះ សម្ភារឧបទេសជួយដល់ការរៀនបានដូចម្តេច កិច្ចការស្រាវជ្រាវវែងពេក ឬខ្លីពេក តើគួរធ្វើដូចម្តេចដើម្បីឱ្យកាន់តែមានការចាប់អារម្មណ៍

តើគួរវាយតម្លៃទៅលើផ្នែកណាខ្លះ។ ការស្វែងយល់បានស៊ីជម្រៅពីរបៀបបង្រៀន និងរបៀបរៀនសូត្រ វាជាផ្នែកយ៉ាងសំខាន់នៅក្នុងការអប់រំ( Seifert & Sutton, 2009 )។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "**ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា កម្រិតមធ្យមសិក្សាទុតិយភូមិ**" មានគោលបំណងស្វែងយល់ និងរកឱ្យឃើញពី ការអនុវត្តកម្មវិធីសិក្សា តាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានកម្រិតណា និងបញ្ហាប្រឈម របស់គ្រូបង្រៀន នៅក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា នៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ។ ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ គឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣. ១. គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ៣ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សីគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅវិទ្យាល័យចំនួន ១០ ក្នុងរាជធានីភ្នំពេញ និងក្រុមគោលដៅបំពេញកម្រងសំណួរមាន៣ប្រភេទ គឺគណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនមុខវិជ្ជា ប្រវត្តិវិទ្យា ពីថ្នាក់ទី១០-១២។

## ៣. ២. ការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រូបង្រៀនតាមសាលារៀនរដ្ឋបានចាប់ផ្តើមបង្រៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៩៧ វជអ.ផក ចុះថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំណាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ តាមរយៈសំណួរសម្ភាសន៍ផ្ទាល់ និងតាមអនឡាញ( Online Google Form )។

ក្រោយពីបានឆ្លងយោបល់ តាមលក្ខណៈបច្ចេកទេសជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមក អ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ មានការសហការល្អជាមួយអាជ្ញាធរដែនដី មន្ទីរអប់រំរាជធានី គណៈគ្រប់គ្រងសាលារៀន ដើម្បីចែកកម្រងសំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។ អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបនាយកសាលារៀននីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងលិខិតចុះប្រមូលទិន្នន័យ ព្រមទាំងសុំការអនុញ្ញាតជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរសម្ភាសន៍មាន គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ ការចុះប្រមូលទិន្នន័យ គឺមានភាពបត់បែនទៅតាមភូមិសាស្ត្ររបស់សាលារៀន និងផ្តល់អាទិភាពដល់អ្នកផ្តល់ទិន្នន័យ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមនានា Google Form Telegram និងតាមប្រព័ន្ធទូរស័ព្ទជាដើម។

ការបំពេញកម្រងសំណួរមានរយៈពេលពីរសប្តាហ៍ អ្នកស្រាវជ្រាវ បានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតបទៅតាមពេលវេលាកំណត់ជាក់លាក់។ ក្នុងពេលអន្តរកាល នៃការរក្សាគម្លាតសង្គម ការចុះប្រមូលទិន្នន័យបានជួបបញ្ហាមួយចំនួនផងដែរ ទាំងផ្នែកបច្ចេកទេស និងបណ្តាញទំនាក់ទំនងសង្គម និងកិច្ចសហការពីអ្នកឆ្លើយតប។ ក្នុងការចុះប្រមូលទិន្នន័យ បានប្រើប្រាស់ពេលវេលាសរុបចំនួន ៣០ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំណួរទាំងអស់ពីគណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។

### ៣. ៣. ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ “**ការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា កម្រិតមធ្យមសិក្សាទុតិយភូមិ**” នៅវិទ្យាល័យចំនួន ១០ ក្នុងរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួន ៣ ប្រភេទ ក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ពីគណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដោយផ្អែកទៅលើឯកសារយោងនានា រួមទាំងខេមរភាសា និងភាសាអង់គ្លេស ហើយឯកសារគោលជាភាសាខ្មែរមានដូចជា គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតសិក្សាសង្គមថ្នាក់ទី១០-១២ ឯកសារណែនាំអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា ថ្នាក់ទី១០-១២

ស្តង់ដាកម្មវិធីសិក្សាជាដើម ដើម្បីសិក្សាពីកម្រិតអនុវត្តបាននៃកម្មវិធីសិក្សានៅកម្រិតសាលារៀន និងបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សាដែលគ្រូបង្រៀនបានជួបប្រទះ ក្នុងដំណើរការនៃការអនុវត្តនាពេលកន្លងមក។

**តារាងទី១៖ ឈ្មោះខណ្ឌ និងសាលា**

| ល.រ | ចំនួនខណ្ឌ | ចំនួនសាលា |
|---|---|---|
| ១ | ជ្រោយចង្វារ | វិទ្យាល័យជា ស៊ីម ជ្រោយចង្វារ |
| ២ | ឫស្សីកែវ | វិទ្យាល័យឫស្សីកែវ |
| ៣ | បឹងកេងកង | វិទ្យាល័យទួលស្វាយព្រៃ |
| | | វិទ្យាល័យ ជា ស៊ីម បឹងកេងកង |
| ៤ | ទួលគោក | វិទ្យាល័យឥន្ទ្រទេវី |
| | | វិទ្យាល័យ ជា ស៊ីម សាមគ្គី |
| ៥ | សែនសុខ | វិទ្យាល័យហ៊ុន សែន បុរី១០០ខ្នង |
| | | វិទ្យាល័យទួលប្រាសាទសែនសុខ |
| ៦ | ដង្កោ | វិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស ជម្ពូវ័ន |
| | | វិទ្យាល័យពងទឹក |
| **សរុប** | **៦ខណ្ឌ** | **១០សាលា** |

### ៣. ៣. ១. កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញដែលបានប្រើប្រាស់នៅក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និងគូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ការសិក្សាស្រាវជ្រាវប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Linkert Scale គឺនិយមចូលចិត្តប្រើប្រាស់ច្រើន លើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញ គឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន នៅតាមវិទ្យាល័យគោលដៅនៃការសិក្សាស្រាវជ្រាវ។

ការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មានចំនួន ៥កម្រិត ពីទាបបំផុត ទៅខ្ពស់បំផុត។ រូបមន្តនៃកម្រិតចង្អុលបង្ហាញដូចខាងក្រោម៖

កម្រិត ១ គឺ មិនយល់ស្របទាល់តែសោះ

កម្រិត ២ គឺ មិនយល់ស្រប

កម្រិត ៣ គឺ ពុំមានយោបល់

កម្រិត ៤ គឺ យល់ស្រប

កម្រិត ៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីធ្វើការវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម( Best, 1981 )៖

$$\frac{Highest\ Score - Lowest\ Score}{No.\ of\ Levels} = \frac{5-1}{5} = \frac{4}{5} = 0.80$$

| | | |
|---|---|---|
| ១.00 ដល់ ១.៨០ | មានន័យថា | ខ្សោយខ្លាំង |

| | | |
|---|---|---|
| ១.៨១ ដល់ ១.៦០ | មានន័យថា | ខ្សោយ |
| ២.៦១ ដល់ ៣.៤០ | មានន័យថា | មធ្យម |
| ៣.៤១ ដល់ ៤.២០ | មានន័យថា | ល្អ |
| ៤.២១ ដល់ ៥.០០ | មានន័យថា | ល្អណាស់ |

### ៣. ៣. ២. កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរស្រាវជ្រាវនេះ គឺដើម្បីរកឱ្យឃើញពីកម្រិតនៃការអនុវត្តបានលើកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងបញ្ហាប្រឈមនានា ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា នៅតាមវិទ្យាល័យគោលដៅនៃការសិក្សាស្រាវជ្រាវទាំង ១០ នៅរាជធានីភ្នំពេញ។ ទិន្នន័យដែលប្រមូលបានពីការសិក្សាស្រាវជ្រាវ គឺបម្រើឱ្យតែការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

#### ⊙ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា

កម្រងសំណួរសម្រាប់លោកនាយក លោកស្រីនាយិកាសាលា មានគោលបំណងស្វែងយល់អំពីដំណើរការនៃការងារគ្រប់គ្រងរបស់លោកនាយក លោកស្រីនាយិកាសាលា និងការពង្រឹងគុណភាពសិក្សារបស់សិស្សនៅក្នុងសាលារៀនរបស់ខ្លួន។ កម្រងសំណួរនេះមានការបែងចែកជាបីផ្នែកគឺ៖ **ផ្នែកទី១** ស្ដីពីព័ត៌មានទូទៅ។ **ផ្នែកទី២** ការអនុវត្តកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាប្រវត្តិវិទ្យា។ ការជានាគុណភាពអប់រំលើការអនុវត្តកម្មវិធីសិក្សា ការងារគ្រប់គ្រង ការដឹកនាំ ជាពិសេសទៅលើការងារពង្រឹងគុណភាពនៃការបង្រៀន និងរៀនរបស់គ្រូ និងសិស្សដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់គាត់។ **ផ្នែកទី៣** បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជា ប្រវត្តិវិទ្យា។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះរយៈពេលនៃការបំពេញកម្រងសំណួរជាមធ្យមមានរយៈពេលពី ១៥នាទីទៅ ២០នាទីនៅតាមកន្លែងដែលបានព្រមព្រៀងគ្នារវាងអ្នកប្រមូលទិន្នន័យ និងអ្នកផ្ដល់ព័ត៌មាន។ ការស្នើសុំណាត់ជួបដើម្បីបំពេញកម្រងសំណួរនៅតាមសាលារៀនគោលដៅ គឺត្រូវបានទទួលការអនុញ្ញាត ពីប្រធានការិយាល័យមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូដែលជាប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវជ្ជា ប្រវត្តិវិទ្យា។

⊙ **កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស**

កម្រងសំណួរនេះ មានគោលបំណងស្វែងយល់ពីដំណើរការនៃ ការងារគ្រប់គ្រងក្រុមបច្ចេកទេស និងការពង្រឹងគុណភាពសិក្សារបស់សិស្សតាមមុខវិជ្ជាឯកទេស(ប្រវត្តិវិទ្យា) នៅក្នុងសាលារបស់ពួកគាត់។ កម្រងសំណួរនេះមានការបែងចែកជាពីរផ្នែកគឺ៖ **ផ្នែកទី១** ស្តីពីព័ត៌មានទូទៅ និង**ផ្នែកទី២** ស្តីពីការងារប្រតិបត្តិរបស់ក្រុមបច្ចេកទេស ការដឹកនាំក្រុមបច្ចេកទេស ការពិនិត្យតាមដាន និងកែលម្អបច្ចេកទេសក្នុងការបង្រៀន និងរៀន និងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ និងវិធីសាស្ត្របង្រៀន មុខវិជ្ជាប្រវត្តិវិទ្យា។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះរយៈពេលនៃការបំពេញកម្រងសំណួរជាមធ្យមមានរយៈពេលពី ១៥នាទី ទៅ ២០នាទីនៅតាមកន្លែងដែលបានព្រមព្រៀងគ្នារវាងអ្នកប្រមូលទិន្នន័យ និងអ្នកផ្តល់ព័ត៌មាន ដោយបានទទួលបានការអនុញ្ញាតពីប្រធានការិយាល័យមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី គណៈគ្រប់គ្រងសាលា និងសាមីខ្លួនផ្ទាល់ដែលជាប្រធានក្រុមបច្ចេកទេសតាមសាលារៀននីមួយៗ។

⊙ **កម្រងសំណួរសម្រាប់គ្រូបង្រៀន**

កម្រងសំណួរសម្រាប់គ្រូបង្រៀន មានគោលបំណងរកឱ្យឃើញនូវស្ថានភាពនៃដំណើរការប្រតិបត្តិ និងប្រសិទ្ធភាពនៃដំណើរការបង្រៀនរបស់គ្រូ ការអនុវត្តតួនាទីរបស់គ្រូបង្រៀនការលើកកម្ពស់គុណភាពនៃការបង្រៀន និងគុណវុឌ្ឍិរបស់គ្រូតាមរយៈការបណ្តុះបណ្តាល ការពិនិត្យតាមដានរបស់គណៈគ្រប់គ្រង និងថ្នាក់មន្ទីរអប់រំ។ កម្រងសំណួរនេះចែកចេញជាប្រាំផ្នែកគឺ៖ កម្រងសំណួរនេះមានការបែងចែកជាបីផ្នែកគឺ៖ **ផ្នែកទី១** ស្តីពីព័ត៌មានទូទៅ។ **ផ្នែកទី២** ការអនុវត្តកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាប្រវត្តិវិទ្យា។ ដំណើរការងារបង្រៀន និងរៀន ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន និងផលប៉ះពាល់នៃម៉ោងសិក្សា។ ជាពិសេសទៅលើការងារពង្រឹងគុណភាពនៃការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូ។ **ផ្នែកទី៣** បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ និងវិធីសាស្ត្របង្រៀន មុខវិជ្ជា ប្រវត្តិវិទ្យា។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះរយៈពេលនៃការបំពេញកម្រងសំណួរ មានជាសំណួរទម្រង់បិទ និងទម្រង់បើកជាមធ្យមមានរយៈពេលពី ១៥នាទីទៅ ២០នាទីនៅតាម

កន្លែងដែលបានព្រមព្រៀងគ្នារវាងអ្នកប្រមូលទិន្នន័យ និងអ្នកផ្តល់ព័ត៌មាន ដោយបានទទួលបានការអនុញ្ញាតពីប្រធានការិយាល័យមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី និងគណៈគ្រប់គ្រងសាលា និងសាមីខ្លួនផ្ទាល់ដែលជាគ្រូបង្រៀនតាមសាលារៀននីមួយៗ។

## ៣. ៤. ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរចំនួន ១០ វិទ្យាល័យនៅរាជធានីភ្នំពេញ ដែលមានចំនួនភាគសំណាកសរុប ៥០នាក់ ដែលក្នុងនោះមានគណៈគ្រប់គ្រងសាលាចំនួន ១០នាក់ ប្រធានក្រុមបច្ចេកទេសចំនួន ១០នាក់ និងគ្រូបង្រៀនចំនួន ៣០នាក់។ ខាងក្រោមនេះគឺជា តារាងលម្អិតនៃការជ្រើសរើសភាគសំណាក ដោយប្រើវិធី Purposeive Sampling( ជ្រើសរើសសំណាកតាមគោលបំណងរបស់អ្នកស្រាវជ្រាវ )។

**តារាងទី២៖ ភាគសំណាក និងទំហំភាគសំណាក**

| ល.រ | ឈ្មោះសាលាគោលដៅ | ភាគសំណាក | | |
|---|---|---|---|---|
| | | គណៈគ្រប់គ្រង | ប្រ. បច្ចេកទេស | គ្រូបង្រៀន |
| ១ | វិទ្យាល័យជា ស៊ីម ជ្រោយចង្វារ | ១នាក់ | ១នាក់ | ៣នាក់ |
| ២ | វិទ្យាល័យឫស្សីកែវ | ១នាក់ | ១នាក់ | ៣នាក់ |
| ៣ | វិទ្យាល័យទួលស្វាយព្រៃ | ១នាក់ | ១នាក់ | ៣នាក់ |
| ៤ | វិទ្យាល័យ ជា ស៊ីម បឹងកេងកង | ១នាក់ | ១នាក់ | ៣នាក់ |
| ៥ | វិទ្យាល័យឥន្ទ្រទេវី | ១នាក់ | ១នាក់ | ៣នាក់ |
| ៦ | វិទ្យាល័យ ជា ស៊ីម សាមគ្គី | ១នាក់ | ១នាក់ | ៣នាក់ |
| ៧ | វិទ្យាល័យហ៊ុន សែន បុរី១០០ខ្នង | ១នាក់ | ១នាក់ | ៣នាក់ |

| | | | | |
|---|---|---|---|---|
| ៨ | វិទ្យាល័យទួលប្រាសាទសែនសុខ | ១នាក់ | ១នាក់ | ៣នាក់ |
| ៩ | វិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេសជម្ពូវ័ន | ១នាក់ | ១នាក់ | ៣នាក់ |
| ១០ | វិទ្យាល័យពងទឹក | ១នាក់ | ១នាក់ | ៣នាក់ |
| **សរុប** | **១០សាលា** | **១០នាក់** | **១០នាក់** | **៣០នាក់** |

### ៣. ៥. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាទម្រង់ពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកជាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យតាមកម្មវិធី SPSS និងប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បីផ្ទុកទិន្នន័យដែលប្រមូលបានពីកម្រងសំណួរក្នុងទម្រង់ Google Form រួចធ្វើការ Export Data from Excel to SPSS( Version 26 ) ដើម្បីវិភាគទិន្នន័យ។ នៅក្នុងកម្មវិធី SPSS អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍មួយចំនួន ដែលមាននៅក្នុងកម្មវិធី SPSS ដើម្បីវិភាគទិន្នន័យ( Persentage, Mean, Standard Deviation,... )។ ការសិក្សាស្រវជ្រាវនេះ បានប្រើប្រាស់ Descriptive Analysis, Prequencies Analysis, Statistics Analysis and Use chart, Tables,...។

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយលទ្ធផល និងពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ លើក្រុមគោលដៅដែលពាក់ព័ន្ធរួមមាន គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ ដែលកំពុងបង្រៀននៅវិទ្យាល័យចំនួន១០ ក្នុងរាជធានីភ្នំពេញ មានដូចជាវិទ្យាល័យជា ស៊ីម ជ្រោយចង្វារ វិទ្យាល័យ ឫស្សីកែវ វិទ្យាល័យ ឥន្ទ្រទេវី វិទ្យាល័យ ជា ស៊ីម សាមគ្គី វិទ្យាល័យ ជា ស៊ីម បឹងកេងកង វិទ្យាល័យ ទួលស្វាយព្រៃ វិទ្យាល័យ ហ៊ុន សែន បុរី១០០ខ្នង វិទ្យាល័យ ទួលប្រាសាទសែនសុខ វិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស ជម្ពូវ័ន និងវិទ្យាល័យពងទឹក ដែលទាក់ទងទៅនឹងទ្រឹស្តីដែលបានលើកឡើងនៅក្នុងជំពូកទី២។ ក្នុងជំពូកទី៤នេះ នឹងបង្ហាញនូវចំណុចសំខាន់ៗ ដែលបានលើកឡើងក្នុងសំណួរស្រាវជ្រាវ ដែលទាក់ទងនឹងកម្រិតនៃការអនុវត្តកម្មវិធីសិក្សា បញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀនទាំង១០ ក្នុងរាជធានីភ្នំពេញ និងការធានាគុណភាពអប់រំ តាមរយៈការអនុវត្តកម្មវិធីសិក្សា ដែលគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបានអនុវត្តកន្លងមក សម្រាប់យកមកធ្វើការបកស្រាយតាមលទ្ធផលជាក់ស្តែង និងធ្វើការពិភាក្សារវាងលទ្ធផលដែលបានរកឃើញ ទៅនឹងទ្រឹស្តីដែលបានលើកឡើងដោយអ្នកសិក្សាស្រាវជ្រាវកន្លងមក។ លើសពីនេះទៅទៀត អ្នកសិក្សាស្រាវជ្រាវក៏បានបង្ហាញពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូទៅលើការអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ដើម្បីទុកជាធាតុចូលក្នុងការកែលម្អ និងជំរុញការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀនឱ្យកាន់តែទទួលបានភាពជោគជ័យ។

## ៤. ១. ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន

នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានកំណត់យកវិទ្យាល័យចំនួន ១០ នៅក្នុងរាជធានីភ្នំពេញមកធ្វើការសិក្សាស្រាវជ្រាវ។ ក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ ដែលជាជាភាគសំណាកនៃការ

សិក្សាស្រាវជ្រាវ ហើយផ្តោតទៅលើព័ត៌មានសំខាន់ៗដូចតទៅ៖ អំពីគណៈគ្រប់គ្រងសាលាមានដូចជា តួនាទី មុខវិជ្ជាឯកទេស ភេទ ក្រុមអាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ។ អំពីប្រធានក្រុមបច្ចេកទេសមានដូចជា មុខវិជ្ជាឯកទេស មុខវិជ្ជាបង្រៀនកម្រិតថ្នាក់បង្រៀន ភេទ កម្រិតវប្បធម៌ បទពិសោធន៍បង្រៀន របបម៉ោងបង្រៀន។ អំពីគ្រូបង្រៀនមានដូចជា មុខវិជ្ជាឯកទេស មុខវិជ្ជាបង្រៀនកម្រិតថ្នាក់បង្រៀន ភេទ ក្រុមអាយុ កម្រិតវប្បធម៌ បទពិសោធន៍បង្រៀន របបម៉ោងបង្រៀន កម្រិតថ្នាក់បង្រៀន។

### ៤. ១. ១. ព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលារៀន

**តារាងទី៣៖ ព័ត៌មានប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលារៀន**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | តួនាទី | នាយក | 4 | 40 |
| | | នាយករង | 6 | 60 |
| | | **សរុប** | **10** | **100** |
| ២ | មុខវិជ្ជាឯកទេស | វិទ្យាសាស្ត្រ | 6 | 60 |
| | | វិទ្យាសាស្ត្រសង្គម | 4 | 40 |
| | | **សរុប** | **10** | **100** |
| ៣ | ភេទ | ស្រី | 1 | 10 |
| | | ប្រុស | 9 | 90 |
| | | **សរុប** | **5** | **100** |
| ៤ | ក្រុមអាយុ | ២៥-៣០ | 1 | 10 |
| | | ៣០-៤០ | 3 | 30 |
| | | លើសពី៤០ | 6 | 60 |
| | | **សរុប** | **10** | **100** |
| ៥ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | 0 | 0 |
| | | បរិញ្ញាបត្រ | 5 | 50 |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 5 | 50 |
| | | **សរុប** | **10** | **100** |
| ៦ | បទពិសោធន៍ជានាយកសាលា | ១-៥ | 2 | 20 |
| | | ៦-១០ | 3 | 30 |
| | | ១១-១៥ | 4 | 40 |
| | | លើសពី២០ | 1 | 10 |

| | | | | |
|---|---|---|---|---|
| | | **សរុប** | **10** | **100** |

**តាមទិន្នន័យតារាងទី៣៖** គណៈគ្រប់គ្រងសាលា ដែលបានចូលរួមក្នុងការឆ្លើយនឹងកម្រងសំណួរដោយផ្ទាល់ និងតាមរយៈ Survey Online ជាទម្រង់ Google Form ដែលបានរៀបចំដោយអ្នកស្រាវជ្រាវគឺមានចំនួនសរុប ១០នាក់ ស្រី០១នាក់ ដែលមានតួនាទីជានាយកចំនួន ០៤នាក់ នាយករង នាយិការងចំនួន ០៦នាក់ ស្រី០១នាក់ ដែលកំពុងបម្រើការងារនៅតាមវិទ្យាល័យគោលដៅស្រាវជ្រាវទាំង១០សាលា។ សូមបញ្ជាក់ផងដែរថា គណៈគ្រប់គ្រងសាលាវិទ្យាល័យទាំង១០នាក់ មានបទពិសោធន៍ជានាយក នាយករង នាយិការងចាប់ពី៥ឆ្នាំ រហូតដល់លើពី២០ឆ្នាំ។ ចំណែកឯកម្រិតវប្បធម៌(គុណវុឌ្ឍិ) របស់គណៈគ្រប់គ្រងសាលាវិញគឺមាន សញ្ញាបត្របរិញ្ញាបត្រចំនួន ០៥នាក់( ៥០ភាគរយ) និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ០៥នាក់( ៥០ភាគរយ)។

## ៤. ១. ២. ព័ត៌មានប្រជាសាស្រ្តរបស់ប្រធានក្រុមបច្ចេកទេស

**តារាងទី៤៖ ព័ត៌មានប្រជាសាស្រ្តរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | តួនាទី | ប្រធានក្រុម | 9 | 90 |
| | | អនុប្រធានក្រុម | 1 | 10 |
| | | **សរុប** | **10** | **100** |
| ២ | ភេទ | ប្រុស | 6 | 60 |
| | | ស្រី | 4 | 40 |
| | | **សរុប** | **10** | **100** |
| ៣ | ជំនាញឯកទេស | ប្រវត្តិវិទ្យា | 10 | 100 |
| | | **សរុប** | **10** | **100** |
| ៤ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | 0 | 0.00 |
| | | បរិញ្ញាបត្រ | 8 | 80 |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 2 | 20 |
| | | បណ្ឌិត | 0 | 0.00 |
| | | **សរុប** | **10** | **100** |
| ៥ | បទពិសោធន៍បង្រៀន | ៦-១០ | 1 | 10 |
| | | ១១-២០ | 4 | 40 |

| | | | | |
|---|---|---|---|---|
| | | លើសពី២០ | 5 | 50 |
| | | **សរុប** | **10** | **100** |
| ៦ | បទពិសោធន៍ដឹកនាំក្រុម | ១-៥ | 4 | 40 |
| | | ១១-២០ | 3 | 30 |
| | | លើសពី២០ | 3 | 30 |
| | | **សរុប** | **10** | **100** |

**តាមទិន្នន័យតារាងទី៤៖** នៅក្នុងចំណោមប្រធានក្រុមបច្ចេកទេស ដែលបានចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវនេះមានចំនួនសរុប ១០នាក់ ស្រី ៤នាក់ ក្នុងមួយវិទ្យាល័យមានប្រធានក្រុមបច្ចេកទេសចំនួន ១នាក់ ដែលជាប្រធានក្រុមបច្ចេកទេសមុខវិជ្ជា ប្រវត្តិវិទ្យា ឬជាប្រធានក្រុមបច្ចេកទេសវិទ្យាសាស្ត្រសង្គម។

- **ជំនាញឯកទេស៖** ក្នុងចំណោមប្រធាន និងអនុប្រធានក្រុមបច្ចេកទេសទាំង១០នាក់ សុទ្ធតែមានជំនាញឯកទេស ប្រវត្តិវិទ្យា។
- **កម្រិតវប្បធម៌៖** មានសញ្ញាបត្របរិញ្ញាបត្រចំនួន ៨នាក់(៨០ភាគរយ) និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ២នាក់(២០ភាគរយ)។
- **បទពិសោធន៍បង្រៀន៖** បង្រៀនចាប់ពី ៦-១០ឆ្នាំមានចំនួន ១នាក់ បង្រៀនចាប់ពី ១១-២០ឆ្នាំមានចំនួន ៤នាក់ និងបង្រៀនលើសពី ២០ឆ្នាំមានចំនួន ៥នាក់។
- **បទពិសោធន៍ដឹកនាំក្រុមបច្ចេកទេស៖** មានបទពិសោធន៍ដឹកនាំក្រុមបច្ចេកទេសចាប់ពី ១-៥ឆ្នាំមានចំនួន ៤នាក់ ចាប់ពី ១១-២០ឆ្នាំមានចំនួន ៣នាក់ និងបទពិសោធន៍លើសពី ២០ឆ្នាំមានចំនួន ៣នាក់។

### ៤. ១. ៣. ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន

**តារាងទី៥៖ ព័ត៌មានប្រជាសាស្ត្ររបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | មុខវិជ្ជាឯកទេស | ប្រវត្តិវិទ្យា | 25 | 83.30 |
| | | ភូមិវិទ្យា | 5 | 16.70 |
| | | **សរុប** | **30** | **100** |

| | | | | |
|---|---|---|---|---|
| ២ | មុខវិជ្ជាដែលបង្រៀន | ប្រវត្តិវិទ្យា | 30 | 100.00 |
| | | ភូមិវិទ្យា | 0 | 0.00 |
| | | **សរុប** | **30** | **100** |
| ៣ | កម្រិតថ្នាក់បង្រៀន | ថ្នាក់ទី១០ | 13 | 43.30 |
| | | ថ្នាក់ទី១១ | 12 | 40.00 |
| | | ថ្នាក់ទី១២ | 5 | 16.70 |
| | | **សរុប** | **30** | **100** |
| ៥ | ភេទ | ប្រុស | 17 | 56.70 |
| | | ស្រី | 13 | 43.30 |
| | | **សរុប** | **30** | **100** |
| ៦ | ក្រុមអាយុ | ៣០-៣៥ | 2 | 6.70 |
| | | ៣៦-៤០ | 7 | 23.30 |
| | | លើសពី៤០ | 21 | 70.00 |
| | | **សរុប** | **30** | **100** |
| ៧ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | 9 | 30.00 |
| | | បរិញ្ញាបត្រ | 14 | 46.70 |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 7 | 23.30 |
| | | **សរុប** | **30** | **100** |
| ៨ | បទពិសោធន៍បង្រៀន | ៦-១០ | 1 | 3.30 |
| | | ១១-២០ | 13 | 43.30 |
| | | លើសពី២០ | 16 | 53.30 |
| | | **សរុប** | **30** | **100** |
| ៩ | របបម៉ោងបង្រៀន | ១-៥ ម៉ោង | 21 | 70.00 |
| | | ៦-១០ ម៉ោង | 7 | 23.30 |
| | | ១១-១៦ ម៉ោង | 2 | 6.70 |
| | | **សរុប** | **30** | **100** |

**តាមទិន្នន័យតារាងទី៥៖** ក្នុងចំណោមលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជា ប្រវត្តិវិទ្យា និងកំពុងបង្រៀននៅវិទ្យាល័យគោលដៅនៃការសិក្សាស្រាវជ្រាវនេះ មានចំនួនសរុប ៣០នាក់ ស្រី ១៣នាក់ មកពីវិទ្យាល័យទាំង១០ ក្នុងមួយវិទ្យាល័យមានចំនួន ៣នាក់។

- **ក្រុមអាយុ៖** អាយុចាប់ពី ៣០-៣៥ឆ្នាំ មានចំនួន ២នាក់ អាយុពី ៣៦-៤០ឆ្នាំ មានចំនួន ៧នាក់ អាយុលើសពី ៤០ឆ្នាំ មានចំនួន ២១នាក់។
- **កម្រិតវប្បធម៌៖** សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួន ៩នាក់ (៣០ភាគរយ) បរិញ្ញាបត្រ មានចំនួន ១៤នាក់(៤៦.៧០ភាគរយ) និងបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៧នាក់ (២៣.៣០ ភាគរយ)។
- **បទពិសោធន៍បង្រៀន៖** បង្រៀនចាប់ពី ៦-១០ឆ្នាំមានចំនួន ១នាក់ បង្រៀនចាប់ពី ១១-២០ឆ្នាំ មានចំនួន ១៣នាក់ និងបទពិសោធន៍បង្រៀនលើសពី ២០ឆ្នាំមានចំនួន ១៦នាក់។
- **កម្រិតថ្នាក់បង្រៀន៖** ក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមបំពេញកម្រងសំណួរសរុបមាន ចំនួន ៣០នាក់ បង្រៀនថ្នាក់ទី១០ មានចំនួន ១៣នាក់ បង្រៀនថ្នាក់ទី១១ មានចំនួន ១២នាក់ និងបង្រៀនថ្នាក់ទី១២ មានចំនួន ៥នាក់។
- **របបម៉ោងបង្រៀន៖** តាមតារាងលទ្ធផលបានបង្ហាញថា មានគ្រូបង្រៀន ចំនួន ២១ នាក់ ដែល បង្រៀនត្រឹមតែ ១-៥ម៉ោងក្នុងមួយសប្តាហ៍ ស្មើនឹងចំនួន ៧០.០០ភាគរយ ដែលជាចំនួនច្រើន ជាងគេក្នុងចំណោមគ្រូបង្រៀនដែលបានចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវនេះ។

## ៤. ២. ការវិភាគទិន្នន័យលើកម្រងសំណួរស្តីពីកម្រិតអនុវត្តនៃកម្មវិធីសិក្សា

ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវ បានធ្វើការវិភាគលើមធ្យមភាគនៃសូចនាករផ្សេងៗ របស់គណៈ គ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ទៅលើកម្រិតនៃការអនុវត្តបានរបស់កម្មវិធី សិក្សាមុខវិជ្ជា ប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ករណីសិក្សានៅវិទ្យាល័យទាំង ១០ នៅរាជធានី ភ្នំពេញ ដែលមាននៅក្នុងកម្រងសំណួរ។

### ៤. ២. ១. កម្រិតនៃការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់គណៈគ្រប់គ្រងសាលា

អំពីគណៈគ្រប់គ្រងសាលារៀន អ្នកសិក្សាស្រាវជ្រាវបានលើកយកនូវចំណុចសំខាន់ៗមួយចំនួន ដើម្បីឱ្យគណៈគ្រប់គ្រងឆ្លើយតបទៅនឹងគោលបំណងការសិក្សាស្រាវជ្រាវនេះ។ ចំណុចសំខាន់ៗទាំងនោះ រួមមាន **ការដឹកនាំ និងគ្រប់គ្រង ការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សា ការងារជាមួយគ្រូបង្រៀន ការងារ**

**ជាមួយសិស្សានុសិស្ស ការបង្រៀន និងរៀន លទ្ធផលសិក្សារបស់សិស្ស** ដើម្បីរកឱ្យឃើញថា ចំណុចទាំងអស់នេះបានជំរុញឱ្យការអនុវត្តកម្មវិធីសិក្សាបានកម្រិតណា និងមានបញ្ហាប្រឈមអ្វីខ្លះទៀតក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា។

**តារាងទី៦៖ ក. ការងារដឹកនាំ និងគ្រប់គ្រង**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | បែងចែកក្រុមបច្ចេកទេស តាមមុខវិជ្ជាបាន ត្រឹមត្រូវ | 4.50 | 0.52 | យល់ស្របខ្លាំង |
| ២ | ក្រុមបច្ចេកទេសតាមមុខវិជ្ជា បានរៀបចំ ផែនការប្រចាំខែ ប្រចាំឆ្នាំ | 4.30 | 0.67 | យល់ស្របខ្លាំង |
| ៣ | ក្រុមបច្ចេកទេសតាមមុខវិជ្ជា មានសមត្ថភាព ដឹកនាំ និងអនុវត្តការងារ | 4.10 | 0.73 | យល់ស្រប |
| ៤ | គណៈគ្រប់គ្រង បានចូលរួមប្រជុំជាមួយក្រុម បច្ចេកទេសប្រចាំខែ | 4.40 | 0.69 | យល់ស្របខ្លាំង |
| ៥ | ការអនុវត្តកម្មវិធីសិក្សា សម្រេចបានតាម ផែនការ | 4.10 | 0.56 | យល់ស្រប |
| ៦ | បំណែងចែកកម្មវិធីសិក្សា បានរៀបចំជាប្រចាំ | 3.80 | 0.91 | យល់ស្រប |
| ៧ | គ្រូបង្រៀន បានអនុវត្តការបង្រៀនតាមបំណែង ចែកកម្មវិធីសិក្សា | 4.20 | 0.63 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ៨ | ការអនុវត្តការងារនៅសាលា មានប្រសិទ្ធភាពខ្ពស់ | 3.80 | 0.63 | យល់ស្រប |
| **សរុប** | | **4.15** | **0.26** | **យល់ស្រប** |

**តាមតារាងទី៦(ក)៖** លទ្ធផលមធ្យមភាគសរុប ដែលបានបង្ហាញក្នុងតារាងខាងលើ បានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងចំណោមគណៈសាលាមកពីវិទ្យាល័យទាំង១០ ក្នុងរាជធានីភ្នំពេញ ដែលបានចូលរួមមានចំនួនសរុប ១០នាក់ ពួកគាត់បានបង្ហាញសូចនាករ **យល់ស្រប(៤.១៥)** ទៅលើការងារគ្រប់គ្រង និងដឹកនាំសាលា ពោលគឺ ពួកគាត់មានទស្សនៈវិស័យ និងគោលដៅដឹកនាំច្បាស់លាស់ មានផែនការការងារ មានការទទួលចំពោះតួនាទី ភារកិច្ចរបស់ខ្លួន បានតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ និងចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំទៅលើការអនុវត្តកម្មវិធីសិក្សាផងដែរ។

**តារាងទី៧៖ ខ. ការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សា**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ | 4.20 | 0.63 | យល់ស្រប |
| ២ | កម្មវិធីសិក្សាលម្អិតសិក្សាសង្គម សម្រាប់មធ្យមសិក្សាទុតិយភូមិ | 4.00 | 0.81 | យល់ស្រប |
| ៣ | កម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ | 3.70 | 0.82 | យល់ស្រប |
| ៤ | ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ ទី១២ | 3.90 | 0.87 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ៥ | ស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី១២ | 3.70 | 0.94 | យល់ស្រប |
| ៦ | ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និង អប់រំបច្ចេកទេស | 3.30 | 1.16 | ពុំមានយោបល់ |
| ៧ | កម្មវិធីសិក្សាលម្អិតប្រវត្តិវិទ្យា សម្រាប់មធ្យម សិក្សាទុតិយភូមិ | 3.90 | 0.87 | យល់ស្រប |
| ៨ | សៀវភៅសិក្សាគោល(សៀវភៅសិស្ស) | 4.20 | 0.63 | យល់ស្រប |
| ៩ | សៀវភៅគ្រូ | 4.00 | 0.66 | យល់ស្រប |
| **សរុប** | | **3.88** | **0.28** | **យល់ស្រប** |

**តាមតារាងទី៧(ខ)៖** ទិន្នន័យមធ្យមភាគសរុប **៣.៨៨** ស្ថិតនៅក្នុងកម្រិតវាស់វែង **យល់ស្រប** ដែលគណៈគ្រប់គ្រងសាលាបានចូលរួមឆ្លើយទៅលើការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សាបង្ហាញថា គណៈគ្រប់គ្រងសាលាទាំង១០ នៅរាជធានីភ្នំពេញ បានយកចិត្តទុកដាក់ជំរុញការអនុវត្តកម្មវិធីសិក្សា ដែលផ្តោតទៅលើការប្រើប្រាស់ឯកសារណែនាំផ្សេងៗ ក្នុងការធានាឱ្យការអនុវត្តកម្មវិធីសិក្សាទទួលបានជោគជ័យ សាលាវិទ្យាល័យទាំង១០ បានប្រើប្រាស់ឯកសារគោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ មានតម្លៃមធ្យមភាគ ៤.២០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។ ការប្រើប្រាស់ឯកសារជំនួយ ក្នុងការអនុវត្តកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតសិក្សាសង្គម សម្រាប់មធ្យមសិក្សាទុតិយភូមិ មានតម្លៃមធ្យមភាគ ៤.០០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។ ការប្រើប្រាស់ ឯកសារស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី១២ មានតម្លៃមធ្យមភាគ ៣.៧០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។ ប្រើប្រាស់កម្មវិធីសិក្សាលម្អិត មុខវិជ្ជាប្រវត្តិវិទ្យា សម្រាប់មធ្យមសិក្សាទុតិយភូមិ មានតម្លៃមធ្យមភាគ ៣.៩០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប ។ ការប្រើប្រាស់សៀវភៅសិក្សាគោល មានតម្លៃមធ្យមភាគ ៤.២០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។ ការប្រើប្រាស់សៀវភៅគ្រូ មានតម្លៃមធ្យមភាគ ៤.០០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។

ដោយឡែកមានតែឯកសារស្តីពីក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ដែលមានមធ្យមភាគទាបជាងគេគឺ ៣.៣០ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់។

**តារាងទី៨៖ គ. ការងារបង្រៀន និងរៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ការបង្រៀន និងរៀន បានអនុវត្តតាមកម្មវិធីសិក្សា | 4.10 | 0.87 | យល់ស្រប |
| ២ | គ្រូបង្រៀនបានប្រើប្រាសវិធីសាស្រ្តសម្បូរបែប ដើម្បីសម្រេចវត្ថុបំណងមេរៀន | 3.80 | 0.42 | យល់ស្រប |
| ៣ | គ្រូបង្រៀនបានបង្កើតបរិស្ថានសិក្សាសមស្របសម្រាប់ការបង្រៀន និងរៀន | 3.80 | 0.42 | យល់ស្រប |
| ៤ | បង្កបរិយាកាសសិក្សាល្អ ដើម្បីធានាឱ្យសិស្សមានវត្តមានទៀងទាត់ | 3.90 | 0.56 | យល់ស្រប |
| ៥ | គ្រូបង្រៀនបានលើកទឹកចិត្តសិស្សជាប្រចាំឱ្យខិតខំរៀនសូត្រ | 4.00 | 0.81 | យល់ស្រប |
| ៦ | គ្រូបានបន្តកែលម្អការបង្រៀនរបស់ខ្លួនជាប្រចាំ | 3.30 | 0.82 | ពុំមានយោបល់ |
| **សរុប** | | **3.82** | **0.28** | **យល់ស្រប** |

**តាមតារាងទី៨(គ)៖** ដំណើរការបង្រៀន និងរៀន ដែលជាផ្នែកមួយយ៉ាងសំខាន់ទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា យោងតាមលទ្ធផលបានបង្ហាញថា គណៈគ្រប់គ្រងសាលារៀន ក៏បានយល់ស្រប ដោយមានមានការពិនិត្យតាមដានទៅលើការបង្រៀន និងរៀនរបស់គ្រូស្របតាមកម្មវិធីសិក្សា(មធ្យមភាគ ៤.១០=

កម្រិតយល់ស្រប) ការប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែបរបស់គ្រូ ដើម្បីឱ្យសម្រេចនូវវត្ថុបំណងមេរៀន(មធ្យមភាគ ៣.៨៨=កម្រិតយល់ស្រប) ការបង្កើតបរិស្ថានសិក្សាសមស្របសម្រាប់ការបង្រៀន និងរៀន(មធ្យមភាគ ៣.៨០=កម្រិតយល់ស្រប) ការបង្កបរិយាកាសល្អ ដើម្បីជានាឱ្យសិស្សមានវត្តមានទៀងទាត់នៅក្នុងការសិក្សា(មធ្យមភាគ ៣.៩០=កម្រិតយល់ស្រប) គ្រូបង្រៀនបានលើកទឹកចិត្តសិស្សឱ្យខិតខំសិក្សារៀនសូត្រជាប្រចាំ(មធ្យមភាគ ៤.០០=កម្រិតយល់ស្រប)។ ប៉ុន្តែមានចំណុចមួយដែលមានមធ្យមភាគទាបជាងគេគឺ គ្រូបានកែលម្អការបង្រៀនរបស់ជាប្រចាំ(មធ្យមភាគ ៣.៣០=ពុំមានយោបល់) ហើយ **សរុបមធ្យមភាគរួមគឺ ៣.៨២ (កម្រិតយល់ស្រប)។** ប្រការនេះ បានសេចក្តីថា គណៈគ្រប់គ្រងសាលា នៅមានកម្រិតក្នុងការយកចិត្តទុកដាក់ លើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ជាពិសេសលើដំណើការបង្រៀន និងរៀនរបស់គ្រូ។

**តារាងទី៩៖ ឃ. លទ្ធផលសិក្សារបស់សិស្ស**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | លទ្ធផលសិក្សារបស់សិស្ស មុខវិជ្ជាប្រវត្តិវិទ្យារីកចម្រើនជាបន្តបន្ទាប់ | 3.30 | 0.82 | ពុំមានយោបល់ |
| ២ | តេស្តវង្វាយតម្លៃការសិក្សារបស់សិស្សស្របតាមស្តង់ដា | 3.40 | 0.84 | ពុំមានយោបល់ |
| ៣ | គ្រូបានវាយតម្លៃការសិក្សារបស់សិស្សតាមដំណាក់ | 4.00 | 0.47 | យល់ស្រប |
| ៤ | ការប្រឡងធ្វើឡើងដោយត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព | 4.00 | 0.66 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ៥ | លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរបស់សិស្ស លើមុខវិជ្ជាប្រវត្តិវិទ្យា នាឆ្នាំកន្លងមកទទួលបានលទ្ធផលល្អ | 3.80 | 0.42 | យល់ស្រប |
| **សរុប** | | 3.7 | 0.33 | **យល់ស្រប** |

**តាមតារាងទី៩(ឃ)៖** លទ្ធផលសិក្សារបស់សិស្ស **សរុបមធ្យមភាគគឺ ៣.៧០ (កម្រិតយល់ស្រប)** ប៉ុន្តែចំពោះលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាប្រវត្តិវិទ្យា(មធ្យមភាគ ៣.៣០=ពុំមានយោបល់) និងការធ្វើតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សស្របតាមស្តង់ដា(មធ្យមភាគ ៣.៤០=ពុំមានយោបល់) តាមរយៈកម្រិតនៃការវាស់វែងនេះ បានបង្ហាញថា គណៈគ្រប់គ្រងសាលាមិនទាន់បានរៀបចំនូវប្រព័ន្ធតាមដានការសិក្សារបស់សិស្ស ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សឱ្យមានប្រសិទ្ធភាព ឆ្លើយតបនឹកាការអនុវត្តកម្មវិធីសិក្សាលើមុខវិជ្ជាប្រវត្តិវិទ្យានៅឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាមធ្យមភាគរួមគឺ ៣.៧០(កម្រិតយល់ស្រប) ដោយផ្អែកទៅលើដំណើរការវាយតម្លៃការសិក្សារបស់សិស្សតាមដំណាក់(មធ្យមភាគ ៤.០០=កម្រិតយល់ស្រប) ការប្រឡងធ្វើឡើងដោយត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព(មធ្យមភាគ ៤.០០=កម្រិតយល់ស្រប) ចំណែកលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើមុខវិជ្ជា ប្រវត្តិវិទ្យា នាឆ្នាំកន្លងមកទទួលបានលទ្ធផលល្អ(មធ្យមភាគ ៣.៨០=កម្រិតយល់ស្រប) ក៏គណៈគ្រប់គ្រងសាលាគួរតែផ្តោតទៅលើដំណើរកាបង្រៀន និងរៀន ភាពច្បាស់លាស់នៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សស្របតាមស្តង់ដា។

### ៤. ២. ២. លទ្ធផលស្រាវជ្រាវលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា

នៅក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទិន្នន័យមធ្យមរួម ទៅលើកម្រិតនៃការអនុវត្តបាននៃកម្មវិធីសិក្សា និងបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា តាមទស្សនៈរបស់គណៈគ្រប់គ្រងសាលារៀនពាក់ព័ន្ធទៅនឹងការងារសំខាន់ៗដូចជា៖ ការងារដឹកនាំ និងគ្រប់គ្រង ការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សា ការងារបង្រៀន និងរៀន លទ្ធផលសិក្សារបស់សិស្សដែលសាលាបានធ្វើនាពលកន្លងមក និងបន្តធ្វើការកែលម្អទៅថ្ងៃអនាគត។

**តារាងទី១០៖ មធ្យមភាគសរុបរួមរបស់គណៈគ្រប់គ្រងសាលារៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ក | ការងារដឹកនាំ និងគ្រប់គ្រង | 4.15 | 0.26 | ល្អ |
| ខ | ការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សា | 3.88 | 0.28 | ល្អ |
| គ | ការងារបង្រៀន និងរៀន | 3.82 | 0.28 | ល្អ |
| ឃ | លទ្ធផលសិក្សារបស់សិស្ស | 3.7 | 0.33 | ល្អ |
| **សរុប** | | **3.89** | **0.19** | **ល្អ** |

**តាមតារាងទី១០៖** លទ្ធផលវិភាគលើមធ្យមភាគបានបង្ហាញថា គណៈគ្រប់គ្រងសាលារៀនចំនួន ១០នាក់មកពីវិទ្យាល័យនៅរាជធានីភ្នំពេញ បានយល់ស្របទៅលើចំណុចដូចជា៖ ការងារដឹកនាំ និងគ្រប់គ្រង (មធ្យមភាគ ៤.១៥=ល្អ) ការចូលរួមគាំទ្រអនុវត្តកម្មវិធីសិក្សា(មធ្យមភាគ ៣.៨៨=ល្អ) ការងារបង្រៀន និងរៀន(មធ្យមភាគ ៣.៨២=ល្អ) ចំណែកឯសូចនាករ លទ្ធផលសិក្សារបស់សិស្ស ជាចំណុចដែលមានមធ្យមភាគទាបជាងគេគឺ(មធ្យមភាគ ៣.៧=ល្អ)។

### ៤. ២. ៣. កម្រិតនៃការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់ប្រធានក្រុមបច្ចេកទេស

ក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តោតទៅលើចំណុចសំខាន់ៗ ពាក់ព័ន្ធនឹងប្រធានក្រុមបច្ចេកទេសដូចជា៖ ការងារប្រតិបត្តិជាប្រធានក្រុមបច្ចេកទេស ការត្រួតពិនិត្យការងារបង្រៀន និងការរៀនរបស់សិស្ស និងលោកគ្រូ អ្នកគ្រូដែលជាសមាជិកក្រុមបច្ចេកទេស ក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យានៅកម្រិតមធ្យមសិក្សាទុតិយភូមិនាពេលកន្លងមក អនុវត្តបានកម្រិតណា។

**តារាងទី១១៖ ក. ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | រៀបចំផែនការការងារក្រុមបច្ចេកទេសបានជាប្រចាំ | 4.20 | 0.91 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ២ | ដឹកនាំការប្រជុំក្រុមបច្ចេកទេសប្រចាំខែ | 4.40 | 0.51 | យល់ស្របខ្លាំង |
| ៣ | ការប្រជុំក្រុមបច្ចេកទេសផ្តោតលើវិធីសាស្ត្របង្រៀន | 4.20 | 0.63 | យល់ស្រប |
| ៤ | ការប្រជុំក្រុមបច្ចេកទេសផ្តោតលើរដ្ឋបាលនិងការគ្រប់គ្រងថ្នាក់រៀន | 3.90 | 0.99 | យល់ស្រប |
| ៥ | ការប្រជុំក្រុមបច្ចេកទេសផ្តោតលើការរៀបចំកិច្ចតែងការបង្រៀន | 4.40 | 0.51 | យល់ស្របខ្លាំង |
| ៦ | ការប្រជុំក្រុមបច្ចេកទេសធ្វើឡើងតាមលំនាំការសិក្សាស្រាវជ្រាវមេរៀន | 3.80 | 1.03 | យល់ស្រប |
| ៧ | ការប្រជុំក្រុមបច្ចេកទេសផ្តោតលើការដឹកនាំធ្វើថ្នាក់និទស្សន៍ | 4.20 | 0.91 | យល់ស្រប |
| ៨ | ការប្រជុំក្រុមបច្ចេកទេសផ្តោតលើការផលិតសម្ភារឧបទេសបង្រៀន | 3.40 | 1.35 | ពុំមានយោបល់ |
| ៩ | សមាជិកបានចូលរួមគ្រប់គ្នាពេលប្រជុំក្រុមបច្ចេកទេស | 3.80 | 1.31 | យល់ស្រប |
| **សរុប** | | **4.03** | **0.33** | **យល់ស្រប** |

**តាមតារាងទី១១(ក)៖** លទ្ធផលក្នុងតារាងខាងលើនេះ គឺបានបង្ហាញអំពីការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេស ដែលមានមធ្យមភាគសរុប ៤.០៣ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។ ក្នុងចំណោមប្រធានក្រុមបច្ចេកទេស ១០នាក់ បានបំពេញការងាររបស់ខ្លួនក្នុងការអនុវត្តកម្មវិធីសិក្សា ដែលផ្តោតលើចំណុចលម្អិតផ្សេងៗដូចជា៖ ការរៀបចំផែនការការងារក្រុមបច្ចេកទេស មានមធ្យមភាគចំនួន(៤.២០=

យល់ស្រប) ការដឹកនាំប្រជុំក្រុមបច្ចេកទេសប្រចាំខែ ដែលមានមធ្យមភាគខ្ពស់ជាងគេគឺ(៤.៤០=យល់ស្របខ្លាំង)។ ដោយឡែកចំណុចដែលមានមធ្យមភាគទាបជាងគេ នៅក្នុងការងារប្រតិបត្តិរបស់ក្រុមបច្ចេកទេស គឺទាក់ទងទៅនឹងការងារប្រជុំក្រុមបច្ចេកទេសផ្តោតទៅលើការផលិតសម្ភារឧបទេសក្នុងការបង្រៀន និងរៀន(៣.៤០=ពុំមានយោបល់)។

**តារាងទី១២៖ ខ. ការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ការបង្រៀនរបស់សមាជិកក្រុមគ្រប់ៗគ្នា | 4.50 | 0.52 | យល់ស្របខ្លាំង |
| ២ | ការកែលម្អការបង្រៀនរបស់គ្រូ | 3.90 | 0.73 | យល់ស្រប |
| ៣ | វិធីសាស្ត្របង្រៀន | 4.40 | 0.51 | យល់ស្របខ្លាំង |
| ៤ | ការរៀបចំកិច្ចតែងការបង្រៀន និងរដ្ឋបាលគ្រូបង្រៀន | 4.40 | 0.51 | យល់ស្របខ្លាំង |
| ៥ | ការគ្រប់គ្រងថ្នាក់រៀន វិន័យ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន | 4.20 | 0.91 | យល់ស្រប |
| ៦ | ការអនុវត្តកម្មវិធីសិក្សា | 4.40 | 0.51 | យល់ស្របខ្លាំង |
| ៧ | ការប្រើប្រាស់សម្ភារឧបទេស ក្នុងការបង្រៀន និងរៀន | 3.80 | 1.03 | យល់ស្រប |
| ៨ | ការបង្កើតបរិស្ថានសិក្សាល្អ ឱ្យសិស្សខិតខំរៀនសូត្រ | 4.30 | 0.67 | យល់ស្របខ្លាំង |
| ៩ | ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបន្ថែម | 3.90 | 0.87 | យល់ស្រប |

| សរុប | 4.2 | 0.26 | យល់ស្រប |
|---|---|---|---|

**តាមតារាងទី១២(ខ)៖** លទ្ធផលក្នុងតារាងបង្ហាញថា ក្នុងចំណោមប្រធានក្រុមបច្ចេកទេសចំនួន ១០នាក់ មានការយល់ស្របទៅលើ ការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ នៅក្នុងវិទ្យាល័យចំនួន ១០ នៅរាជធានីភ្នំពេញ ផ្អែកតាមចំណុចលម្អិតនៃសូចនាករនីមួយៗដូចតទៅ៖ ការបង្រៀនរបស់សមាជិកក្រុមគ្រប់ៗគ្នា (មធ្យមភាគ ៤.៥០=យល់ស្របខ្លាំង) ការកែលម្អការបង្រៀនរបស់គ្រូ(មធ្យមភាគ ៣.៩០=យល់ស្រប) វិធីសាស្ត្របង្រៀន(មធ្យមភាគ ៤.៤០=យល់ស្របខ្លាំង) ការរៀបចំកិច្ចតែងការបង្រៀន និងរដ្ឋបាលគ្រូបង្រៀន(មធ្យមភាគ ៤.៤០=យល់ស្របខ្លាំង) ការគ្រប់គ្រងថ្នាក់រៀន វិន័យ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន (មធ្យមភាគ ៤.២០=យល់ស្រប) ការអនុវត្តកម្មវិធីសិក្សា(មធ្យមភាគ ៤.៤០=យល់ស្របខ្លាំង) ការបង្កើតបរិស្ថានសិក្សាល្អ ឱ្យសិស្សខិតខំរៀនសូត្រ(មធ្យមភាគ ៤.៣០=យល់ស្របខ្លាំង)។ ក្នុងចំណោមចំណុចចំនួន ៩ ដែលមានមធ្យមភាគទាបជាងគេគឺ ការប្រើប្រាស់សម្ភារឧបទេស ក្នុងការបង្រៀន និងរៀន(មធ្យមភាគ ៣.៨០=យល់ស្រប)។

### ៤. ២. ៤. លទ្ធផលស្រាវជ្រាវលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា

ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីកម្រិតនៃការអនុវត្តកម្មវិធីសិក្សា ដែលបានផ្តោតទៅលើសូចនាករសំខាន់ៗដែលប្រធានក្រុម បានដឹកនាំក្រុមបច្ចេកទេស ក្នុងការអនុវត្តកម្មវិធីសិក្សា ការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលនៃការបំពេញការងារនាពេលកន្លងមក។

**តារាងទី១៣៖ មធ្យមភាគសរុបរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ក | ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេស | 4.03 | 0.33 | ល្អ |
| ខ | ការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ | 4.2 | 0.26 | ល្អ |
| **សរុប** | | **4.12** | **0.12** | **ល្អ** |

**តាមតារាងទី១៣៖** លទ្ធផលក្នុងតារាងបានបង្ហាញថា ប្រធានក្រុមបច្ចេកទេស បានបំពេញការងារប្រតិបត្តិតាមតួនាទីរបស់ខ្លួន និងការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ ក្នុងការចូលរួមចំណែកជំរុញការអនុវត្តកម្មវិធីសិក្សា ដែលបង្ហាញឡើងតាមចំណុចសំខាន់ៗដូចជា៖ ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេសដែលមានមធ្យមភាគ ៤.០៣(ល្អ) ការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ មានមធ្យមភាគ ៤.២(ល្អ)។ ចំពោះមធ្យមភាគសរុបរួម ស្តីពីកម្រិតអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់ប្រធានក្រុមបច្ចេកទេសគឺ ៤.១២ ដែលស្ថិតនៅក្នុងកម្រិតវាស់វែងយល់ស្រប(**ល្អ**)។ តាមរយៈលទ្ធផលនេះបង្ហាញថា ប្រធានក្រុមបច្ចេកទេសបានបំពេញការងារប្រតិបត្តិ និងត្រួតពិនិត្យការងាររបស់គ្រូបង្រៀនបានក្នុងកម្រិតល្អ។

### ៤. ២. ៥. កម្រិតនៃការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈរបស់គ្រូបង្រៀន

ក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តោតលើចំណុចសំខាន់ៗ ពាក់ព័ន្ធនឹងគ្រូបង្រៀនដូចជា៖ ការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា ដំណើរការបង្រៀន និងការរៀន ការប្រើប្រាស់សម្ភារឧបទេសបង្រៀន ទំនាក់ទំនងរវាងសិស្ស និងគ្រូ គ្រូបង្រៀន និងសិស្ស ដែលក្នុងនាមជាគ្រូបង្រៀនបានប្រតិបត្តិនាពេលកន្លងមក ដើម្បីជានាបាននូវការអនុវត្តកម្មវិធីសិក្សាទទួលបានគុណភាព និងប្រសិទ្ធភាព លោកគ្រូអ្នកគ្រូបានអនុវត្តកម្មវិធីសិក្សាបានកម្រិតណានាពេលកន្លងមក។

**តារាងទី១៤៖ ក. ការអនុវត្តកម្មវិធីសិក្សា**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | បង្រៀនចប់កម្មវិធីសិក្សា តាមការណែនាំរបស់ក្រសួងអប់រំ | 3.70 | 1.02 | យល់ស្រប |
| ២ | រៀបចំបំណែងចែកកម្មវិធីសិក្សាប្រចាំត្រីមាស ប្រចាំឆ្នាំ | 4.43 | 0.56 | យល់ស្របខ្លាំង |
| ៣ | ចូលរួមការប្រជុំក្រុមបច្ចេកទេសជាទៀងទាត់ | 4.47 | 0.68 | យល់ស្របខ្លាំង |

| | | | | |
|---|---|---|---|---|
| ៤ | រៀបចំកិច្ចតែងការបង្រៀនគ្រប់មេរៀនជាប្រចាំ | 4.40 | 0.67 | យល់ស្របខ្លាំង |
| ៥ | ការបង្រៀន បានប្រើប្រាស់សៀវភៅគ្រូ សៀវភៅសិស្សជាប្រចាំ | 4.43 | 0.67 | យល់ស្របខ្លាំង |
| ៦ | គ្រប់គ្រងពេលវេលាបង្រៀនបានត្រឹមត្រូវតាមបំណែងចែកកម្មវិធីសិក្សា | 4.23 | 0.89 | យល់ស្របខ្លាំង |
| ៧ | ប្រើប្រាស់ឯកសារជំនួយក្នុងការអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវ | 4.10 | 0.60 | យល់ស្រប |
| ៨ | សៀវភៅសម្រង់អត្ថបទមានសារៈសំខាន់ និងបានប្រើជាប្រចាំ | 4.37 | 0.55 | យល់ស្របខ្លាំង |
| ៩ | បង្រៀនតាមកាលវិភាគ និងម៉ោងកំណត់ជាប្រចាំ | 4.37 | 0.66 | យល់ស្របខ្លាំង |
| ១០ | មានសៀវភៅណែនាំគ្រូ អាចជួយឱ្យការរៀបចំកិច្ចតែងការបង្រៀនបានល្អ | 4.20 | 0.96 | យល់ស្រប |
| **សរុប** | | **4.27** | **0.23** | **យល់ស្របខ្លាំង** |

**តាមតារាងទី១៤(ក)៖** លទ្ធផលក្នុងតារាងខាងលើនេះ បានបង្ហាញថាការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូបង្រៀនដោយមានមធ្យមភាគសរុបគឺ ៤.២៧ ដែលស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្របខ្លាំង។ ក្នុងចំណោមគ្រូបង្រៀនសរុប ៣០នាក់ មកពីវិទ្យាល័យចំនួន ១០នៅរាជធានីភ្នំពេញ បានឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីសិក្សាផ្តោតលើចំណុចលម្អិតសំខាន់ៗដូចជា៖ បង្រៀនចប់កម្មវិធីសិក្សា តាមការណែនាំរបស់ក្រសួងអប់រំ មានមធ្យមភាគចំនួន(៣.៧០=យល់ស្រប) រៀបចំបំណែងចែកកម្មវិធីសិក្សាប្រចាំត្រី

មាស ប្រចាំឆ្នាំ មានមធ្យមភាគចំនួន(៤.៤៣=យល់ស្របខ្លាំង) ចូលរួមការប្រជុំក្រុមបច្ចេកទេសជាទៀងទាត់ មានមធ្យមភាគចំនួន(៤.៤៧=យល់ស្របខ្លាំង) រៀបចំកិច្ចតែងការបង្រៀនគ្រប់មេរៀនជាប្រចាំ មានមធ្យមភាគចំនួន(៤.៤០=យល់ស្របខ្លាំង) ការបង្រៀន បានប្រើប្រាស់សៀវភៅគ្រូ សៀវភៅសិស្សជាប្រចាំ មានមធ្យមភាគចំនួន(៤.៤៣=យល់ស្របខ្លាំង) គ្រប់គ្រងពេលវេលាបង្រៀនបានត្រឹមត្រូវ តាមបំណែងចែកកម្មវិធីសិក្សា មានមធ្យមភាគចំនួន(៤.២៣=យល់ស្របខ្លាំង) ប្រើប្រាស់ឯកសារជំនួយក្នុងការអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវ មានមធ្យមភាគចំនួន(៤.១០=យល់ស្រប) សៀវភៅសម្រង់អត្ថបទមានសារៈសំខាន់ និងបានប្រើជាប្រចាំ មានមធ្យមភាគចំនួន(៤.៣៧=យល់ស្របខ្លាំង) បង្រៀនតាមកាលវិភាគ និងម៉ោងកំណត់ជាប្រចាំ មានមធ្យមភាគចំនួន(៤.៣៧=យល់ស្របខ្លាំង) មានសៀវភៅណែនាំគ្រូអាចជួយឱ្យការរៀបចំកិច្ចតែងការបង្រៀនបានល្អ មានមធ្យមភាគចំនួន(៤.១០=យល់ស្រប)។ ចំណែកឯមធ្យមភាគសរុបរួមគឺ ៤.២៧ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្របខ្លាំង។

**តារាងទី១៥៖ ខ. ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ | 3.77 | 0.72 | យល់ស្រប |
| ២ | កម្មវិធីសិក្សាលម្អិតសិក្សាសង្គម សម្រាប់មធ្យមសិក្សាទុតិយភូមិ | 3.83 | 0.74 | យល់ស្រប |
| ៣ | កម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ | 3.77 | 0.67 | យល់ស្រប |
| ៤ | ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ ទី១២ | 3.87 | 1.00 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ៥ | ស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី១២ | 4.23 | 0.77 | យល់ស្របខ្លាំង |
| ៦ | ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស | 3.83 | 0.69 | យល់ស្រប |
| ៧ | កម្មវិធីសិក្សាលម្អិតប្រវត្តិវិទ្យា សម្រាប់មធ្យមសិក្សាទុតិយភូមិ | 4.07 | 0.78 | យល់ស្រប |
| ៨ | សៀវភៅសិក្សាគោល(សៀវភៅសិស្ស) | 4.37 | 0.55 | យល់ស្របខ្លាំង |
| ៩ | សៀវភៅគ្រូ | 4.33 | 0.66 | យល់ស្របខ្លាំង |
| **សរុប** | | **4.01** | **0.25** | **យល់ស្រប** |

**តាមតារាងទី១៥(ខ)៖** លទ្ធផលក្នុងតារាងខាងលើនេះ បង្ហាញថាក្នុងចំណោមគ្រូបង្រៀនចំនួន ៣០នាក់ មានការយល់ស្របទៅលើ ការប្រើប្រាស់ឯកសារណែនាំ គាំទ្រដល់ការអនុវត្តកម្មវិធីសិក្សា ទៅតាមចំណុចសំខាន់ៗដូចតទៅ៖ គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ(មធ្យមភាគ ៣.៧៧=យល់ស្រប) កម្មវិធីសិក្សាលម្អិតសិក្សាសង្គម សម្រាប់មធ្យមសិក្សាទុតិយភូមិ(មធ្យមភាគ ៣.៨៣=យល់ស្រប) កម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ(មធ្យមភាគ ៣.៧៧=យលស្រប) ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ ទី១២(មធ្យមភាគ ៣.៨៧=យល់ស្រប) ស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី១២(មធ្យមភាគ ៤.២៣=យល់ស្របខ្លាំង) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស(មធ្យមភាគ ៣.៨៣=យល់ស្រប) កម្មវិធីសិក្សាលម្អិតប្រវត្តិវិទ្យាសម្រាប់មធ្យមសិក្សាទុតិយភូមិ(មធ្យមភាគ ៤.០៧=យល់ស្រប) សៀវភៅសិក្សាគោល(មធ្យមភាគ ៤.៣៧=យល់ស្របខ្លាំង) សៀវភៅគ្រូ(មធ្យមភាគ ៤.៣៣=យល់ស្របខ្លាំង)។ ដោយឡែកបើមើលលើមធ្យមភាគសរុបជារួមគឺ ៤.០១ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។

**តារាងទី១៦៖ គ. ដំណើរការបង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | មានសមត្ថភាពចំណេះដឹង ជំនាញ និងវិធីសាស្ត្របង្រៀនគ្រប់គ្រាន់ | 4.20 | 0.76 | យល់ស្រប |
| ២ | បង្រៀនត្រូវតាមឯកទេស ដែលបានទទួលការបណ្តុះបណ្តាល | 4.37 | 0.71 | យល់ស្របខ្លាំង |
| ៣ | ខ្លឹមសារមេរៀន មានភាពងាយស្រួលក្នុងការបង្រៀន | 3.77 | 0.93 | យល់ស្រប |
| ៤ | បានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ | 4.23 | 0.77 | យល់ស្របខ្លាំង |
| ៥ | ដំណើរការបង្រៀនបានអនុវត្តគ្រប់ជំហានទាំង៥ តាមកិច្ចតែងការបង្រៀន | 4.37 | 0.66 | យល់ស្របខ្លាំង |
| ៦ | កិច្ចតែងការបានធ្វើឱ្យមានភាពល្អប្រសើរក្នុងការបង្រៀន និងរៀន | 4.30 | 0.79 | យល់ស្របខ្លាំង |
| ៧ | មានរៀបចំសៀវភៅសម្រង់អត្ថបទ ជាប្រចាំក្នុងការបង្រៀន | 4.33 | 0.66 | យល់ស្របខ្លាំង |
| ៨ | មានសៀវភៅសម្រង់អវត្តមានសិស្សជាប្រចាំ | 4.50 | 0.57 | យល់ស្របខ្លាំង |
| ៩ | មានរៀបចំសៀវភៅពិន្ទុសិស្សបានត្រឹមត្រូវ | 4.43 | 0.62 | យល់ស្របខ្លាំង |
| ១០ | វិធីសាស្ត្របង្រៀន ជួយឱ្យការអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវ | 4.20 | 0.80 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ១១ | មានការវាយតម្លៃការសិក្សារបស់សិស្សតាមដំណាក់ | 4.07 | 0.78 | យល់ស្រប |
| **សរុប** | | **4.25** | **0.20** | **យល់ស្របខ្លាំង** |

**តាមតារាងទី១៦(គ)៖** ដំណើរការបង្រៀនមានមធ្យមភាគរួមសរុប ៤.២៥ ដែលស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្របខ្លាំង។ ក្នុងចំណោមគ្រូបង្រៀនសរុប ៣០នាក់ បានបង្ហាញទស្សនៈឆ្លើយតបនឹងចំណុចលម្អិតដូចតទៅ៖ គ្រូបង្រៀនមានសមត្ថភាពចំណេះដឹង ជំនាញ និងវិធីសាស្ត្របង្រៀនគ្រប់គ្រាន់(មធ្យមភាគ ៤.២០=យល់ស្រប) បង្រៀនត្រូវតាមឯកទេស ដែលបានទទួលការបណ្តុះបណ្តាល(មធ្យមភាគ ៤.៣៧=យល់ស្របខ្លាំង) ខ្លឹមសារមេរៀន មានភាពងាយស្រួលក្នុងការបង្រៀន(មធ្យមភាគ ៣.៧៧=យល់ស្រប) បានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ(មធ្យមភាគ ៤.២៣=យល់ស្របខ្លាំង) ដំណើរការបង្រៀនបានអនុវត្តគ្រប់ជំហានទាំង៥ តាមកិច្ចតែងការបង្រៀន(មធ្យមភាគ ៤.៣៧=យល់ស្របខ្លាំង) កិច្ចតែងការបានធ្វើឱ្យមានភាពល្អប្រសើរក្នុងការបង្រៀន និងរៀន(មធ្យមភាគ ៤.៣០=យល់ស្របខ្លាំង) មានរៀបចំសៀវភៅសម្រង់អត្ថបទ ជាប្រចាំក្នុងការបង្រៀន(មធ្យមភាគ ៤.៣៣=យល់ស្របខ្លាំង) មានសៀវភៅសម្រង់អវត្តមានសិស្សជាប្រចាំ(មធ្យមភាគ ៤.៥០=យល់ស្របខ្លាំង) មានរៀបចំសៀវភៅពិន្ទុសិស្សបានត្រឹមត្រូវ(មធ្យមភាគ ៤.៤៣=យល់ស្របខ្លាំង) វិធីសាស្ត្របង្រៀន ជួយឱ្យការអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវ(មធ្យមភាគ ៤.២០=យល់ស្រប) មានការវាយតម្លៃការសិក្សារបស់សិស្សតាមដំណាក់(មធ្យមភាគ ៤.០៧=យល់ស្រប)។

**តារាងទី១៧៖ ឃ. ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន**

| **ល.រ** | **បរិយាយ** | **មធ្យម** | **គម្លាតស្តង់ដា** | **កម្រិតវាស់វែង** |
|---|---|---|---|---|
| ១ | បានប្រើប្រាស់សម្ភារឧបទេសជំនួយការបង្រៀនជាប្រចាំ | 3.93 | 0.78 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ២ | សម្ភារៈឧបទ្ទេស បានជួយឱ្យសិស្សងាយស្រួលក្នុងការយល់ខ្លឹមសារ | 4.23 | 0.72 | យល់ស្របខ្លាំង |
| ៣ | សម្ភារឧបទេសធ្វើឱ្យចំណេញពេលវេលា និងទាក់ទាញអារម្មណ៍សិស្ស | 4.23 | 0.72 | យល់ស្របខ្លាំង |
| ៤ | មានឯកសារជំនួយបន្ថែមក្នុងការបង្រៀនគ្រប់គ្រាន់ | 3.97 | 0.76 | យល់ស្រប |
| ៥ | ចេះផលិត និងប្រើប្រាស់សម្ភារឧបទេសបង្រៀនបានត្រឹមត្រូវ | 3.70 | 0.87 | យល់ស្រប |
| ៦ | មានសម្ភារឧបទេសគ្រប់គ្រាន់ដើម្បីជំនួយការបង្រៀន និងរៀន | 4.03 | 0.76 | យល់ស្រប |
| ៧ | មានសៀវភៅសិស្ស សៀវភៅគ្រូគ្រប់គ្រាន់ក្នុងការបង្រៀន និងរៀន | 4.20 | 0.92 | យល់ស្រប |
| ៨ | ប្រើប្រាស់បច្ចេកវិទ្យាបម្រើឱ្យការបង្រៀន និងរៀន | 3.80 | 0.96 | យល់ស្រប |
| **សរុប** | | **4.01** | **0.20** | **យល់ស្រប** |

**តាមតារាងទី១៧(ឃ)៖** ការប្រើប្រាស់សម្ភារឧបទេសជំនួយក្នុងការបង្រៀន និងរៀន ក្នុងចំណោមលោកគ្រូ អ្នកគ្រូបង្រៀនចំនួន ៣០នាក់ មធ្យមភាគសរុបរួមគឺ ៤.០១ បង្ហាញពីកម្រិតវាស់វែង យល់ស្រប។ ក្នុងចំណោមសូចនាករវាស់វែងចំនួន ៨ចំណុចសំខាន់ៗគឺ បានប្រើប្រាស់សម្ភារឧបទេសជំនួយការបង្រៀន និងរៀនជាប្រចាំ(មធ្យមភាគ ៣.៩៣=យល់ស្រប) ចំណែកឯសម្ភារៈឧបទេស បានជួយឱ្យសិស្សងាយស្រួលក្នុងការយល់ខ្លឹមសារ និងសម្ភារឧបទេសធ្វើឱ្យចំណេញពេលវេលា និងទាក់ទាញអារម្មណ៍សិស្ស

មានកម្រិតមធ្យមភាគខ្ពស់ជាងគេ( មធ្យមភាគ ៤.២៣=យល់ស្របខ្លាំង។ ដោយឡែកសូចនាករដទៃទៀត ដែលមានកម្រិតវាស់វែងត្រឹមតែ កម្រិតយល់ស្រប មានតែចំណុចស្តីពី ការចេះផលិត និងប្រើប្រាស់សម្ភារឧបទេសបង្រៀនបានត្រឹមត្រូវ ដែលមានកម្រិតមធ្យមភាគទាបជាងគេគឺ ៣.៧០។

**តារាងទី១៨៖ ង. ទំនាក់ទំនងគ្រូ-សិស្ស**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | គ្រូ និងសិស្សមានទំនាក់ទំនងល្អក្នុងដំណើរការបង្រៀន និងរៀន | 4.43 | 0.56 | យល់ស្របខ្លាំង |
| ២ | សិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរបង្រៀន និងរៀន | 3.83 | 0.87 | យល់ស្រប |
| ៣ | ការឆ្លើយតប និងបកស្រាយចម្ងល់សិស្សបានក្បោះក្បាយ | 4.07 | 0.78 | យល់ស្រប |
| ៤ | បានជំរុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា | 4.43 | 0.56 | យល់ស្របខ្លាំង |
| ៥ | បង្កើតបរិស្ថានសិក្សាល្អ ធានាឱ្យសិស្សទទួលបានការរៀនសូត្រដូចៗគ្នា | 4.23 | 0.77 | យល់ស្របខ្លាំង |
| ៦ | លទ្ធផលសិក្សារបស់សិស្ស បង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន | 4.13 | 0.68 | យល់ស្រប |
| ៧ | មានទំនាក់ទំនងជាប្រចាំជាមួយអាណាព្យាបាលសិស្ស | 3.60 | 0.81 | យល់ស្រប |

| សរុប | 4.1 | 0.31 | យល់ស្រប |
|---|---|---|---|

**តាមតារាងទី១៨(ង)៖** បានបង្ហាញថា ទំនាក់ទំនងរវាងគ្រូ-សិស្ស មានមធ្យមភាគសរុបរួម ៤.១ ដែលស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។ នៅក្នុងចំណុចទំនាក់ទំនងគ្រូ-សិស្សមានសូចនាករវាស់វែងលម្អិតចំនួន ៧ចំណុចសំខាន់ៗដូចជា៖ គ្រូ និងសិស្សមានទំនាក់ទំនងល្អក្នុងដំណើរការបង្រៀន និងរៀន(មធ្យមភាគ ៤.៤៣=យល់ស្របខ្លាំង) សិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរបង្រៀន និងរៀន(មធ្យមភាគ ៣.៨៣=យល់ស្រប) ការឆ្លើយតប និងបកស្រាយចម្ងល់សិស្ស បានក្បោះក្បាយ(មធ្យមភាគ ៤.០៧=យល់ស្រប)បានជំរុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា(មធ្យមភាគ ៤.៤៣=យល់ស្របខ្លាំង) ការបង្កើតបរិស្ថានសិក្សាល្អ ជានាឱ្យសិស្សទទួលបានការរៀនសូត្រដូចៗគ្នា(មធ្យមភាគ ៤.២៣=យល់ស្របខ្លាំង) លទ្ធផលសិក្សារបស់សិស្ស បង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន(មធ្យមភាគ ៤.១៣=យល់ស្រប) ចំណែកឯសូចនាករចុងក្រោយ មានទំនាក់ទំនងជាប្រចាំជាមួយអាណាព្យាបាលសិស្ស មានមធ្យមភាគទាបជាងគេគឺ ៣.៦០ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប។

### ៤. ២. ៦. លទ្ធផលស្រាវជ្រាវលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា

នៅក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទិន្នន័យមធ្យមរួម ទៅលើកម្រិតនៃការអនុវត្តបាននៃកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា តាមទស្សនៈរបស់គ្រូបង្រៀនដែលចូលរួមឆ្លើយនឹងកម្រងសំណួរពាក់ព័ន្ធទៅនឹងចំណុចសំខាន់ៗដូចជា៖ ការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា ដំណើរការបង្រៀន និងរៀន ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន ទំនាក់ទំនងគ្រូ-សិស្ស។

**តារាងទី១៩៖ មធ្យមភាគសរុបរួមរបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ក | ការអនុវត្តកម្មវិធីសិក្សា | 4.27 | 0.23 | ល្អណាស់ |

| | | | | |
|---|---|---|---|---|
| ខ | ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា | 4.01 | 0.25 | ល្អ |
| គ | ដំណើរការបង្រៀន | 4.25 | 0.20 | ល្អណាស់ |
| ឃ | ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន | 4.01 | 0.20 | ល្អ |
| ង | ទំនាក់ទំនងគ្រូ-សិស្ស | 4.1 | 0.31 | ល្អ |
| **សរុប** | | **4.13** | **0.13** | **ល្អ** |

**តាមតារាងទី១៩៖** លទ្ធផលបង្ហាញថា គ្រូបង្រៀនបានចូលរួមបំពេញតួនាទី ភារកិច្ចក្នុងការអនុវត្តកម្មវិធីសិក្សា ដែលបង្ហាញឡើងតាមរយៈសូចនាករសំខាន់ៗដូចជា៖ ការអនុវត្តកម្មវិធីសិក្សា ដែលមានមធ្យមភាគ ៤.២៧(ល្អណាស់) ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា មានមធ្យមភាគ ៤.០១(ល្អ) ដំណើរការបង្រៀន មានមធ្យមភាគ ៤.២៥(ល្អណាស់) ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន មានមធ្យមភាគ ៤.០១(ល្អ) ទំនាក់ទំនងគ្រូ-សិស្ស មានមធ្យមភាគ ៤.១(ល្អ)។ ក្នុងចំណោមសូចនាករវាស់វែងចំនួន ៥ចំណុច ការអនុវត្តកម្មវិធីសិក្សាទទួលកម្រិតមធ្យមភាគខ្ពស់ជាងគេ។ ដោយឡែកមធ្យមភាគសរុបរួមគឺ ៤.១៣ ដែលស្ថិតនៅក្នុងកម្រិតវាស់វែង ល្អ។

## ៤. ៣. ការពិភាក្សាលើកម្រិតនៃការអនុវត្តកម្មវិធីសិក្សា

ឆ្លងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ នៃសំណួរស្រាវជ្រាវផ្នែកទី២ ដែលផ្ដោតសំខាន់ទៅលើការអនុវត្តកម្មវិធីសិក្សា បានបង្ហាញថា ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ទៅលើដំណើរការអនុវត្តកម្មវិធីសិក្សា ដើម្បីធ្វើការកែលម្អបន្ថែមលើការអនុវត្ត ក្នុងន័យលើកកម្ពស់គុណភាពអប់រំឱ្យឆ្លើយតបនឹងគោលនយោបាយកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ជាពិសេសការកំណែទម្រង់កម្មវិធីសិក្សា។ ចំណុចខ្លាំងជាងគេ(មានមធ្យមភាគខ្ពស់ជាងគេ) ក្នុងការអនុវត្តការងារលើការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលាទាំង ១០នាក់ គឺ ការងារដឹកនាំ និងគ្រប់គ្រង ពោលគឺគណៈគ្រប់គ្រងសាលារៀន មានផែនការក្នុងការរៀបចំនូវរចនាសម្ព័ន្ធលើការងារគ្រប់គ្រង និងដឹកនាំទៅលើក្រុមបច្ចេកទេស ការងារប្រតិបត្តិរបស់ក្រុមមុខវិជ្ជាដែលជាប្រធានក្រុម

បច្ចេកទេស ក្នុងការជួយជំរុញ និងទឹកចិត្តគ្រូបង្រៀនតាមរយៈប្រធានក្រុមបច្ចេកទេស ដែលជាអ្នកជំនាញលើមុខវិជ្ជាបង្រៀនរបស់គ្រូ។ ជាការពិតណាស់ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ដែលផ្តោតសំខាន់ទៅលើគោលនយោបាយស្តីពីគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា និងបរិស្ថានសិក្សា ព្រមទាំងកំណែទម្រង់សំខាន់ៗដទៃទៀត ក្នុងគោលបំណងរួមគឺលទ្ធផលសិក្សារបស់សិស្សានុសិស្សកាន់តែមានភាពប្រសើរឡើង។ យ៉ាងណាមិញ នៅក្នុងការងារគ្រប់គ្រង និងដឹកនាំរបស់គណៈគ្រប់គ្រងសាលារៀន វាក៏ជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជំរុញលទ្ធផលសិក្សារបស់សិស្ស ពីព្រោះថាគណៈគ្រប់គ្រងសាលារៀនគឺជា ភ្នាក់ងារនៃការផ្លាស់ប្តូរយ៉ាងសំខាន់របស់ក្រសួងអប់រំនៅថ្នាក់ក្រោមជាតិ ដែលជាអ្នកអនុវត្តផ្ទាល់ជាមួយគ្រូបង្រៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ដើម្បីអនុវត្តនូវចក្ខុវិស័យនេះបានជោគជ័យ ដោយយកចិត្តទុកដាក់លើការផ្តល់ការអប់រំប្រកបដោយគុណភាព និងសាលារៀនសម្រាប់អនាគត ក្រសួងបានបង្កើតសាលារៀនជំនាន់ថ្មីចំនួន១១កន្លែង ដើម្បីសាកល្បងកំណែទម្រង់ការអប់រំជាប្រព័ន្ធ។ យើងមើលឃើញថា គុណភាពអប់រំមានភាពល្អប្រសើរជាងមុន ហើយសិស្សានុសិស្សត្រូវបានបំពាក់ដោយជំនាញរឹង និងជំនាញទន់ ជាពិសេសគំនិតផ្តួចផ្តើមថ្មីៗ ការគិតត្រិះរិះ និងការដោះស្រាយបញ្ហា។ ម្យ៉ាងទៀត ក្រសួងទើបតែបានជ្រើសរើសសាលារៀនចំនួន១០០ បន្ថែមទៀត ដើម្បីបង្កើតជាសាលារៀនគំរូកម្រិតទី២ ដោយក្រសួងកំពុងអនុវត្តក្នុងគម្រោង «ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព (SEIP)»។ ទន្ទឹមនឹងនេះ ក្រសួងក៏បានដាក់ចេញនូវគោលដៅប្រែក្លាយសាលាធនធានចំនួន៥០ ឱ្យក្លាយជាសាលាគំរូផងដែរ។ ទាំងអស់នេះ គឺជាការផ្តោតសំខាន់លើការងារគ្រប់គ្រង និងដឹកនាំរបស់គណៈគ្រប់គ្រងសាលារៀននៅទូទាំងប្រទេសនាពេលអនាគត។ លើសពីនេះ គណៈសាលារៀនត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិតរស់រវើក និងការប្រាស្រ័យទាក់ទងល្អក្នុងការដឹកនាំគ្រប់គ្រងសាលារៀន និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពឆ្លើយតបទៅនឹងបរិបទនៃការអប់រំក្នុងប្រទេស តំបន់ និងពិភពលោក។ ការកំណត់គុណវុឌ្ឍិ និងសមត្ថភាពរបស់គណៈគ្រប់គ្រងសាលារៀននៅតាមប្រភេទគ្រឹះស្ថានសិក្សានីមួយៗ និងផ្លាស់ប្តូរវិធីសាស្ត្រក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីគាំទ្រដល់គ្រូបង្រៀនដែលបានបំពេញការងារទៅតាមសមត្ថភាពទេព

កោសល្យ និងផ្សារភ្ជាប់សាលារៀន និងសហគមន៍ជាដើម។ គណៈគ្រប់គ្រងសាលាត្រូវមានជំនាញចាំបាច់ ដូចជា គ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់ការបង្រៀន និងរៀន ការគ្រប់គ្រងធនធានមនុស្ស។ ក្រសួងអប់រំយុវជន និងកីឡា បានកំណត់នូវស្តង់ដាគណៈគ្រប់គ្រងសាលាត្រូវមាន៦គឺ កម្រិតវប្បធម៌ និងបទពិសោធការងារ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលា បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ ភាពជាអ្នកដឹកនាំគ្រប់គងរដ្ឋបាលសាលា ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន ការផ្សារភ្ជាប់សាលារៀន និងសហគមន៍(ក្រសួង អ.យ.ក ២០១៧)។

ចំណែកឯចំណុចកែលម្អ ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា តាមការលើកឡើងរបស់គណៈគ្រប់គ្រងសាលារៀនគឺ បានបង្ហាញពី ការចូលរួមគាំទ្រក្នុងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន និងរៀន និងលទ្ធផលសិក្សារបស់សិស្ស ដែលជាចំណុចសូចនាករមានតម្លៃមធ្យមភាគស្ថិតក្នុងចំណុចកែលម្អ ក្នុងនោះលទ្ធផលសិក្សារបស់សិស្ស មានតម្លៃមធ្យមភាគទាបជាងគេគឺ ៣.៧។ តាមរយៈលទ្ធផលសិក្សានេះ បានបង្ហាញថា លទ្ធផលសិក្សារបស់សិស្ស ត្រូវតែធ្វើការកែលម្អដោយខានមិនបាន។ គុណភាពអប់រំរបស់បណ្តាប្រទេសនីមួយៗនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ គឺវាបង្ហាញឡើងតាមរយៈលទ្ធផលសិក្សារបស់សិស្សនេះឯង។ ដូចនេះ គណៈគ្រប់គ្រងសាលារៀន ពិតជាត្រូវចូលរួមចំណែកយ៉ាងសំខាន់មិនអាចខ្វះបានក្នុងការធានាបាននូវកូណភាពអប់រំ គឺការយកចិត្តទុកដាក់ និងរិះរកគ្រប់មធ្យោបាយ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស តាមរយៈការចូលរួមជំសរុញការអនុវត្តកម្មវិធីសិក្សាឱ្យបានពេញលេញ និងមានភាពទូលំទូលាយនៅក្នុសាលារៀនដែលខ្លួនគ្រប់គ្រង។ គ្រូបង្រៀន ជាអ្នកអនុវត្តកម្មវិធីសិក្សាផ្ទាល់ជាមួយសិស្ស ក៏ត្រូវតែធានាបានថា ស្ថិតនៅក្រោមការតាមដាន ត្រួតពិនិត្យ វាយតម្លៃជាប្រចាំពីគណៈគ្រប់គ្រងសាលាដែលមានតួនាទីជាអធិការកិច្ចអចិន្ត្រៃយ៍។ បើយោងតាម Hang-Chuon (2018) គណៈគ្រប់គ្រងសាលារៀន ដែលជាអ្នកដឹកនាំស្ថាប័នប្រកបដោយភាពជោគជ័យ ត្រូវប្រកាន់ភ្ជាប់នូវគោលដៅសំខាន់ៗចំនួន៤គឺៈ

- លើកម្ពស់ដំណើរការបង្រៀន និងរៀន ដើម្បីសម្រេចបាននូវលទ្ធផលសិក្សាល្អរបស់សិស្សគ្រប់ៗគ្នា

- ទាក់ទាញការចូលរួមរបស់សហគមន៍ ឱ្យបានទូលំទូលាយ តាមគ្រប់រូបភាពក្នុងដំណើរការគាំទ្រសាលារៀន ការងារបង្រៀន និងរៀន ពីព្រោះថា សហគមន៍ជាផ្នែកមួយរបស់សាលារៀន
- រីករាយក្នុងការលើកកម្ពស់ស្ថានភាពសង្គម សេដ្ឋកិច្ចរស់សិស្សានុសិស្ស
- លើកទឹកចិត្ត និងជំរុញឱ្យមានការអភិវឌ្ឍវប្បធម៌អប់រំក្នុងចំណោមមាតាបិតាសិស្ស។

អំពីការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា តាមការយល់ឃើញរបស់ប្រធានក្រុមបច្ចេកទេសលើការប្រតិបត្តិការងារគឺមានចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អ។ ចំពោះការអនុវត្តបានល្អនៅក្នុងចំណោមសូចនាករវាស់វែងគឺ ការត្រួតពិនិត្យការងារបង្រៀន និងរៀនរបស់គ្រូ ប្រធានក្រុមបច្ចេកទេសបានវាយតម្លៃខ្ពស់។ មានន័យថា ប្រធានក្រុមបច្ចេកទេសបានបំពេញតួនាទីរបស់ខ្លួនក្នុងការងារត្រួតពិនិត្យតាមដាន និងវាយតម្លៃការបង្រៀន និងរៀនរបស់គ្រូបានត្រឹមត្រូវទៅតាមតួនាទីជាប្រធានក្រុមបច្ចេកទេសដែលជាអ្នកជំណាញតាមមុខវិជ្ជារបស់ខ្លួន។ ដោយឡែកចំណុចដែលត្រូវកែលម្អ គឺការងារប្រតិបត្តិរបស់ប្រធានក្រុម ត្រង់ចំណុចនេះបញ្ជាក់ឱ្យឃើញថា ប្រធានក្រុមបច្ចេកទេស នៅមិនទាន់បានយល់ច្បាស់ពីតួនាទីរបស់ខ្លួនក្នុងការដឹកនាំក្រុមបបច្ចេកទេឱ្យដំណើរការល្អនៅឡើយ។ ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាជាតំណាងឱ្យគណៈគ្រប់គ្រងសាលាក្នុងការ ក្នុងនាមជាអ្នកជំនាញឯកទេសតាមមុខវិជ្ជានីមួយៗ។ ប្រធានក្រុមបច្ចេកទេសត្រូវបំពេញតួនាទីផ្សេងៗដូចជា ដឹកនាំសមាជិកការប្រជុំបច្ចេកទេសប្រចាំខែ រៀបចំបំណែងចែកកម្មវិធីសិក្សាជូនសាលា សហការជាមួយគ្រូក្នុងការសិក្សាស្រាវជ្រាវពីវិធីសាស្ត្របង្រៀនថ្មីៗឱ្យស្របតាមបរិបទ តាមតម្រូវការ និងកម្រិតសិក្សារបស់សិស្ស ចូលរួមកែលម្អ វាយតម្លៃលទ្ធផលសិក្សារបស់សិស្សធ្វើថ្នាក់និទស្សន៍ដើម្បីចែករំលែកបទពិសោធន៍ កែលម្អកិច្ចតែងការបង្រៀន និងរៀនរបស់ក្រុម ពិនិត្យតាមដានការបង្រៀន និងរៀនរបស់គ្រូ ដឹកនាំសមាជិកក្រុមក្នុងការផលិត និងប្រើប្រាស់សម្ភារឧបទេសបង្រៀន និងរៀន រាយការណ៍ និងផ្តល់យោបល់ជូនគណៈគ្រប់គ្រងសាលាដើម្បីកែលម្អគុណភាពអប់រំ។ ជាការពិតណាស់ ប្រសិនបើប្រធានក្រុមបច្ចេកទេស មិនបានចូលរួមក្នុងការបំពេញការងារ និងតួនាទីរបស់ខ្លួនឱ្យបានពេញលេញទេនោះ។ វាពិតជានឹងជះឥទ្ធពលដល់ដំណើរការលើកកម្ពស់គុណភាពអប់រំ នៅកម្រិតសាលារៀន ក្នុងកម្រិតណាមួយនោះជាក់ជាមិនខាន។ ផ្អែកទៅតាមលទ្ធផលសិក្សាស្រាវជ្រាវ តាមរយៈការ

ចូលរួមឆ្លើយតបនឹងកម្រងសំណួរស្រាវជ្រាវរបស់ប្រធានក្រុមបច្ចេកទេសចំនួន ១០នាក់ បានបង្ហាញថា ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេសមានតម្លៃមធ្យមភាគទាបគឺ ៤.០៣ តាមរយៈលទ្ធផលនេះពិត ជាបាមបង្ហាញយ៉ាងច្បាស់ថា ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេសនៅតាមសាលារៀនគោលដៅ នៃការសិក្សាស្រាវជ្រាវ ត្រូវធ្វើការកែលម្អ ដើម្បីជានាឱ្យបាននូវលទ្ធផលសិក្សារបស់សិស្សមានគុណភាព តាមរយៈការចូលរួមបានឱ្យបានពេញលេញ តាមតួនាទីជាប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា។

អំពីការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា តាមការយល់ឃើញរបស់គ្រូបង្រៀន លើការអនុវត្ត កម្មវិធីសិក្សា តាមរយៈការឆ្លើយតបនឹងកម្រងសំណួរស្រាវជ្រាវ ដែលផ្តោតលើសូចនាករសំខាន់ៗ ការអនុវត្តកម្មវិធីសិក្សាមានតម្លៃមធ្យមភាគខ្ពស់ជាងគេគឺ ៤.២៧ ដែលស្ថិនៅក្នុងកម្រិតវាស់វែង យល់ស្របខ្លាំង(ល្អណាស់)។ តាមរយៈលទ្ធផលនេះបង្ហាញថា គ្រូបង្រៀនបានអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា បានល្អ ចំណែកឯដំណើរការបង្រៀន និងរៀនក៏មានតម្លៃមធ្យមខ្ពស់បន្ទាប់គឺ ៤.២៥ ដែលស្ថិត នៅក្នុងកម្រិតវាស់វែង យល់ស្របខ្លាំង(ល្អណាស់) ដែលបានបង្ហាញថា ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា ជាពិសេសក្នុងដំណើរការបង្រៀន និងរៀនបានល្អប្រសើរពុំមានបញ្ហាប្រឈមនោះទេ។ ដោយឡែកការប្រើ ប្រាស់សម្ភារឧបទេសបង្រៀន និងរៀន និងការប្រើប្រាស់ឯកសារជំនួយគាំទ្រដល់ការអនុវត្តកម្មវិធីសិក្សា ជាសូចនាករមានកម្រិតវាស់វែងទាបជាងគេគឺ ៤.០១ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប(ល្អ) ក្នុងន័យ នេះហើយ ការប្រើប្រាស់សម្ភារឧបទេសបង្រៀន និងរៀន និងការប្រើប្រាស់ឯកសារជំនួយគាំទ្រដល់ការ អនុវត្តកម្មវិធីសិក្សា នៅតែមានបញ្ហាមួយចំនួនដែលគួរតែធ្វើការកែលម្អបន្តទៀត។

## ៤.៤. ការវិភាគទិន្នន័យលើសំណួរស្តីពីបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា

នៅក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីមធ្យមភាគ ដែលទទួលបានពីការចូលរួមឆ្លើយ នឹងកម្រងសំណួរស្រាវជ្រាវរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបង្រៀន ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា ការងារជាមួយគ្រូបង្រៀន និងសិស្សានុសិស្ស វិធីសាស្ត្របង្រៀនរបស់គ្រូ ក្នុងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាប្រវត្តិវិទ្យាបានជួបប្រទះ នូវបញ្ហាផ្សេងៗនាពេលកន្លងមក។

### ៤. ៤. ១. បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈគណៈគ្រប់គ្រង

នៅក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញនូវលទ្ធផលដែលទទួលបានពីការចូលរួមឆ្លើយនឹងកម្រងសំណួរស្រាវជ្រាវរបស់គណៈគ្រប់គ្រងសាលារៀនចំនួន ១០នៅរាជធានីភ្នំពេញស្តីពី បញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា ពាក់ព័ន្ធទៅនឹងសូចនាករវាស់វែងសំខាន់ៗដូចជា៖ **ដំណើរការអនុវត្តកម្មវិធីសិក្សា ការងារជាមួយគ្រូបង្រៀន និងសិស្សានុសិស្ស និងវិធីសាស្រ្តបង្រៀនរបស់គ្រូ**ជាដើម ដើម្បីរកឱ្យឃើញពីបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា ដែលជះឥទ្ធិពលដល់គុណភាពអប់រំនៅតាមសាលារៀន ក៏ដូចជាវិស័យអប់រំទាំងមូលតាមរយៈការអនុវត្តកម្មវិធីសិក្សា។

**តារាងទី២០៖ ក. ដំណើរការបង្រៀន និងរៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | អនុវត្តកម្មវិធីសិក្សាមិនបានចប់តាមការណែនាំរបស់ក្រសួងអប់រំ | 3.30 | 1.41 | ពុំមានយោបល់ |
| ២ | គ្រូបង្រៀនមិនចប់កម្មវិធីសិក្សា ដោយសារខ្លឹមសារមេរៀនច្រើន | 3.10 | 0.87 | ពុំមានយោបល់ |
| ៣ | បាត់បង់ម៉ោងសិក្សា ដោយសារថ្ងៃឈប់សម្រាកប្រចាំឆ្នាំច្រើន | 3.20 | 0.91 | ពុំមានយោបល់ |
| ៤ | បាត់បង់ម៉ោងសិក្សា ដោយសារការខកខានរបស់គ្រូ | 3.20 | 0.91 | ពុំមានយោបល់ |
| ៥ | បាត់បង់ម៉ោងសិក្សា ដោយសារការខកខានរបស់សិស្ស | 2.80 | 1.13 | ពុំមានយោបល់ |

| | | | | |
|---|---|---|---|---|
| ៦ | បាត់បង់ម៉ោងសិក្សា ដោយសារការឈប់សម្រាកមុនកាលកំណត់ | 3.00 | 0.94 | ពុំមានយោបល់ |
| ៧ | ការចុះអធិការកិច្ចមិនបានទៀងទាត់លើការអនុវត្តកម្មវិធីសិក្សា | 3.00 | 0.94 | ពុំមានយោបល់ |
| ៨ | សម្ភារៈជំនួយបម្រើឱ្យការរៀន និងបង្រៀនមិនគ្រប់គ្រាន់ | 3.20 | 1.03 | ពុំមានយោបល់ |
| ៩ | ការអនុវត្ត មិនស្របតាមរបាយម៉ោងនៃមុខវិជ្ជាប្រវត្តិវិទ្យា | 2.60 | 0.84 | មិនយល់ស្រប |
| ១០ | គ្រូបង្រៀនមិនបានបំពេញតួនាទីភារកិច្ចពេញលេញ | 3.10 | 0.99 | ពុំមានយោបល់ |
| ១១ | ពុំបានពិនិត្យការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស ប្រចាំឆ្នាំ | 3.00 | 1.41 | ពុំមានយោបល់ |
| ១២ | កម្មវិធីសិក្សា មិនបានធ្វើបច្ចុប្បន្នភាព | 3.00 | 1.15 | ពុំមានយោបល់ |
| **សរុប** | | **3.04** | **0.19** | **ពុំមានយោបល់** |

**តាមតារាងទី២០(ក)៖** បញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សា របស់គណៈគ្រប់គ្រងសាលាវិទ្យាល័យទាំង១០ នៅរាជធានីភ្នំពេញមានមធ្យមភាគរួមគឺ ៣.០៤(ពុំមានយោបល់) ក្នុងចំណោមសូចនាករចំនួន១២ចំនុច មានតែការអនុវត្តមិនស្របតាមរបាយម៉ោងនៃមុខវិជ្ជា ប្រវត្តិវិទ្យា(មធ្យមភាគ ២.៦០= មិនយល់ស្រប) ចំណែកឯសូចនាករចំនួន១១ចំណុចផ្សេងទៀតគឺ **កម្រិតពុំមានយោបល់។**

**តារាងទី២១៖ ខ. ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | គ្រូបង្រៀនមិនបានធ្វើការសិក្សាស្រាវជ្រាវបន្ថែម | 2.80 | 0.91 | ពុំមានយោបល់ |
| ២ | ផែនការអធិការកិច្ចគ្រូបង្រៀនមិនបានអនុវត្តជាប្រចាំ | 3.00 | 0.94 | ពុំមានយោបល់ |
| ៣ | មិនបានត្រួតពិនិត្យការងាររដ្ឋបាលគ្រូបង្រៀនជាប្រចាំ | 2.60 | 0.84 | មិនយលស្រប |
| ៤ | មិនបានរៀបចំផែនការវាយតម្លៃគ្រូបង្រៀនទៀងទាត់ | 3.10 | 1.10 | ពុំមាយោបល់ |
| ៥ | មិនដែលបានផ្លាស់ប្តូរសមត្ថភាពគ្រូបង្រៀនជាមួយសាលាដទៃ | 3.90 | 0.73 | យល់ស្រប |
| ៦ | មិនបានត្រួតពិនិត្យទៀងទាត់និយ័តភាពការងាររបស់គ្រូបង្រៀន | 2.90 | 0.99 | ពុំមានយោបល់ |
| ៧ | គ្រូបង្រៀនមួយចំនួនមិនបានអភិវឌ្ឍសមត្ថភាពបន្ថែម | 3.30 | 0.94 | ពុំមានយោបល់ |
| ៨ | ខ្វះធានធានសម្រាប់គាំទ្រដល់ការសិក្សាបន្ថែមដល់សិស្ស | 3.20 | 1.03 | ពុំមានយោបល់ |
| ៩ | បញ្ហាសិស្សរៀនយឺត ពិបាកក្នុងការអនុវត្តកម្មវិធីសិក្សា | 3.60 | 0.69 | យល់ស្រប |
| **សរុប** | | **3.16** | **0.40** | **ពុំមានយោបល់** |

**តាមតារាងទី២១(ខ)៖** ការងារជាមួយគ្រូបង្រៀន និងសិស្សានុសិស្សវិញ លទ្ធផលមធ្យមភាគ និងកម្រិតវាស់វែងបានបង្ហាញថា គណៈគ្រប់គ្រងសាលាពុំទាន់បានយកចិត្តទុកដាក់ក្នុងការធ្វើផែនការអធិការកិច្ចគ្រូបង្រៀន ការត្រួតពិនិត្យរដ្ឋបាលគ្រូបង្រៀន ការត្រួតពិនិត្យនិយ័តភាពរបស់គ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពបន្ថែមរបស់គ្រូបង្រៀន សមរុបមធ្យមភាគរួមគឺ **៣.១៦(ពុំមានយោបល់)**។ ដោយឡែកនៅក្នុងសូចនាករ មិនដែលបានផ្លាស់ប្តូរសមត្ថភាពបង្រៀនជាមួយសាលាដទៃមានមធ្យមភាគខ្ពស់ជាងគេ (មធ្យមភាគ៣.៩០=កម្រិតយល់ស្រប) និងបញ្ហាសិស្សរៀនយឺត ពិបាកក្នុងកាអនុវត្តកម្មវិធីសិក្សា(មធ្យមភាគ ៣.៦០=កម្រិតយល់ស្រប)។

**តារាងទី២១៖ គ. វិធីសាស្ត្របង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | កម្មវិធីសិក្សាមិនស្របតាមវិធីសាស្ត្របង្រៀនថ្មីៗ | 3.00 | 0.94 | ពុំមានយោបល់ |
| ២ | ពិបាកបន្ស៊ីរវាងខ្លឹមសារ និងវិធីសាស្ត្របង្រៀនថ្មីៗ | 3.20 | 0.91 | ពុំមានយោបល់ |
| ៣ | ផលធៀបសិស្ស-គ្រូមានទំហំធំ | 3.50 | 0.85 | យល់ស្រប |
| ៤ | ខ្វះខាតឧបករណ៍ជំនួយផ្នែកបច្ចេកវិទ្យាក្នុងដំណើរការបង្រៀន និងរៀន | 3.30 | 0.82 | ពុំមានយោបល់ |
| ៥ | សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា ICT ក្នុងការបង្រៀន របស់គ្រូបង្រៀននៅមានកម្រិត | 4.00 | 0.47 | យល់ស្រប |
| ៦ | គ្រូមិនទទួលបានការបំប៉នគ្រប់គ្រាន់ពីវិធីសាស្ត្របង្រៀនថ្មីៗ | 3.60 | 0.96 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ៧ | គ្រូបង្រៀនមិនបានផលិត និងប្រើប្រាស់សម្ភារឧបទេស | 3.30 | 0.82 | ពុំមានយោបល់ |
| ៨ | ការសិក្សាស្រាវជ្រាវមេរៀន LS មិនមានដំណើរការ | 3.40 | 0.69 | ពុំមានយោបល់ |
| **សរុប** | | **3.41** | **0.30** | **យល់ស្រប** |

**តាមតារាងទី២២(គ)៖** ទិន្នន័យមធ្យមភាគសរុប(**៣.៤១=យល់ស្រប**) ដែលគណៈគ្រប់គ្រងសាលារៀនបានឆ្លើយតប ទៅនឹងវិធីសាស្ត្របង្រៀនរបស់លោកគ្រូ អ្នកគ្រូ។ ដោយឡែកមានតែចំណុចស្ដីពីសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា ICT ក្នុងការបង្រៀន របស់គ្រូបង្រៀននៅមានកម្រិត ដែលមានមធ្យមភាគខ្ពស់ជាងគេគឺ **៤.០០(កម្រិតយល់ស្រប)** កម្មវិធីសិក្សាមិនស្របតាមវិធីសាស្ត្របង្រៀនថ្មី មានមធ្យមភាគទាបជាងគេគឺ ៣.០០(ពុំមានយោបល់)។

### ៤. ៤. ២. លទ្ធផលស្រាវជ្រាវលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា

នៅត្រង់ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបូកសរុបមធ្យមភាគនៃសូចនាករនីមួយៗ របស់អថេរដែលជាគណៈគ្រប់គ្រងសាលារៀន ដែលទាក់ទងនឹងបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា ដែលផ្ដោតលើដំណើរការបង្រៀន និងរៀន ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន និងវិធីសាស្ត្របង្រៀន។

**តារាងទី២៣៖ មធ្យមភាគសរុបរួមរបស់គណៈគ្រប់គ្រងសាលារៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ក | ដំណើរការបង្រៀន និងរៀន | 3.04 | 0.19 | មធ្យម |
| ខ | ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន | 3.16 | 0.40 | មធ្យម |
| គ | វិធីសាស្ត្របង្រៀន | 3.41 | 0.30 | មិនល្អ |
| **សរុប** | | **3.2** | **0.19** | **មធ្យម** |

**តារាងទី២៣៖** លទ្ធផលក្នុងតារាងខាងលើបានបង្ហាញថា មធ្យមភាគរួមសរុបគឺ ៣.២ ដែលស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់(មធ្យម)។ ចំណែកឯសូចនាករវាស់វែងពាក់ព័ន្ធដទៃទៀតដូចជា៖ ដំណើរការអនុវត្តកម្មវិធីសិក្សា មានមធ្យមភាគ ៣.០៤ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់(មធ្យម) ការងារជាមួយគ្រូបង្រៀន និងសិស្សានុសិស្ស មានមធ្យមភាគ ៣.១៦ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់(មធ្យម) មានតែសូចនាករស្ដីពី វិធីសាស្ត្របង្រៀនទេដែលមានមធ្យមភាគខ្ពស់ជាងគេគឺ ៣.៤១ ស្ថិតនៅក្នុងកម្រិតវាស់វែង យល់ស្រប(មិនល្អ)។

### ៤. ៤. ៣. បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈប្រធានក្រុមបច្ចេកទេស

ក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវ បានផ្ដោតទៅលើសូចនាករសំខាន់ៗ ដែលពាក់ព័ន្ធសម្រាប់ឱ្យប្រធានក្រុមបច្ចេកទេសឆ្លើយតបមានដូចជា៖ ការងារប្រតិបត្តិរបស់គ្រូបង្រៀន និងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន។ តើរាងការយល់ឃើញរបស់ប្រធានក្រុមបច្ចេកទេស ទៅលើចំណុចទាំងពីរខាងលើនេះមានលក្ខណៈដូចម្ដេច។

**តារាងទី២៤៖ ក. ការងារប្រតិបត្តិរបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ការបង្រៀនមិនបានអនុវត្តតាមកម្មវិធីសិក្សា | 2.70 | 1.25 | ពុំមានយោបល់ |
| ២ | ការបង្រៀនដាក់ស្ដែងមិនបានពេញលេញតាមម៉ោងក្នុងកម្មវិធីសិក្សា | 2.70 | 0.94 | ពុំមានយោបល់ |
| ៣ | បង្រៀនមិនចប់កម្មវិធីសិក្សា | 3.00 | 1.41 | ពុំមានយោបល់ |
| ៤ | គ្រូបង្រៀនមួយចំនួនមកបង្រៀនមិនទៀងទាត់ | 2.80 | 1.39 | ពុំមានយោបល់ |

| | | | | |
|---|---|---|---|---|
| ៥ | គ្រូបង្រៀនមួយចំនួនមិនបានចូលរួមប្រជុំក្រុមបច្ចេកទេសទៀងទាត់ | 3.30 | 0.94 | ពុំមានយោបល់ |
| ៦ | ខ្វះឯកសារជំនួយបន្ថែមក្នុងការបង្រៀន និងរៀន | 3.40 | 1.17 | ពុំមានយោបល់ |
| **សរុប** | | **2.98** | **0.31** | **ពុំមានយោបល់** |

**តាមតារាងទី២៤(ក)៖** អំពីដំណើរការប្រតិបត្តិការងារបង្រៀន និងរៀនប្រចាំថ្ងៃរបស់គ្រូបង្រៀន ទស្សនៈរបស់ប្រធានក្រុមបច្ចេកទេសដែលបានឆ្លើយតបមានមធ្យមភាគរួមសរុបគឺ ស្ថិតក្នុងកម្រិត **ពុំមានយោបល់ (មធ្យមភាគ=២.៩៨)**។ ក្នុងចំនោមសូចនាករសរុបចំនួន ៦ចំណុច មានតែចំណុចស្តីពី ខ្វះឯកសារជំនួយបន្ថែមក្នុងការបង្រៀន និងរៀនដែលមានមធ្យមភាគខ្ពស់ជាងគេ(៣.៤០=ពុំមានយោបល់) ឯចំណុចដែលមានមធ្យមភាគទាបជាងគេគឺ ការបង្រៀនមិនបានអនុវត្តតាមកម្មវិធីសិក្សា និងការបង្រៀនជាក់ស្តែងមិនបានពេញលេញតាមម៉ោងក្នុងកម្មវិធីសិក្សា(២.៧០=ពុំមានយោបល់)។ ដោយឡែក ចំពោះសូចនាករដទៃទៀតគឺស្ថិតនៅក្នុងមធ្យមភាគ ដែលមានកម្រិតវាស់វែង **ពុំមានយោបល់** ដូចគ្នាដែរ។

**តារាងទី២៥៖ ខ. ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | មិនមានឯកសារណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សា | 3.40 | 1.35 | ពុំមានយោបល់ |
| ២ | ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលច្រើន | 4.10 | 0.99 | យល់ស្រប |
| ៣ | ខ្វះគ្រូបង្រៀនតាមឯកទេស ឬគ្រូបង្រៀនមិនចំឯកទេស | 2.70 | 1.25 | ពុំមានយោបល់ |

| | | | | |
|---|---|---|---|---|
| ៤ | គ្រូបង្រៀនខុសកម្រិតសិក្សា | 2.60 | 1.35 | មិនយល់ស្រប |
| ៥ | មិនមានសម្ភារឧបទេសគ្រប់គ្រាន់ក្នុងការបង្រៀន និងរៀន | 3.10 | 1.19 | ពុំមានយោបល់ |
| ៦ | ការសង្កេតថ្នាក់រៀនមិនមានប្រសិទ្ធភាព | 2.50 | 1.17 | មិនយល់ស្រប |
| ៧ | គ្រូបង្រៀនមួយចំនួនមិនបានអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបន្ថែម | 3.40 | 0.84 | ពុំមានយោបល់ |
| ៨ | ខ្លឹមសារសៀវភៅសិក្សាគោលមិនបានធ្វើបច្ចុប្បន្នភាព | 3.70 | 0.94 | យល់ស្រប |
| **សរុប** | | **3.19** | **0.57** | **ពុំមានយោបល់** |

**តាមតារាងទី២៥(ខ)៖** អំពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន ទស្សនៈរបស់ប្រធានក្រុមបច្ចេកទេសដែលបានឆ្លើយតបមានមធ្យមភាគរួមសរុបគឺ ក្នុងកម្រិត **ពុំមានយោបល់ (មធ្យមភាគ=៣.១៩)**។ ក្នុងចំនោមសូចនាករសរុបចំនួន ៨ចំណុច មានតែចំណុចស្តីពី ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលច្រើនដែលមានមធ្យមភាគខ្ពស់ជាងគេ(៤.១០=ពុំមានយោបល់) ឯចំណុចដែលមានមធ្យមភាគទាបជាងគេគឺ ការសង្កេតថ្នាក់រៀនមិនមានប្រសិទ្ធភាព(២.៥០=មិនយល់ស្រប) និងគ្រូបង្រៀនខុសកម្រិតសិក្សា(២.៦០=មិនយល់ស្រប)។ ដោយឡែក សូចនាករដទៃទៀតគឺស្ថិតនៅក្នុងមធ្យមភាគ ដែលមានកម្រិតវាស់វែង **ពុំមានយោបល់**។

### ៤. ៤. ៤. លទ្ធផលស្រាវជ្រាវលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា

នៅត្រង់ចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបូកសរុបមធ្យមភាគនៃសូចនាករនីមួយៗ របស់អថេរដែលជាប្រធានក្រុមបច្ចេកទេស ដែលទាក់ទងនឹងបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា ដែលផ្តោតលើការងារប្រតិបត្តិរបស់គ្រូបង្រៀន និងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន។

**តារាងទី២៦៖ មធ្យមភាគសរុបរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ក | ការងារប្រតិបត្តិរបស់គ្រូបង្រៀន | 3.1 | 0.31 | មធ្យម |
| ខ | ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ | 3.19 | 0.57 | មធ្យម |
| **សរុប** | | **3.15** | **0.06** | **មធ្យម** |

**តាមតារាងទី២៦៖** លទ្ធផលក្នុងតារាងបានបង្ហាញថា ប្រធានក្រុមបច្ចេកទេស បានបំពេញការងារប្រតិបត្តិ ជួយដល់សមាជិកក្រុមបច្ចេកទេសក្នុងការបំពេញការងារ ដំណើរការអនុវត្តកម្មវិធីសិក្សា និងជំរុញការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបន្ថែមតាមតារាងខាងលើធ្វើបាននៅក្នុងកម្រិតមធ្យម ដោយយោងទៅតាមតម្លៃមធ្យមភាគគឺ ៣.១៥ ស្ថិតនៅក្នុងកម្រិតវាស់វែង **មធ្យម** នៅឡើយ។

### ៤. ៤. ៥. បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា តាមទស្សនៈគ្រូបង្រៀន

ក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តោតលើសូចនាករសំខាន់ៗ ដែលពាក់ព័ន្ធនឹងគ្រូបង្រៀន ដូចជា៖ ការការបាត់បង់ម៉ោងបង្រៀនដោយកត្តាផ្សេងៗ ដំណើរការបង្រៀន និងរៀន និងបញ្ហាប្រឈមនានាដែលលោកគ្រូ អ្នកគ្រូបានជួបប្រទះនាពេលកន្លងមក។

**តារាងទី២៧៖ ក. ការបាត់បង់ម៉ោងបង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | បាត់បង់ម៉ោងសិក្សា ដោយសារថ្ងៃឈប់សម្រាកប្រចាំឆ្នាំច្រើន | 3.90 | 0.99 | យល់ស្រប |
| ២ | បាត់បង់ម៉ោងសិក្សា ដោយសារការខកខានរបស់គ្រូ | 3.07 | 1.14 | ពុំមានយោបល់ |
| ៣ | ចូលរួមប្រជុំការងារផ្សេងៗរបស់សាលាច្រើន | 3.73 | 1.17 | យល់ស្រប |

| | | | | |
|---|---|---|---|---|
| ៤ | ចូលបង្រៀនយឺតម៉ោង និងចេញមុនម៉ោងកំណត់ | 2.63 | 1.06 | ពុំមានយោបល់ |
| ៥ | បាត់បង់ម៉ោងសិក្សា ដោយសារការខកខានរបស់សិស្ស | 3.27 | 0.98 | ពុំមានយោបល់ |
| ៦ | រង់ចាំសិស្សសម្អាតថ្នាក់មុនចាប់បង្រៀនមេរៀន | 3.50 | 1.10 | យល់ស្រប |
| ៧ | រង់ចាំសិស្សមកដល់គ្រប់ចំនួនមុនចាប់ផ្ដើមមេរៀន | 2.37 | 0.76 | មិនយល់ស្រប |
| ៨ | ការចេញលេងរបស់សិស្សលើសម៉ោងកំណត់ | 2.97 | 0.99 | ពុំមានយោបល់ |
| **សរុប** | | **3.18** | **0.53** | **ពុំមានយោបល់** |

**តាមតារាងទី២៧(ក)៖** ដោយផ្អែកតាមតារាងលទ្ធផលខាងលើមធ្យមភាគរួមសរុបគឺ ៣.១៨ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់។ ក្នុងចំណោមគ្រូបង្រៀន ដែលបានចូលរួមឆ្លើយតបទៅនឹង បញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាប្រវត្តិវិទ្យា ដែលមានសូចនាករលម្អិតចំនួន ៨ចំណុច ភាគច្រើនមធ្យមភាគមានកម្រិតទាប ដែលស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់។ ដោយឡែកសូចនាករដែលមានមធ្យមភាគត្រឹមកម្រិតវាស់វែង **យល់ស្រប** មានដូចជា៖ បាត់បង់ម៉ោងសិក្សា ដោយសារថ្ងៃឈប់សម្រាកប្រចាំឆ្នាំច្រើន(មធ្យមភាគ ៣.៩០=យល់ស្រប) ចូលរួមប្រជុំការងារផ្សេងៗរបស់សាលាច្រើន(មធ្យមភាគ ៣.៧៣=យល់ស្រប) រង់ចាំសិស្សសម្អាតថ្នាក់មុនចាប់បង្រៀនមេរៀន(មធ្យមភាគ ៣.៥០=យល់ស្រប)។

**តារាងទី២៨៖ ខ. ការបង្រៀន និងរៀន**

| លរ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | មិនមានឯកសារណែនាំស្ដីពីការអនុវត្តកម្មវិធីសិក្សា | 2.80 | 0.99 | ពុំមានយោបល់ |
| ២ | បង្រៀនមិនចប់កម្មវិធីសិក្សា | 3.07 | 1.20 | ពុំមានយោបល់ |
| ៣ | ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលច្រើន | 3.67 | 0.92 | យល់ស្រប |
| ៤ | ខ្លឹមសារសៀវភៅសិក្សាគោលនៅមិនទាន់បានធ្វើបច្ចុប្បន្នភាព | 3.37 | 1.06 | ពុំមានយោបល់ |
| ៥ | ការបង្រៀនជាក់ស្ដែងមិនបានពេញលេញ តាមម៉ោងក្នុងកម្មវិធីសិក្សា | 3.40 | 1.03 | ពុំមានយោបល់ |
| ៦ | ខ្វះឯកសារជំនួយបន្ថែមក្នុងការបង្រៀន និងរៀន | 3.50 | 0.90 | យល់ស្រប |
| **សរុប** | | **3.3** | **0.31** | **ពុំមានយោបល់** |

**តាមតារាងទី២៨(ខ)៖** ដោយផ្អែកតាមតារាងលទ្ធផលខាងលើមធ្យមភាគរួមសរុបគឺ ៣.៣ ស្ថិតនៅក្នុងកម្រិតវាស់វែង **ពុំមានយោបល់**។ តាមទិន្នន័យមធ្យមដែលបង្ហាញតាមសូចនាករសំខាន់ៗចំនួន ៦ចំណុចក្នុងតារាងខាងលើ បញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាប្រវត្តិវិទ្យា ទៅលើការងារបង្រៀន និងរៀន ផ្អែកតាមទស្សនៈរបស់គ្រូបង្រៀនដែលបានចូលរួមឆ្លើយនឹងកម្រងសំណួរដែលពាក់ព័ន្ធដែលជាបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សាគឺ ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលច្រើន មានតម្លៃមធ្យមខ្ពស់ជាងគេ(**៣.៦៧=យល់ស្រប**)។

## ៤. ៤. ៦. លទ្ធផលស្រាវជ្រាវលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា

ក្នុងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបូកសរុបមធ្យមភាគរបស់អថេរគ្រូបង្រៀន ដែលទាក់ទងនឹងបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា។

**តារាងទី២៩៖ មធ្យមភាគសរុបរួមរបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ក | ការបាត់បង់ម៉ោងបង្រៀន | 3.18 | 0.53 | មធ្យម |
| ខ | ការបង្រៀន និងរៀន | 3.3 | 0.31 | មធ្យម |
| **សរុប** | | **3.23** | **0.05** | **មធ្យម** |

**តាមតារាងទី២៩៖** លទ្ធផលក្នុងតារាងខាងលើបង្ហាញពីសូចនាករគោលសំខាន់ៗចំនួនពីរចំណុចគឺ ការបាត់បង់ម៉ោងបង្រៀន ដែលមានតម្លៃមធ្យម ៣.១៨ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់(មធ្យម)។ ការបង្រៀន និងរៀន មានតម្លៃមធ្យម ៣.៣០ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់(មធ្យម)។ ជារួមតាមលទ្ធផលសរុបក្នុងតារាងនេះ ដែលផ្តោតលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា បានបង្ហាញតម្លៃមធ្យមភាគស្មើនឹង ៣.២៣ ស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់(មធ្យម)។ នេះបានបញ្ជាក់ថា ការបាត់បង់ម៉ោងបង្រៀន និងការបង្រៀន និងរៀន នៅតែជាបញ្ហាប្រឈមក្នុងដំណើការអនុវត្តកម្មវិធីសិក្សា ទោះបីជាបញ្ហាទាំងនោះបានកើតឡើងស្ថិតនៅក្នុងកម្រិតមួយមធ្យមក៏ដោយ។

## ៤. ៥. ការពិភាក្សាលើបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា

កម្មវិធីសិក្សាពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្តល់នូវចំណេះដឹងដល់សិស្ស។ ការអនុវត្តបាននូវកម្មវិធីសិក្សាបានគ្រប់ជ្រុងជ្រោយ និងពេញលេញពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញគុណភាពអប់រំ។ នៅក្នុងចំណុចស្តីពីបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធី អ្នកសិក្សាស្រាវជ្រាវបានផ្តោតទៅលើតាមរយៈការយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ ទៅលើសូចនាករសំខាន់ៗដូចជា៖ ដំណើរការបង្រៀន និងរៀន ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន វិធីសាស្រ្តបង្រៀន ការងារប្រតិបត្តិរបស់គ្រូបង្រៀន ការបាត់បង់ម៉ោងបង្រៀន។ តាមលទ្ធផលបង្ហាញបានបញ្ជាក់ថាក្នុងចំណោមអថេរជា គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន មានតែសូចនាករស្តីពី វិធីសាស្រ្តបង្រៀនរបស់គ្រូ ដែលមានមធ្យមភាគខ្ពស់ជាងគេគឺ ៣.៤១ ស្ថិនៅក្នុងកម្រិតវាស់វែងយល់ស្រប មានចំណាត់ថ្នាក់មិនល្អ ចំណែកឯសូចនាករដទៃទៀតស្ថិតនៅក្នុងកម្រិតវាស់វែង ពុំមានយោបល់

ដែលមានចំណាត់ថ្នាក់មធ្យម។ តាមរយៈលទ្ធផលនេះបានបង្ហាញថា ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សានៅក្នុងសាលាគោលដៅនៃការសិក្សាស្រាវជ្រាវ វិធីសាស្រ្តបង្រៀនរបស់គ្រូបង្រៀនស្ថិតនៅក្នុងកម្រិតមួយដែលត្រូវធ្វើការពង្រឹងឡើងវិញ ជាគ្រូបង្រៀនត្រូវតែមានការសិក្សាស្រាវជ្រាវ និងបំប៉នផ្នែកវិធីសាស្រ្តបង្រៀនថ្មីៗបន្ថែម ដើម្បីឱ្យឆ្លើយតបនឹងតម្រូវការរបស់សិស្ស ស្របតាមបរិបទសកល និងកម្រិតសិក្សារបស់សិស្ស ក្នុងគោលដៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ម្យ៉ាងវិញទៀត សូចនាករដែលផ្តោតសំខាន់ទៅលើដំណើរការបង្រៀន និងរៀន ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន ការងារប្រតិបត្តិរបស់គ្រូបង្រៀន និងការបាត់បង់ម៉ោងបង្រៀនមានតម្លៃមធ្យមភាគ ដែលស្ថិតនៅក្នុងកម្រិតវាស់វែង មធ្យម នេះក៏បង្ហាញផងដែរថា ក្នុងការអនុវត្តកម្មវិធីសិក្សា លើមុខវិជ្ជា ប្រវត្តិវិទ្យា នៅតាមសាលរៀនគោលដៅទាំង ១០ នៃការសិក្សាស្រាវជ្រាវ មានចំណុចខ្វះខាតជាច្រើន តាមរយៈសូចនាករវាស់វែង ដែលមានការចូលរួមឆ្លើយតបនឹងកម្រងសំណួរស្រាវជ្រាវពីសំណាក់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។

តាមរយៈលទ្ធផលដែលបានបង្ហាញ វាពិតជាមានទំនាក់ទំនងអវិជ្ជមានរវាងគ្រូហើយនឹងសិស្ស ឬក៏ទំនាក់ទំនងនឹងអវត្តមានរបស់សិស្សវានឹងស្តែងចេញពីលទ្ធផលសិក្សារបស់គ្រឹះស្ថាន។ គួយ៉ាងដូចជានៅក្នុងករណីប្រទេស Madagascar ការសិក្សាបានបង្ហាញឱ្យឃើញថា ក្នុងខណៈពេលដែលមានការកែលម្អនូវផែការអប់រំសម្រាប់ទាំងអស់គ្នាកាលពីឆ្នាំ២០០៥ បានលេចជារូបរាងឡើង ម៉ោងបង្រៀនពិតប្រាកដនៅតាមតំបន់មួយចំនួនគឺស្មើនឹងពាក់កណ្តាលនៃម៉ោងដែលក្រសួងអប់រំបានកំណត់។ ដូច្នេះម៉ោងបង្រៀននៅតាមតំបន់ គឺជាកត្តាមួយដែលមានឥទ្ធពលយ៉ាងខ្លាំង ដែលតម្រូវឱ្យលោកគ្រូ អ្នកគ្រូ និងអ្នកសិក្សានៅក្នុងការិយាល័យសិក្សាទាំងអស់ធ្វើការសហការគ្នាដើម្បីបង្កើននូវចំណេះដឹងរបស់សិស្ស។ ម៉ោងបង្រៀនជាផ្លូវការនៅប្រទេសកម្ពុជាមានចំនួន ៦៨៤-៧៦០ ម៉ោងក្នុងមួយឆ្នាំសិក្សា ដែលជាតួលេខមួយដែលទាបជាងអនុសាសន៍ជាលក្ខណៈអន្តរជាតិដែលគួរតែមានពី ៨៥០-១០០០ ម៉ោងក្នុងមួយឆ្នាំសិក្សា។ គុណភាពនៃការអប់រំទាបនៅកម្ពុជា គឺការបាត់បង់នៃម៉ោងបង្រៀនក្រៅផ្លូវការជាមធ្យមនៅឆ្នាំ២០១៣ មានប្រហែល ២៧% នៃម៉ោងបង្រៀន(៥០.៥ថ្ងៃ) ការបាត់បង់នេះ ដោយសារតែការឈប់សម្រាកផ្លូវការការអវត្តមានរបស់គ្រូ និងការបង្រៀនមិនពេញម៉ោងដោយសារចូលយឺត ចេញមុន(Vision, 2017)។

ម្យ៉ាងវិញទៀត បើយោងតាមការសិក្សាស្រាវជ្រាវរបស់ Glatthorn et al. (2019) បានបង្ហាញឱ្យដឹងថា មានគ្រូបង្រៀនប្រមាណជា ៧០.២៣% ដែលមិនអាចមានលទ្ធផលបង្រៀនបានចប់កម្មវិធីសិក្សា ដូចនេះមានតែគ្រូបង្រៀនចំនួន ២០.៧៧% ដែលបានបញ្ចប់នូវកម្មវិធីសិក្សាបានពេញលេញ។ ហេតុផលរបស់លោកគ្រូ-អ្នកគ្រូ បណ្តាលមកពីខ្វះខាតពេលវេលា នេះជាការព្រួយបារម្ភយ៉ាងខ្លាំងទៅលើមុខវិជ្ជាទាំងអស់ដែលក្រសួងអប់រំបានកំណត់។ យោងតាម Abadzi (2007) តួលេខនៃការអវត្តមានខ្ពស់របស់គ្រូបង្រៀន គឺជាការខ្វះខាតទៅលើការវិនិយោគវិស័យអប់រំ។ តាមការស្រាវជ្រាវបានបង្ហាញថា ការអវត្តមានរបស់គ្រូបង្រៀនមាន ១១% នៅក្នុងប្រទេសប៉េរូ ២១% នៅឥណ្ឌូនេស៊ី ២៧% នៅអ៊ុយហ្គង់ដា ៣០% នៅប្រទេសកេនយ៉ា។ សរុបជារួមមានប្រហែល ២០-២៥% ដែលគ្រូបង្រៀនអវត្តមាន ពិសេសសាលារៀននៅតាមតំបន់ជនបទដែលមានអត្រាខ្ពស់។ លើសពីនេះទៅទៀតការបិទសាលារៀន និងការខ្វះខាតពេលវេលាក្នុងការបង្រៀនក្នុងថ្នាក់ក៏ជាកត្តាសំខាន់ផងដែរ។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវ និងសង្កេតនៅតាមសាលារៀន លើប្រធានបទ "**ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាប្រវត្តិវិទ្យានៅមធ្យមសិក្សាទុតិយភូមិ**"(រាជធានីភ្នំពេញ) បានបង្ហាញពីកម្រិតនៃការអនុវត្តកម្មវិធីសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ នូវចំណុចដែលអនុវត្តបានល្អ តាមរយៈតម្លៃមធ្យមដែលខ្ពស់ និងចំណុចដែលគួរកែលម្អបន្ថែម(តម្លៃមធ្យមទាបជាងគេ) ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សា និងដោះស្រាយប្រឈមនានា ដែលគ្រូបង្រៀនបានជួបប្រទះកមន្លងមក ឱ្យកាន់តែមានភាពល្អប្រសើរឡើង។ ខាងក្រោមនេះជាចំណុចសំខាន់ៗពីរ តាមរយៈលទ្ធផលដែលបានបង្ហាញក្នុងការសិក្សាស្រាវជ្រាវនេះ គឺទី១៖ កម្រិតនៃការអនុវត្តបាននៃកម្មវិធីសិក្សា ដែលទទួលបានតម្លៃមធ្យមខ្ពស់ ទី២៖ បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា ដែលទទួលបានតម្លៃមធ្យមទាប។

1) **កម្រិតនៃការអនុវត្តបាននៃកម្មវិធីសិក្សា ដែលមានតម្លៃមធ្យមខ្ពស់ ដែលបង្ហាញថាបានចូលរួមអនុវត្តតាមរយៈអថេរពីគណៈគ្រប់គ្រងសាលា ប្រធនក្រុមបច្ចេកទេស និងគ្រូបង្រៀន៖**

**ក. គណៈគ្រប់គ្រងសាលារៀន៖** បានចូលរួមក្នុងការងារគាំទ្រ និងអនុតវត្តកម្មវិធីសិក្សា ដែលនៅក្នុងនោះរួមមានជាអាទិ៍៖ ការងារដឹកនាំ និងគ្រប់គ្រង ការចូលរួមគាំទ្រការអនុវត្តកម្មវិធីសិក្សា ការងារបង្រៀន និងរៀន ការងារជាមួយសិស្សានុសិស្សជាដើម។ នៅក្នុងចំណោមសូចនាករទាំងអស់ គឺសូចនាករស្តីពីការងារដឹកនាំ និងគ្រប់គ្រងស្ថិនៅក្នុងកម្រិតចង្អុលបង្ហាញល្អ។ ក្នុងន័យនេះ គណៈគ្រប់គ្រងសាលាបានវាយតម្លៃទៅលើការចូលរួមរបស់ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនក្នុងដំណើរការអនុវត្តកម្មវិធីសិក្សាស្ថិតក្នុងកម្រិតល្អ ដែលវាពិតជាបានឆ្លុះបញ្ចាំងពីការបានចូលរួមអនុវត្តកម្មវិធីសិក្សា ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្ស។

**ខ. ប្រធានក្រុមបច្ចេកទេស៖** ប្រធានក្រុមបច្ចេកទេសដើរតួនាទីយ៉ាងសំខាន់ ក្នុងនាមជាអ្នកអនុវត្តកម្មវិធីសិក្សាផ្ទាល់ផង និងជាជំនួយរបស់គណៈគ្រប់គ្រងសាលាទៅលើការងារបច្ចេកទេស និងពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ដើម្បីឱ្យលទ្ធផលបំពេញការងាររបស់គ្រូ និងលទ្ធផលសិក្សារបស់

សិស្សមានគុណភាព។ តាមរយៈការងារសំខាន់ៗដែលប្រធានក្រុមបច្ចេកទេសបានអនុវត្តរួមមានជាអាទិ៍៖ ការងារប្រតិបត្តិរបស់ប្រធានក្រុមបច្ចេកទេស និងការត្រួតពិនិត្យការងារបង្រៀនរបស់គ្រូ។ តាមលទ្ធផលបានចង្អុលបង្ហាញថា ប្រធានក្រុមបច្ចេកទេស បានបំពេញការងារបានល្អ ដើម្បីលើកកម្ពស់ការបង្រៀន និងរៀនរបស់គ្រូ មានន័យថា ប្រធានក្រុមបានរៀបចំផែនការកាងារដឹកនាំក្រុម និងត្រួតពិនិត្យសមាជិកក្រុមបានត្រឹមត្រូវ។

**គ. គ្រូបង្រៀន៖** គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកិច្ចការងារផ្សេងៗ ដែលគណៈគ្រប់គ្រងសាលារៀនបានប្រគល់ឱ្យ និងបំពេញភារកិច្ចតៅតាមតួនាទីជាគ្រូបង្រៀនតាមរយៈធ្វើកិច្ចការងារផ្សេងៗ ដែលបម្រើឱ្យប្រយោជន៍នៃការបង្រៀន និងរៀន ជាពិសេសដើម្បីឱ្យសម្រេចលទ្ធផលសិក្សារបស់សិស្ស។ តាមរយៈការងារសំខាន់ៗ ដែលគ្រូបង្រៀនបានអនុវត្តរួមមានជាអាទិ៍៖ ការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់ឯកសារណែនាំ គាំទ្រការអនុវត្តកម្មវិធីសិក្សា ដំណើរការបង្រៀន ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន ទំនាក់ទំនងគ្រូ-សិស្ស។ តាមលទ្ធផលបានបង្ហាញថា គ្រូបង្រៀនបានអុវត្តបានល្អប្រសើរទៅលើការការអនុវត្តកម្មវិធីសិក្សា និងក្នុងដំណើរការបង្រៀន និងរៀន។ នេះមានន័យថា គ្រូបង្រៀនមានការរៀបចំផែនការបង្រៀន និងរៀនបានត្រឹមត្រូវ និងមានភាពទៀងទាត់ក្នុងការបង្រៀនផងដែរ។

**2) បញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា ដែលមានតម្លៃមធ្យមទាប ដែលបង្ហាញពីដំណើរការអនុវត្តនៅមិនទាន់មានភាពរលូនល្អនោះទេ តាមរយៈអថេរពីគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន៖**

លទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា ក្នុងការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា ដំណើរការបង្រៀនរបស់គ្រូតាមសាលារៀនបានជួបប្រទះបញ្ហាប្រឈមច្រើន បើទោះបីជាអ្នកពាក់ព័ន្ធមានដូចជាគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន មានការយល់ដឹងច្បាស់អំពីគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សា សេចក្តីណែនាំស្តីពីការប្រើប្រាស់ម៉ោងបង្រៀនទៅតាមកម្រិតថ្នាក់យ៉ាងណាក៏ដោយ វាមិនទាន់មាន

ប្រសិទ្ធភាពក្នុងការជំរុញឱ្យអគ្រាបង្រៀនចប់កម្មវិធីសិក្សាបានពេញលេញ និងសម្រេចលទ្ធផលសិក្សារំពឹងទុកបានល្អនៅឡើយទេ។ បញ្ហាដែលនៅតែកើតមានបណ្ដាលមកពីមូលហេតុមួយចំនួនដែលបានបញ្ជាក់ពីបញ្ហានោះ**ទី១៖** ការអភិវឌ្ឍសមត្ថភាពបន្ថែមរបស់គ្រូបង្រៀន ទាំងចំណេះដឹងខ្លឹមសារ និងវិធីសាស្ត្របង្រៀនថ្មីៗដែលសមស្របតាមបរិបទ ស្របតាមតម្រូវការ និងកម្រិតរបស់អ្នកសិក្សា មិនទាន់បានល្អ។ ជាការពិតណាស់ កម្មវិធីសិក្សាមានការប្រែប្រួលផ្លាស់ប្ដូរជាបន្តបន្ទាប់ ដើម្បីតម្រូវតាមការប្រែប្រួលនៃចរន្តសកលទាំងផ្នែកសេដ្ឋកិច្ច សង្គម នយោបាយ វប្បធម៌ជាដើម។ **ទី២៖** ការបង្រៀន និងរៀន តម្រូវឱ្យផ្សារភ្ជាប់ទៅនឹងចិត្តវិទ្យា គរុកោសល្យ វិធីសាស្ត្របង្រៀន បច្ចេកវិទ្យា ដែលជាចំណុចសំខាន់ក្នុងការដឹកនាំសិស្សឱ្យចេះស្វែងរកប្រភពព័ត៌មាន យល់ឱ្យបានស៊ីជម្រៅទៅលើខ្លឹមសារ និងស្វ័យសិក្សាពេញមួយជីវិត។ ដូច្នេះគ្រូបង្រៀនត្រូវតែមានផែនការក្នុងការដឹកនាំសិស្សឱ្យចេះរៀសូត្រ តាមរយៈការស្វែងរកនូវប្រភពឯកសារជំនួយ រៀបចំផែនការបង្រៀន កិច្ចតែងបង្រៀន និងប្រើប្រាស់នូវវិធីសាស្ត្រសម្បូរបែបក្នុងការបង្រៀន និងរៀន។ **ទី៣៖** ទាក់ទងទៅនឹកម្រិតនៃការប្រើប្រាស់សម្ភារឧបទេស សម្រាបជួយដល់សកម្មភាពបង្រៀន និងរៀន។ តាមរយៈការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជា ប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ បានបង្ហាញថា មេរៀនជាច្រើនតម្រូវឱ្យគ្រូបង្រៀនប្រើប្រាស់នូសម្ភារឧបទេស ដើម្បីឱ្យសិស្សកាន់តែមានចំណាប់អារម្មណ៍ទៅលើការសិក្សា ធ្វើឱ្យសិស្សងាយយល់ខ្លឹមសារ ជួយសន្សំពេលវេលា និងធ្វើឱ្យគ្រូមិនចាំបាច់បន្តធ្វើជាអ្នកផ្ទេរចំណេះដឹងទៅឱ្យសិស្សទាំងស្រុងនោះទេ។

ជាមួយគ្នានេះដែរ ខណៈដែលការអនុវត្តកម្មវិធីសិក្សាមិនបានពេញលេញ ស្របតាមកាណែនាំរបស់ក្រសួងអប់រំ វានឹងជះឥទ្ធិពលជាអវិជ្ជមានទៅលើលទ្ធផលសិក្សារបស់សិស្ស អ្នករៀបចំគោលនយោបាយអបរំ អ្នករៀបចំកម្មវិធីសិក្សាថ្មី និងអ្នកអនុវត្តផ្ទាល់ ហើយវាពិតជាមិនអាចចូលរួមចំណែកសម្រេចបានគោលនយោបាយកំណែទម្រង់វិស័យអប់រំ ដើម្បីធានាឱ្យការអប់រំមានគុណភាពនោះទេ។

សរុបមកអ្នកសិក្សាស្រាវជ្រាវបានរកឃើញថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជា ប្រវត្តិវិទ្យា នៅមធ្យមសិក្សាទុតិយភូមិ នៅមានភាពខ្វះចន្លោះច្រើន និងអនុវត្តមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយ

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវឃើញថា ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជា ប្រវត្តិវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ មានបញ្ហាប្រឈមមួយចំនួនដូចជា ទៅលើដំណើរការបង្រៀន និងរៀន មិនទាន់បានពេញលេញទៅតាមម៉ោងកំណត់របស់ក្រសួងអប់រំ ការងារប្រតិបត្តិរបស់គ្រូបង្រៀននៅមានកម្រិត ការបាត់បង់ម៉ោងបង្រៀន គ្រូបង្រៀនមិនបានអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបន្ថែម ហើយក្នុងនោះដែរ វិធីសាស្ត្របង្រៀន ក៏ជាបញ្ហាប្រឈមយ៉ាងសំខាន់ដែលអ្នកអនុវត្តបានជួបប្រទះ។ ការអនុវត្តកម្មវិធីសិក្សា គួរត្រូវបានយកចិត្តទុកដាក់ និងដោះស្រាយរាល់បញ្ហាប្រឈមនានាឱ្យបានទាន់ពេលវេលា ឆ្លើយតបទៅនឹងកំណែទម្រង់គុណភាពអប់រំ របស់ក្រសួងអប់រំក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

## ៥. ២. សំណូមពរ

